ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Oct-2012, 16:00
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី១១៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដារ អានសាន

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ឃីត រេយ៍ន័រ (*Mr.Keith RAYNOR*)

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្លួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក មាស វឿន (TCW-428) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក មាស វឿន** (TCW-428)

សួរបន្តដោយលោក ពេជ អង្គ ផ្ដើមពី៖ .................................................................ទំព័រ ៣
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី៖ .........................................ទំព័រ ១៣
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖.......................................................ទំព័រ ២៣
សួរដោយលោក សុន អរុណ ផ្ដើមពី៖...................................................................ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយកាលពីសវនាការពិភាក្សាដេញដោលថ្ងៃព្រហស្បតិ៍សប្តាហ៍មុន គឺយើងដល់វេទិកាទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលចប់ដោយក្រុមមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីជាតិហើយ នៅខាងអន្តរជាតិ។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

សូមអញ្ជើញលោកមេធាវី! លោកមេធាវីប្រសិនបើលោកមានការអី លោកចងចាំថាលោកស្នើសុំប្រធានបទដែលលោកមានបំណងនិយាយជាមុនសិន ហើយនិងហេតុផលដែលនាំឲ្យលោកមានបំណងធ្វើសេចក្តីថ្លែងការណ៍កាត់ពេលវេលាដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនេះ ដើម្បីអង្គជំនុំជម្រះសម្រេចថាអនុញ្ញាតឲ្យលោកធ្វើដូច្នេះ ឬមិនអនុញ្ញាតឲ្យទេ។ នេះគឺជាវិធានទូទៅដែលអង្គជំនុំជម្រះកត់សម្គាល់ឃើញថាការកំណត់របស់អង្គជំនុំជម្រះឲ្យភាគីដែលពាក់ព័ន្ធធ្វើដូច្នេះ លោកមេធាវីកម្រនឹងបានប្រព្រឹត្តតាមការណែនាំរបស់អង្គជំនុំជម្រះណាស់។

[០៩:០៦:១៤]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីអស់លោក លោកស្រី។ ខ្ញុំគិតថាអស់លោក លោកស្រីមានពេលវេលាល្អក្នុងចុងសប្តាហ៍ ខ្ញុំមានចំណុចពីរ។ ចំណុចទី១ គឺខ្ញុំសូមលើកអំពីប្រតិចារឹក នេះគឺជាសេចក្តីស្នើសុំដោយផ្ទាល់មាត់របស់ខ្ញុំ ដែលខ្ញុំបានលើកឡើង ដែលថាលោក នួន ជា -- ដែលវាពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់លោក លោកចៅក្រម។ ហើយដែលខ្ញុំលើកឡើងបញ្ជាក់ថាពេលដែលលោកចៅក្រមដើរចេញទៅខាងក្រៅនោះ គឺមិនអាចដោះស្រាយបញ្ហាបាននោះទេ។

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។ មានបញ្ហាអីទៀតទេ?

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

ខ្ញុំមាន។ ខ្ញុំមានចំណុចពីរខ្លីៗ។ ចំណុចទី១ អំមិញ អម្បាញ់មិញនេះ។ ចំណុចទី២ គឺសំណើសុំឲ្យបញ្ជាក់បន្ថែម ពាក់ព័ន្ធទៅនឹងចៅក្រម ខាតវ៉ាយថ៍ លើកឡើងកាលពីថ្ងៃពុធ។ ជាការពិត គឺលោកមិនយល់អំពីនីតិវិធីដែលយើងអនុវត្តនៅទីនេះ ជាពិសេសអ្វីដែលយើងអនុវត្តតាម។ ហើយយើងមិនលុបចោលទេចំពោះការដោះស្រាយលើបញ្ហារបស់លោក។ ចំណុចនេះគឺជាអ្វីដែលអង្គជំនុំជម្រះបានសម្រេច ហើយចៅក្រម ខាតវ៉ាយថ៍ បានលើកឡើង។ ក្របខ័ណ្ឌផ្លូវច្បាប់នោះមិនមែនអនុញ្ញាតឲ្យយើងគូសចំណុចហ្នឹងចោល ដើម្បីជាដំណោះស្រាយនោះទេ។

[០៩:០៨:០៨]

ពីរថ្ងៃក្រោយមក គឺថាចៅក្រមលើកឡើងចំណុចនេះ ហើយលោកស្រីបានចុះហត្ថលេខាទៅលើដីកាសម្រេចលុបចោលចំណុចដែលបានលើកឡើងនៅក្នុងប្រតិចារឹកនោះ។ ចៅក្រម ខាតវ៉ាយថ៍ គាត់បានបញ្ជាក់ហើយថា “ការគូសចំណុចក្នុងប្រតិចារឹកចោលនេះ មិនមែនជាដំណោះស្រាយនោះទេ” ក៏ប៉ុន្តែគាត់បានចេញដីកាមួយ ហើយចុះហត្ថលេខាលុបចោលចំណុចប្រតិចារឹកក្នុងនោះវិញ។

ខ្ញុំសូមលើកឡើងអ្វីដែលចៅក្រម ហាន់ នៅអាយ.ស៊ី.ធី.វ៉ាយ បានបញ្ជាក់ ជាពិសេសនៅក្នុងរឿងក្តី មីឡូសឺវិក គាត់បានលើកឡើងនូវអ្វីដែលចៅក្រម ឡូត នោះបានបំពេញការងារ។ ខ្ញុំគឺគ្រាន់តែលើកឡើងអំពីការណែនាំតែប៉ុណ្ណោះ។ ហើយគឺការដែលលើកឡើងនោះ គឺមានន័យថា វាអ្វី ដែលខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់តែប៉ុណ្ណោះ។ បញ្ហាចោទនោះគឺថាវាមានចំណុចច្រើន។ ចំណុចដែលលើកឡើងនោះគឺវាពាក់ព័ន្ធទៅនឹងចំណុចមួយចំនួនទៅលើប្រតិចារឹក។

**ប្រធានអង្គជំនុំ៖**

បានហើយៗ យើងមិនអនុញ្ញាតឲ្យលោកនិយាយទៀតទេ។ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាង អ៎! ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកនិយាយតទៅទៀតទេ។ កត់ត្រាចូលក្នុងប្រតិចារឹក ថាយើងប្រធានសាលាដំបូងមិនអនុញ្ញាតឲ្យលោកនិយាយបញ្ហានេះតទៅទៀតទេ។ វេទិកានេះយើងបានផ្តល់តាំងពីដំបូង

ទីឲ្យទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី សាធារណជន ព្រះសង្ឃគ្រប់ព្រះអង្គ និងដើមបណ្តឹងរដ្ឋប្បវេណី។ តាមការពិត សំណួរដែលខ្ញុំបានលើកមិនទាន់បានចប់ទេទៅសាក្សីរូបនេះ។ ហើយខ្ញុំចង់សូមបញ្ជាក់ជាមួយលោកប្រធានថា ពេលវេលារបស់ដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃមុនបានចំណាយពេល២០នាទី ហើយថ្ងៃនេះ តើត្រឹមត្រូវទេដែលខាងយើងខ្ញុំនៅសល់ ១ម៉ោងទៀត?

បាទ សូមអរគុណលោកប្រធាន។

[០៩:១០:៥៣]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរបន្តដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមជម្រាបសួរលោកអ៊ំ មាស វឿន។ ខ្ញុំលើកបន្តទៀត ពីសប្តាហ៍មុនថ្ងៃព្រហស្បតិ៍ លោកអ៊ំបានមានប្រសាសន៍ថា តាម៉ុក បានធ្លាប់បង្រៀនលោកអ៊ំមួយចំនួន។ តើលោកអ៊ំអាចជម្រាបបានទេ ថាតើតាម៉ុក គាត់ធ្លាប់បង្រៀនអ៊ំនៅពេលណា? ហើយពេលដែលគាត់បង្រៀនអ៊ំហ្នឹង ថាតើគាត់បង្រៀនអំពីអ្វីខ្លះ?

**លោក មាស វឿន៖**

**ឆ៖** បាទ តាម៉ុក បានបង្រៀនខ្ញុំតាំងពីនៅព្រៃ ក៏ប៉ុន្តែការដែលបង្រៀននៅព្រៃនោះផ្សេង ហើយបង្រៀនដល់ពេលវៃនោះផ្សេង។ ទី១ បង្រៀននៅព្រៃ ឲ្យដឹងពីសភាពប្រទេសរបស់យើងមិនទាន់បានឯករាជ្យ ជាពិសេសសេដ្ឋកិច្ចនៅក្រោមអាណានិគមបារាំងត្រួតត្រាទាំងអស់។ ហើយដល់ពេលដែលដល់ពេលមាន ដល់ពេលវៃសមរភូមិ គាត់បង្រៀនពីទិសនៃវៃទាហាន ឬវៃសត្រូវខ្លាំង គឺបង្រៀនពីការវៃភូមិ វៃទីតាំង វៃតាមផ្លូវជាតិ ផ្តាច់ស្ពាន ផ្តាច់ផ្លូវ នេះដែលកាលគាត់បង្រៀនបាទ។ ហើយទី៣ ពេលដែលឈ្នះហើយ គាត់បង្រៀនពីរឿងឲ្យយើងការពារប្រទេស ហើយនិងកសាងប្រទេស ដៃមួយដៃម្យាងវៃខ្មាំង ដៃម្ខាងការពារជាតិ។ ហ្នឹងអង្គាល់ទិសគាត់បង្រៀនអ៊ីចឹងបាទ។

**ស៖** បាទ អរគុណលោកអ៊ំ។ ខ្ញុំចាប់អារម្មណ៍ចំណុចមួយ ដែលលោកអ៊ំបានលើកអំពីបញ្ហាផ្តាច់ស្ពាន គាត់បង្រៀនអំពីរឿងផ្តាច់ស្ពាន ផ្តាច់ផ្លូវ ថាតើហេតុអ្វីបានជាចាំបាច់ពេលធ្វើសង្គ្រាមត្រូវមានការផ្តាច់ស្ពាន ផ្តាច់ផ្លូវយ៉ាងដូច្នេះ?

[០៩:១៣:៣២]

**ឆ៖** បាទ ក្នុងការដែលវ៉ៃខ្មាំងផ្តាច់ស្ពាន ផ្តាច់ផ្លូវ គឺជាផ្លូវ ឬក៏ជាឈាម ដែលសម្រាប់មានការទាក់ទងរវាងខ្មាំង ដូច្នេះ ដើម្បីវ៉ៃបានជ័យជម្នះ ទាល់តែយើងផ្តាច់សរសៃឈាម ឬក៏ផ្លូវតូចធំរបស់ខ្មាំងបាទ។

**សះ** តើគាត់មានបង្រៀនថាតើត្រូវធ្វើយ៉ាងដូចម្តេចនៅពេលធ្វើសង្គ្រាមហ្នឹង ថាតើត្រូវធ្វើយ៉ាងម្តេច ដូចម្តេចចំពោះប្រជាជនដែរឬទេលោកអ៊ំ?

**ឆ៖** បាទ ក្នុងការវ៉ៃខ្មាំង គឺថាប្រជាជនខ្មាំង ឬក៏ប្រជាជនធម្មតា គឺថាអត់ឲ្យមានការធ្វើបាបទេ។ តែជាក់ស្តែងកន្លងមក ទាហានដែលត្រូវវ៉ៃបាន ចាប់បានក្នុងឆ្នាំ១៩៧០ គឺយកមកតាម -- ដាក់តាមភូមិមែន ហើយខ្ញុំផ្ទាល់ក៏បាននាំទាហានចាប់បានហ្នឹងយកមកដាក់សមរភូមិខាងក្រោយ។ ហើយក្នុងនោះមានប្រពន្ធ ឬក៏កូនទាហានស្លាប់ ហើយក៏គាត់ឲ្យជួយពមកដាក់តាមមូលដ្ឋានរំដោះ ក្នុងនោះគាត់ឲ្យលុយកាក់ ហើយធ្វើបុណ្យធ្វើទានសម្រាប់ដែលគ្រួសារ ឬក៏កូនបាត់បង់ជីវិតក្នុងពេលយើងប្រយុទ្ធក្នុងសមរភូមិបាទ។

**សះ** បាទ អរគុណលោកអ៊ំ។ ខ្ញុំចង់សួរបញ្ជាក់ថែមទៀតថា អំពីតម្លៃនៃការណែនាំ ឬក៏ការបញ្ជាពីថ្នាក់លើ ថាតើការបញ្ជា ឬក៏ការណែនាំ ឬក៏គោលនយោបាយដែលដាក់ពីថ្នាក់លើមក កន្លងមកដែលអ៊ំធ្លាប់ធ្វើជាយោធាហ្នឹង ថាតើអ្វីដែលថាពីថ្នាក់លើមកគឺគេត្រូវតែអនុវត្តតែម្តងឲ្យខាងតែបាន ឬក៏ទាហានមានសិទ្ធិផងដែរនៅក្នុងការមិនអនុវត្ត?

**ឆ៖** បាទ ក្នុងគម្រោងការ និងផែនការដែលដាក់មក ចុះមកឲ្យអ្នកខាងក្រោមធ្វើគឺបញ្ជាការសមរភូមិ គឺដាច់ខាត ឧបមាថា បើត្រូវវ៉ៃកន្លែងណាគឺត្រូវវ៉ៃឲ្យបាន គឺអត់ឲ្យមានការដកថយទេ។ បើសិនជាមានការដកថយលុះត្រាណាតែមានបញ្ជាថ្មីទៀត ទោះបីសមរភូមិក្តៅយ៉ាងណាក៏ដោយ ក៏ដាច់ខាតមិនឲ្យដកបាទ។

[០៩:១៦:៣៤]

**សះ** តើធ្លាប់មានករណីដែលបញ្ជាត្រូវបានឲ្យទៅធ្វើ ហើយមានការដកថយដែរឬទេ?

**ឆ៖** បាទ ក្នុងការដែលបញ្ជាឲ្យធ្វើ ឲ្យបាននោះ ក្នុងពេលដែលធ្វើមិនបាននោះគឺមានការ កន្លែងខ្លះធ្វើអត់បានដែរ។ ពិសេសគឺថា ដោយសារតែកម្លាំងខ្មាំងធំជាងយើង ហើយជួនកាលខ្មាំងវ៉ៃយើងទៅយើងបាក់រត់រតាត់រតាយហ្នឹង គឺថាអត់បាច់បញ្ជាអ្នកណាឲ្យដកទេ គឺដកដោយវិធីខ្លួនឯង បាទ។

**ស៖** បាទ លោកអ៊ំខ្ញុំសូមចូលទៅក្នុងៗពេលវេលាចន្លោះពីឆ្នាំ១៩៧៥ ដល់ ៧៩ តើលោកអ៊ំអាចបញ្ជាក់បានទេថា បញ្ជាដែលពីថ្នាក់បញ្ជាទៅខាងទាហាន ខាងយោធារបស់អ៊ំនោះ ថាតើគេត្រូវតែអនុវត្តឲ្យខាងតែបានដូចដែលលោកអ៊ំមានប្រសាសន៍ពីមុនដែរឬទេ?

[០៩:១៧:៥៦]

**ឆ៖** បាទ ក្រោយពីឆ្នាំ១៩៧៥ - ៧៩ គឺថាការបញ្ជា ខាងខ្ញុំបញ្ជាតែត្រឹមវ៉ៃការពារព្រំដែន។ ការការពារព្រំដែនគឺថា មុខសញ្ញារបស់ខ្ញុំ គឺសត្រូវ ឬក៏ប្រទេសជិតខាងមិនមានអីប៉ះពាល់ធ្ងន់ធ្ងរទេ។ ឯទឹកដីក៏មិនអាចនឹងត្រូវបោះយកបានដែរ ទី១។ ទី២ គឺថាខ្លួនឧបត្ថម្ភខ្លួន គឺថាការពារផង ហើយនិងធ្វើស្រែចិញ្ចឹមអង្គភាពផង កន្លែងនោះខ្ញុំធ្វើមិនបានដែរ។ ដូចឧបមាថា តាមសមុទ្រវាទឹកប្រៃ ខ្ញុំធ្វើបានខ្លះក៏ប៉ុន្តែចំណុចខ្លះ ខ្ញុំធ្វើមិនបាន។ អាហ្នឹងគឺថា ផែនការដែលដាក់ចុះមក។ បាទ ប៉ុណ្ណេះ។

**ស៖** តើលោកអ៊ំអាចបញ្ជាក់បានទេ អម្បាញ់មិញអ៊ំថា ការៗការងារនៅក្នុងការការពារព្រំដែនតើមានបញ្ហាពាក់ព័ន្ធទៅនឹងអ្នកដែលរត់ចេញទៅនៅថៃ រត់ទៅថៃ ឬក៏ពាក់ព័ន្ធនឹងអ្នកមកនេសាទ បញ្ហាដែលពាក់ព័ន្ធទៅនឹងការចាប់ពួកគាត់ហ្នឹងថាតើជាបញ្ហាទាំងអស់នោះ ៗ ត្រូវតែគោរពតាមតែម្តង ឬក៏ថាយ៉ាងដូចម្តេច?

**ឆ៖** បាទ កន្លែងដែលប្រជាជន កាលដែលខ្ញុំទៅនៅនោះ គឺថាប្រជាជនត្រូវដកចេញមកក្រោយអស់ហើយ ក៏ប៉ុន្តែផ្លូវនោះ គឺមិនអាចប្រជាជនរត់ចេញចូលបានទេ ពីព្រោះត្រូវឆ្លងកាត់ព្រែក កាត់ព្រៃជាពិសេសគឺព្រែកដែលមិនអាចឆ្លងបានទេ ទី១។ ទី២ ទៀត គឺថាចំពោះអ្នកដែលអ្នកនេសាទតាមសមុទ្រ ពិសេសប្រទេសជិតខាងនេសាទត្រីតាមសមុទ្រ គឺថាបើសិនជាចូលទឹកដី ឬដែនទឹករបស់យើងជ្រៅ គឺគាត់ដាក់បញ្ហាថា យើងត្រូវតែចាប់ បើចាប់មិនបាន គេរត់រួចក៏រត់ទៅ ក៏ប៉ុន្តែថាបើចូលចាប់ត្រីនៅក្នុងដែនសមុទ្រយើងជ្រៅ សំខាន់គឺថាត្រូវតែចាប់ឲ្យបាន។ ប៉ុន្តែក្នុងពេលនោះ យើងអាចចាប់បានខ្លះមិនបានខ្លះក្នុងគេនេសាទត្រីក្នុងដែនសមុទ្រយើង បាទ។

[០៩:២០:៤០]

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំចូលទៅប្រធានបទមួយទៀត ពាក់ព័ន្ធទៅនឹងរឿងវាយចូលភ្នំពេញ តើលោកអ៊ំអាចបញ្ជាក់បានទេ ទាហានខាងអ៊ំដែលវាយមកភ្នំពេញហ្នឹង ថាតើការវាយមកលើកងទ័ព លន់ នល់ រយៈពេលប៉ុន្មានថ្ងៃ បានភ្នំពេញត្រូវបានកាន់កាប់ទាំងមូល? និយាយចាប់ពីពេលចាប់ផ្តើមវាយភ្នំពេញរហូតទៅដល់ពេលដែលជោគជ័យលើភ្នំពេញទាំងមូលហ្នឹង។

**ឆ៖** បាទ ក្នុងពេលដែលបើកវាយសមរភូមិនៅភ្នំពេញ ខ្ញុំទទួលផែនការពីកងពលតែ៥ថ្ងៃទេ។ ៥ថ្ងៃ ហៅថាសមរភូមិក្តៅ ហើយផែនការដែល៥ថ្ងៃ ត្រូវវ៉ៃរំដោះភ្នំពេញ គឺរំដោះថ្ងៃ១៨ មេសា។ នេះជាផែនការជារួម ប៉ុន្តែដល់តែយើងវ៉ៃដោយក្តៅទៅ គឺថា ត្រូវរំដោះថ្ងៃ១៧ មេសា ឆ្នាំ៧៥។ ប៉ុន្តែយើងឃើញថា គឺទទួលផែនការពីថ្ងៃទី--

**ស៖** បាទ សូមៗអរគុណលោកអ៊ំ សូមកាត់អ៊ំបន្តិចកន្លែងហ្នឹង។ ខ្ញុំចូលទៅដល់សំណួរមួយទៀត ព្រោះអ៊ំអម្បាញ់មិញអ៊ំបានឆ្លើយនឹងសំណួរខ្ញុំរួចហើយ។ លោកអាចបញ្ជាក់បានទេ ទាហានដែលមកតាម មកវាយនៅភ្នំពេញ ថាតើទាហានហ្នឹងគឺគេបែងចែកទៅតាម ជាទាហានកងពល ឬក៏គេបែងចែកជាទាហានរបស់ភូមិភាគ ដែលមកវាយយកភ្នំពេញហ្នឹង? ហើយនៅពេលដែលថាចូលមកដល់ភ្នំពេញហើយ ថាតើការកាន់កាប់ភ្នំពេញហ្នឹង គឺគេកាន់កាប់តាមមុខព្រួញកងពល ឬក៏កាន់កាប់តាមភូមិភាគ? មានការបែងចែកការកាន់កាប់នៅលើទីក្រុងភ្នំពេញដែរឬទេ ពេលនោះ?

[០៩:២២:៥១]

**ឆ៖** បាទ បើតាមខ្ញុំដឹងខ្លះ បាទ បែងចែកតាមអង្គភាពកងពល និរតីកាន់កាប់ខាងនិរតី កាលនោះមិនមានបស្ចិមទេ។ ខាងបូព៌ាកាន់កាប់ខាងបូព៌ាទៅ ខាងឧត្តរកាន់កាប់ខាងឧត្តរ។ បាទ ខ្ញុំដឹងថាការកាន់មានប៉ុណ្ណឹង។

**ស៖** តើគេមានបែងចែកនៅលើផែនទីភ្នំពេញ គេមានបែងចែកផ្នែកណានៃភ្នំពេញកាន់កាប់ដោយឧត្តរ ផ្នែកណានៃភ្នំពេញកាន់កាប់ដោយនិរតី ឬក៏ខាងបូព៌ាដែរឬទេអ៊ំ?

**ឆ៖** បាទ ក្នុងពេលនុំង គេៗបែងចែកតែក្នុងពេលដែលយើងកំពុងតែវ៉ៃទេ ដល់ពេលដែលឈ្នះរំដោះហើយនោះ ហ្នឹងគឺថាដូចជាមិនមានការបែងចែកទេ តាមខ្ញុំដឹង បាទ។

**ស៖** ពីសប្តាហ៍មុនអ៊ំបានបញ្ជាក់ចំណុចមួយ ដែលខ្ញុំចាប់អារម្មណ៍ គឺថាខាងនិរតីរបស់អ៊ំ គឺកាន់កាប់ពីម្តុំបុរីកីឡាទៅខាងលិច អ៊ីចឹងផ្នែកខាងនិរតី។ ថាតើមានការ -- មានផ្នែកផ្សេងៗទៀតទាហានរបស់ភូមិភាគផ្សេងៗទៀតកាន់កាប់ មានការបែងចែងកាន់កាប់ទៅលើផ្នែកផ្សេងៗទៀតដែរទេ? ហើយតើផ្នែកផ្សេងៗទៀត អ៊ំអាចជម្រាបបានទេ ផ្នែកផ្សេងៗទៀតនៅភ្នំពេញកាន់កាប់ដោយទាហានភូមិភាគណា?

[០៩:២៤:៣៨]

**ឆ៖** បាទ ខ្ញុំដឹងថាមុខសញ្ញាខាងភូមិភាគនិរតី ខ្ញុំដឹងថា មុខសញ្ញាខ្ញុំមានដូចលោកបានរៀបរាប់

អ៊ីចឹង។ តែមុខសញ្ញាដទៃទៀត ខ្ញុំមិនបានទៅដល់ចំណុចហ្នឹងទេ ពីព្រោះប្រហែលជាដូចគ្នាអ៊ីចឹងដែរ តាមមើលទៅ ក្នុងពេលដែលយើងរំដោះភ្លាមហ្នឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងទាហាន លន់ នល់។ អ៊ំអាចរៀបរាប់បានទេ ដែលអ៊ំឃើញផ្ទាល់ហ្នឹង ថាតើទាហាន លន់ នល់ ពេលដែលអ៊ំវ៉ៃទៅលើទាហាន លន់ នល់ ហ្នឹងក្នុងរយៈពេល៥ថ្ងៃ ដែលវ៉ៃឲ្យដាច់ហ្នឹង។ តើទាហាន លន់ នល់ មានគ្នាច្រើនដែរឬទេ នៅពេលដែលតតាំងជាមួយទាហានរបស់អ៊ំ? ហើយនៅពេលដែលចូលដល់ភ្នំពេញ ថាតើមានទាហាន លន់ នល់ ច្រើនដែរឬទេ ដែលគាត់ទម្លាក់អាវុធ?

**ឆ៖** បាទ ក្នុងពេលដែលវ៉ៃ មុខសញ្ញាខ្ញុំមិនសូវមានការគ្រោះថ្នាក់ទេ ទាហាន លន់ នល់ ចាប់ពីពោធិ៍តុងទៅដល់ភ្នំពេញ។ ប៉ុន្តែដល់ពេលដែលចូលដល់ទីក្រុងហើយ គឺមានសភាពអត់មានផ្ទុះ ឬអត់មានបាញ់គ្នាអីតទៀតទេ។ តាមមើលឃើញទាហាន លន់ នល់ ទាំងនោះប្រហែលជា -- ដូចអត់ឃើញមានក្នុងបន្ទាយផង។ ឃើញនៅ ជួនកាលនៅលើឡាន ក្នុងមួយឡាន សេ.អឹម.សេ អ៊ីចឹងទៅ។ ទៅណោះ ឃើញមួយឡាន សេ.អឹម.សេ អ៊ីចឹងទៅ។ គឺថាដូចជាមិនមានឃើញបន្ទាយនៅក្នុងក្រុង។ អានេះដែលខ្ញុំចូលមកបានមួយចំណិតខាងលិចនោះបាទ។

[០៩:២៦:២៧]

**ស៖** តាមការវាយ អ៎! ភាពជាក់ស្តែង ការវាយទៅលើទ័ព លន់ នល់ ពេលនោះមានការលំបាកទេសម្រាប់ទ័ពរបស់អ៊ំ? ហើយមានការចាំបាច់ប្រើកាំភ្លើងធន់ធំអីដែរឬទេ?

**ឆ៖** បាទ ពីពេលដែលកំពុងវ៉ៃដល់ត្រឹមពោធិ៍តុងហ្នឹង យើងប្រើកាំភ្លើងធ្ងន់ធន់ត្រឹម១២០លី ហើយនិងកាំភ្លើង អាខូសេតហ្នឹង។ ហើយដល់ពេលដែលដល់ទីក្រុងហើយ យើងអត់មានប្រើកាំភ្លើងធំទៀតទេ ហើយប្រើត្រឹមកាំភ្លើងដៃមួយប្រាវ ប៉ុន្តែក្រោយមក គឺយើងឈប់ប្រើទាំងអស់បាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងរឿងពេលវាយភ្នំពេញដែរ ប៉ុន្តែផ្តោតជាពិសេសទៅលើប្រជាជន។ អ៊ំមានប្រសាសន៍ពីសប្តាហ៍មុនថា ប្រជាជនពេលវាយភ្នំពេញ គឺប្រជាជនពេលចូលមកដល់ឃើញប្រជាជននៅសម្ងំនៅក្នុងផ្ទះ។ តើអ៊ំអាចជម្រាបបានទេ តើប្រជាជនដែលនៅតាមផ្ទះហ្នឹងមានចំនួនតិច ឬច្រើន ហើយមានលក្ខណៈយ៉ាងណាខ្លះ? ជាអ្នកឈឺ អ្នកជា ក្មេងចាស់ ឬក៏យ៉ាងម៉េចអ៊ំ? អ៊ំអាចបញ្ជាក់បានទេ?

[០៩:២៨:០៧]

**ឆ៖** បាទ ខ្ញុំបានចូលទៅដល់ តែមិនជ្រៅប៉ុន្មានទេក្នុងមុខសញ្ញាខ្ញុំ។ ប៉ុន្តែចូលទៅដំបូងឃើញប្រជាជន គាត់ចងទង់សនៅតាមផ្ទះថ្ម ហើយគាត់មិនចូលក្នុងផ្ទះទេ គាត់អង្គុយតាមកន្លែងដែលគាត់អង្គុយតាមវង់ផ្ទះថ្មហ្នឹងនៅលើហ្នឹង។ ហើយប្រជាជនខ្លះគាត់នៅខាងក្រោម គាត់ចុះមក គាត់បានប្រាប់ពីរឿងអត់បាយ ហើយនិងថ្នាំពេទ្យ ដូចជាមិនឃើញអីដែលមានការគ្រោះថ្នាក់ទេតាមមើល។ ហ្នឹងខ្ញុំឃើញតែប៉ុណ្ណឹង ហើយក្រៅពីហ្នឹងទៀត ក៏អត់មាន គាត់មិនមានការចុះដើរឆ្វេចឆ្វាច ពិសេសនៅឃើញតែកងទ័ពខ្មែរក្រហមហ្នឹងនៅតាមផ្លូវថ្នល់ តាមអីហ្នឹង។ ឯប្រជាជនគាត់នៅតែលើផ្ទះ ចាំមើលតែយើង ហើយនិងបានប្រាប់ពីរឿងអត់បាយ អត់ម្ហូប ចំណី អត់ថ្នាំពេទ្យតែប៉ុណ្ណឹងឯង បាទ។

[០៩:២៩:២៣]

**ស៖** តើលោកអាចបញ្ជាក់បានទេថា មានអ្នកណាគេដោះស្រាយបញ្ហាម្ហូបចំណី ឬ -- ហើយនិងថ្នាំពេទ្យជូនប្រជាជនដែលអត់នោះដែរឬទេ ពេលដែលគាត់និយាយថា គាត់អត់បាយ អត់មានថ្នាំពេទ្យនោះ?

**ឆ៖** ខ្ញុំមិនបានដឹងចំណុចត្រង់ដែលប្រជាជនអត់បាយ ហើយគេដោះស្រាយនោះ ខ្ញុំអត់បានដឹងថាគេដោះស្រាយរបៀបម៉េចទេ ក៏ប៉ុន្តែខ្ញុំចូលដល់មកកន្លែងនោះ គឺចូលកន្លែងថ្នាំពេទ្យនោះ ប្រជាជនគាត់ចុះមករើកញ្ចក់ ហើយគាត់ចូលទៅយកថ្នាំពេទ្យខ្លួនគាត់ហ្នឹង ហើយមុតឈាមហើយ ខ្ញុំក៏ប្រាប់គាត់ថា កុំចូលមុតកញ្ចក់ ឈាមនៅក្នុងមន្ទីរពេទ្យហ្នឹង ហើយខ្ញុំក៏ថយមកវិញមក ហ្នឹងគាត់ចូលយកយ៉ាងម៉េច ខ្ញុំមិនដឹង។ ហើយក្រោយមក មិនដឹងជារបស់ទាំងអស់នោះ គេដោះស្រាយយ៉ាងណានោះ ខ្ញុំអត់បានចូលនៅ តាមដានមើលទៀតទេ បាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ លោកអ៊ំមានប្រសាសន៍អម្បាញ់មិញ គឺចូលយកថ្នាំពេទ្យនៅមន្ទីរពេទ្យ។ អ៊ីចឹងមានន័យថា លោកអ៊ំនៅមន្ទីរពេទ្យហើយពេលនោះ លោកអ៊ំបានទៅមន្ទីរពេទ្យ។ តើលោកអ៊ំអាចជម្រាបបានទេ ថាតើមនុស្សនៅមន្ទីរពេទ្យមានចំនួនច្រើនដែរឬទេ ដែលលោកអ៊ំទៅឃើញហ្នឹង? ហើយមានអ្នកជំងឺច្រើនដែរឬទេ ពេលនោះ?

[០៩:៣១:១៣]

**ឆ៖** បាទ អត់មានប្រជាជនផង ជាពិសេសគឺឃ្លាំងៗថ្នាំពេទ្យ គាត់រើយក កន្លែងឃ្លាំងថ្នាំពេទ្យ ហើយអ្នកជំងឺ បុគ្គលិកពេទ្យអត់មានឃើញផង បាទ។

**ស៖** បាទៗ ខ្ញុំសួរសំណួរបន្តបន្ទាប់ទៀត។ តើលោកអ៊ំដែលបានជួបជាមួយនឹងប្រជាជនដែល

នៅទីក្រុងភ្នំពេញហ្នឹង ថាតើប្រជាជនមានមនុស្សចាស់ មានជំងឺ មានកុមារច្រើនទេ នៅទីក្រុងភ្នំពេញ ពេលដែលវាយបានទីក្រុងភ្នំពេញ?

**ឆ៖** បាទ ឃើញច្រើនដែរ តែមិនដឹងចំនួនប៉ុន្មានទេ ប៉ុន្តែឃើញគាត់នៅគ្រប់តែផ្ទះថ្ម នៅគ្រប់តែផ្ទះ គ្មានសល់ផ្ទះណាមួយទេ បាទ។

**ស៖** តើពេលនោះ ទ័ពអ៊ំមាននិយាយអ្វីខ្លះជាមួយប្រជាជនដែរឬទេ? មាននិយាយឲ្យគាត់មានការទុកចិត្តទៅលើទ័ពរបស់អ៊ំដែរឬទេ ដែលអ៊ំចូលទៅជួបពួកគាត់ហ្នឹង?

**ឆ៖** បាទ គ្រាន់តែប្រាប់គាត់មួយម៉ាត់ពីរថា កុំឲ្យភ័យឲ្យខ្លាចអី គេឈប់វ៉ៃ ឈប់ឲ្យមានផ្ទុះអាវុធតទៅទៀត។ ហើយខ្ញុំក៏អត់បាននៅកន្លែងហ្នឹងយូរដែរ ខ្ញុំថយមកនៅក្រោយណេះវិញហើយ បាទ។

[០៩:៣៣:០០]

**ស៖** តើពេលដែលអ៊ំថយមកខាងក្រោយវិញ អ៊ំឃើញគេ ប្រជាជនចេញពីទីក្រុង។ តើពេលនោះ ប្រជាជនគាត់មានបានយកសម្ភារៈអ្វី យកទៅតាមខ្លួនគាត់ដែរឬទេពេលនោះ ដូចទ្រព្យសម្បត្តិរបស់គាត់ គាត់មានយកទៅតាមគាត់ដែរឬទេ? ហើយគាត់ធ្វើដំណើរចេញហ្នឹង គាត់ប្រើមធ្យោបាយអីខ្លះ? គាត់ដើរ ជិះកង់ ម៉ូតូ ឡាន លោកអ៊ំអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ខ្ញុំថយមកនៅតាមផ្លូវស្ទឹងមានជ័យ ប្រហែលជាបីថ្ងៃ ឃើញប្រជាជនគាត់ចេញមក មានខ្លះដើរ មានអ្នកខ្លះស្ពាយៗ មានអ្នកខ្លះរុញរទេះរបស់របរគាត់ហ្នឹង ហើយមានកូន មានចៅគាត់ហ្នឹង ហើយខ្លះទៀត រុញទាំងឡានមកទៀត អត់សាំង ឡានវាអត់សាំង គាត់រុញទាំងឡានមក។ ឡានណាដែលអាចរុញបានមក ក៏រុញ មិនដឹងគាត់រុញដល់ណាទេ តែរុញអ៊ីចឹងមក។ ដូច្នេះរបស់របររបស់គាត់ គាត់យកបាន។ អ្នកខ្លះយកបានលុយបាន អ្នកខ្លះយកបាន សំពាយ ឬក៏ឡាន ឬក៏ម៉ូតូ គាត់អូសមកទាំងអស់របស់គាត់បាន ទាំងអស់ តាមផ្លូវអ៊ីចឹងមករហូត មិនដឹងជាគាត់ទៅដល់ណាទេ ខ្ញុំមិនដឹងថា ទិសដៅរបស់គាត់ទៅដល់ណាដែរ អង្កាល់ណោះ បាទ។

[០៩:៣៤:៣៣]

**ស៖** តើលោកអ៊ំមានបានទឹកមុខរបស់ពួកគាត់ទេ ថាតើគាត់សប្បាយចិត្តនឹងដើរចេញពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ គាត់ប្រាប់ៗខ្ញុំខ្លះដែរ គាត់ថា គាត់ស្ពាយរបស់របរគាត់ខ្លះដែរ ក៏ប៉ុន្តែយើងមើលទឹក

មុខមាត់គាត់ គាត់ធម្មតា ក៏មិនសូវរីករាយប៉ុន្មានដែរ ក៏ប៉ុន្តែថា -- ឃើញថា ជាពិសេសគឺទ្រព្យសម្បត្តិរបស់គាត់ដែលគាត់យកមិនអស់ហ្នឹង ហើយអង្ករ ស្ពាបព្រាអីអត់មានទេ។ ពិសេសអង្ករ គឺអង្គស្ពាបព្រាអត់មានទាំងអស់។ ដែលចេញមកហ្នឹង តែបើខោអាវស្អីៗ គាត់យកបានខ្លះរបស់គាត់បាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំមួយសំណួរទៀតពាក់ព័ន្ធនឹងប្រធានបទនេះថា តើលោកអ៊ំមានដឹងទេថា ពេលដែលគាត់ចេញពីភ្នំពេញហ្នឹង គាត់មានត្រូវបានគេបញ្ជាក់ថា គាត់មាន -- គាត់អាចត្រឡប់មកភ្នំពេញបានដែរឬទេ? គាត់ត្រឡប់មកវិញបានដែរឬទេ គាត់មានបាននិយាយ ឬក៏ថាមានអ្នកណាគេបញ្ជាក់ ទាហានបញ្ជាក់ប្រាប់គាត់ថាអ៊ំចេញទៅ -- បងប្អូនចេញទៅ ហើយត្រឡប់មកវិញបានដែរឬទេ? មានសិទ្ធិត្រឡប់មកវិញទេ?

[០៩:៣៥:៥៩]

**ឆ៖** បាទ ខ្ញុំដូចមិនឮគាត់និយាយថា "ឲ្យគាត់ចេញ ឬក៏ឲ្យត្រឡប់មកវិញ" អត់មានឮគាត់និយាយផង គាត់ចេះតែទៅៗ។ ទៅតំបន់រំដោះ គាត់ប្រាប់ថា "ទៅតំបន់រំដោះ"ៗ អ៊ីចឹងទៅ សួរគាត់អ៊ីចឹង គាត់ឆ្លើយតែអ៊ីចឹង។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំមានពីរចំណុចទៀតចង់សួរទៅលោកអ៊ំ ដើម្បីឲ្យលោកអ៊ំបញ្ជាក់ ហើយមិនជាវែងប៉ុន្មានទេ។ លោកអ៊ំស្គាល់លោក ហ៊ូ យន់ ពេលដែលលោកអ៊ំនៅក្នុងព្រៃ។ លោកអ៊ំបានការពារគាត់នៅក្នុងពេលអ៊ំជាទាហានរបស់ តាម៉ុក។ នៅពេលក្រោយ ១៧មេសា ឆ្នាំ១៩៧៥។ តើលោក ហ៊ូ យន់ ហ្នឹងគាត់ៗ -- ជោគវាសនារបស់លោក ហ៊ូ យន់ ហ្នឹងវាយ៉ាងម៉េច? តើលោកអ៊ំអាចដឹងបានទេ? ហើយក្រោយមកទៀត គាត់នៅរស់ ឬក៏ថាយ៉ាងម៉េច ក្រោយ៧៩?

**ឆ៖** បាទ ខ្ញុំដឹងថា លោក ហ៊ូ យន់ និងលោក ហ៊ូ នឹម គឺកាលពីនៅព្រៃ ខ្ញុំធ្លាប់ស្គាល់គាត់ ហើយស្រឡាញ់គាត់។ និយាយអ្នកទាំងបីហ្នឹង ខ្ញុំស្រឡាញ់គាត់ដូចជាៗ បង ឬក៏ដូចជាឪពុកខ្ញុំអ៊ីចឹង។ ក៏ប៉ុន្តែដល់ពេលឆ្នាំ៧៥ ខ្ញុំបែកគាត់ពីឆ្នាំ១៩៧០ ដែលខ្ញុំមិនបានស្គាល់មុខគាត់រហូតតាំងពីខ្ញុំធ្វើទ័ព។ ដល់ពេលឆ្នាំ៧៥ មកដល់ ៧៩ ខ្ញុំអត់បានឃើញមុខគាត់រហូត។ តែគ្រាន់តែមិត្តភក្តិខ្លះដែលនិយាយប្រាប់ខ្ញុំថា លោក ហ៊ូ នឹម ថា "គេចាប់"។ ថារឿងអីអ្វី? ទេ រឿងសីលធម៌នៅក្នុងអង្គភាពហ្នឹង។--

[០៩:៣៨:១១]

**ស៖** បាទ សូមអត់ទោសលោកអ៊ំ។ ខ្ញុំចង់សួរអំពីលោក ហ៊ូ យន់ ថាតើមានអ្វីកើតឡើងចំពោះលោក ហ៊ូ យន់ ដែរឬទេ?

**ឆ៖** បាទ អ្នកទាំងពីរហ្នឹងដូចគ្នា ខ្ញុំគឺថាលោក ហ៊ូ យន់ ក៏អត់បានជួបមុខ ទាំងពីរនាក់ហ្នឹងអត់បានជួបមុខរហូតទាល់តែ៧៩ អត់បានជួបមុខរហូតបាទ។

**សៈ** តើលោកអ៊ំមានធ្លាប់ឮអ្វីពាក់ព័ន្ធទៅនឹងលោក ហ៊ូ យន់ ទេថា តើគាត់នៅរស់ ឬក៏ថាយ៉ាងម៉េច?

**ឆ៖** ខ្ញុំឮថា គាត់ស្លាប់ហើយ គាត់ត្រូវគេចាប់អ៊ីចឹង។ នៅតែស្លាប់ មិនទេដឹងទេ ខ្ញុំគ្រាន់ថា ត្រូវគេចាប់បាទ។

**សៈ** តើលោកអ៊ំមានបានដំណឹងទេថា ហេតុអ្វីបានជាលោក ហ៊ូ យន់ ត្រូវបានគេចាប់?

**ឆ៖** បាទ តាមឮគេថា គេចាប់ ថាគាត់ហ្នឹងមានការប្រឆាំង ឬក៏ទំនាស់ពីរឿងការចាយលុយ ឬមិនចាយលុយ។ ខ្ញុំឮគេថា ឮប៉ុណ្ណឹងឯងបាទ។

[០៩:៣៩:៤៩]

**សៈ** បាទ សូមអរគុណលោកអ៊ំ។ ខ្ញុំសួរបន្ថែមទៀតជាចំណុចចុងក្រោយ ពាក់ព័ន្ធទៅនឹងកាលលោកអ៊ំនៅព្រះវិហារ ហើយកាលនោះ លោកអ៊ំត្រូវបានប្រាប់ថា ទៅមើលប្រជាជននៅព្រះវិហារទៅតាមដានមើលនៅទីនោះ ហើយប្រជាជនមានការខ្វះខាត។ ហើយតើលោកអ៊ំធ្លាប់រាយការណ៍អំពីការខ្វះខាត អំពីស្ថានភាពរបស់ប្រជាជននៅព្រះវិហារហ្នឹងមកខាងមជ្ឈិមដែរឬទេ? ហើយបើរាយ-ការណ៍ លោកអ៊ំរាយការណ៍ទៅខាងណា?

**ឆ៖** បាទ កាលដែលខ្ញុំទៅព្រះវិហារហ្នឹង កាលដែលទៅគឺ ប៉ុល ពត គាត់ណែនាំខ្ញុំថាឲ្យមិត្តទៅមើលប្រជាជនកន្លែងនុ៎ង គេចាប់ច្រើនហើយអត់បាយ។ ដល់ខ្ញុំទៅគេចាប់មែន ហើយប្រជាជនក៏ត្រូវអត់បាយមែន។ ហើយដល់ពេលដែលខ្ញុំទៅហ្នឹង គឺខែ៨ ឆ្នាំ៧៨ ៗខ្ញុំទៅបានតែ៤ខែទេ ត្រូវវៀតណាមវ៉ៃចូលស្រុកខ្មែរ។ ហើយដល់ពេលខ្ញុំទៅ ដែលត្រូវរាយការណ៍ ឬមិនរាយការណ៍នោះ ពេលនោះខ្ញុំបានរាយការណ៍ដំបូងមានតែមនុស្សដែលត្រូវគេចាប់ គេចាប់ដាក់ឃុំឃាំង គេចាប់ដាក់គុក។ កន្លែងខ្លះឃុំឃាំង កន្លែងខ្លះដាក់គុកនៅឯសៀមរាប។ ប៉ុន្តែដល់ពេលវេលាដែលទៅត្រូវខ្លីពេក ខ្ញុំមិនបានរាយការណ៍មកថ្នាក់លើ គឺខ្ញុំរាយការណ៍បានតែម្ដងគត់ ពីរឿងបងប្អូនលោក ខៀវ សំផន ហើយនិងប្រជាជនត្រូវអត់បាយ ប្រជាជនត្រូវដែលគេដាក់ឃុំឃាំង គឺបានរាយការណ៍តែម្ដងប៉ុណ្ណោះ ពេលនោះគឺត្រូវវៀតណាមវ៉ៃចូលស្រុកខ្មែរ ក៏ដាច់ខាងទូរស័ព្ទ ខាងសារទូរលេខខាងលើក៏ដាច់ ហើយខ្ញុំក៏មិនដឹងរាយការណ៍ទៅឯណា ខ្ញុំអត់បានរាយការណ៍។ រាយការណ៍បានតែម្ដងប៉ុណ្ណោះបាទ។

[០៩:៤២:១៦]

**ស៖** បាទ អរគុណលោកអ៊ំ។ នៅពេលដែលអ៊ំរាយការណ៍មកថ្នាក់លើហ្នឹង អ៊ំរាយការណ៍ទៅខាងណា? អ៊ំអាចបញ្ជាក់បានទេ អម្បាញ់មិញខ្ញុំអត់ទាន់បានឮ?

**ផ៖** បាទ រាយការណ៍មកលោក ខៀវ សំផន។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ នៅពេលដែលរាយាការណ៍ទៅលោក ខៀវ សំផន ហើយតើលោកអ៊ំមានបានដឹងទេ ថាតើមានដំណោះស្រាយអ្វីខ្លះដែលសម្រាប់ជួយប្រជាជន ទាំងការអត់បាយ ទាំងការដែលថាប្រជាជនត្រូវបានគេឃុំឃាំង ថាតើមានដំណោះស្រាយទេពេលនោះ មានដំណោះស្រាយពីខាងលើមកដែរឬទេ?

**ផ៖** បាទ គាត់អត់បានផ្តល់យោបល់អីឲ្យខ្ញុំតបមកវិញផង ខ្ញុំគ្រាន់តែរាយការណ៍ប៉ុណ្ណឹង គាត់អត់មានតបយោបល់មតិអីមកខ្ញុំផង។ ខ្ញុំកំណត់ថា អ្នកដែលត្រូវគេឃុំឃាំងនៅវៀងប្រហែលជា៥០០ ខ្ញុំកំណត់ ខ្ញុំលែងខ្លួន ខ្ញុំឲ្យគាត់ឲ្យទៅផ្ទះ ឲ្យទៅផ្ទះ ឲ្យទៅបងប្អូនទៅ ហើយចំណែកនៅខាងសៀមរាបខ្ញុំអត់បានដឹងទេបាទ។

[០៩:៤៣:៣៧]

**ស៖** បាទ អរគុណលោកអ៊ំ។ បន្ទាប់មកទៀត ថាតើស្ថានភាពអត់បាយរបស់ប្រជាជននៅតែបន្តទៀត ឬយ៉ាងណា?

**ផ៖** បាទ ពេលនុំងប្រជាជនអត់បាយ ក្នុងពេលដែលខ្ញុំទៅដល់ ស្រូវជិតទុំអស់ហើយ ខ្ញុំឲ្យប្រជាជនគាត់ច្រូត។ អង្កាល់ដែលខ្ញុំមិនទាន់ទៅហ្នឹង គឺអត់ -- សហករណ៍គេអត់ឲ្យប្រជាជនច្រូត ខ្លះដើម្បីនេះ ប៉ុន្តែខ្ញុំឲ្យរៀបចំច្រូតស្រូវហ្នឹង ដើម្បីដោះស្រាយតាមសហករណ៍។ ហើយប្រជាជនដែលគេប្រមូលយកទៅដាក់ព្រៃឆ្ងាយពីហ្នឹងមានចិន មានអី ខ្ញុំប្រមូលឲ្យមកនៅក្នុងភូមិ សហករណ៍វិញទាំងអស់ អត់ឲ្យនៅតាមអង្គភាពក្នុងព្រៃទេ។ ពិសេសនៅកន្លែងតាលក់ កន្លែងអីហ្នឹង ហើយផ្សាអីហ្នឹង។ ហើយខ្ញុំឲ្យគាត់មកនៅតាមសហករណ៍វិញទាំងអស់។ កាលខ្ញុំទៅឃើញគេប្រមូលដាក់ទៅក្នុងព្រៃតាម១ពួកគាត់អ៊ីចឹងទៅ ដាំដំឡូងដាំអីហូបអ៊ីចឹងទៅ ដល់នេះខ្ញុំប្រមូលមកវិញអស់។ បាទ ប៉ុណ្ណឹង។

[០៩:៤៤:៥៤]

**ស៖** បាទ អរគុណលោកអ៊ំ។ សំណួរចុងក្រោយរបស់ខ្ញុំអម្បាញ់មិញអ៊ំមានប្រសាសន៍ថាប្រជាជននៅវៀងដែលជាប់ឃុំឃាំង៥០០នាក់ត្រូវបានដោះលែង ក៏ប៉ុន្តែពីសប្តាហ៍មុនចម្លើយរបស់អ៊ំថា

ក្នុងចំណោមប្រជាជនទាំងអស់នោះ គឺមានដោះលែងតែបងថ្លៃរបស់លោក ខៀវ សំផន តែម្នាក់ តែប៉ុណ្ណោះ។ អ៊ីចឹងលោកអ៊ំអាចបញ្ជាក់ឡើងវិញបានទេ អំពីចំណុចនេះដើម្បីជៀសវាងកុំឲ្យមានភាពខុសគ្នានឹងចម្លើយលោកអ៊ំ ថាតើប្រជាជនផ្សេងៗពីបងថ្លៃរបស់លោក ខៀវ សំផន ត្រូវបានដោះលែងដែរឬទេ? នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ សូមអរគុណលោកអ៊ំ។

**ឆ៖** បាទ អាហ្នឹងន៎ ខ្ញុំនៅឯព្រះវិហារ ហើយខាង បងសឿង គាត់នៅខាងសៀមរាប ដែលខ្ញុំដែលថា ដោះលែង ខ្ញុំដោះលែងនៅរវៀង ស្រុករវៀង ដែលគេឃុំឃាំងចំនួន ៥០០នាក់ អាហ្នឹងគេអត់ឃុំឃាំងទេ គឺកន្លែងគេដាក់ អ៎! កន្លែងគេដាក់ឃុំហើយ មានកន្លែងមើលការពារដែរ តែអត់មានរបងមានអីទេ អហ្នឹងខ្ញុំលែងនៅពេលដែលវៀតណាមវ៉ៃចូលព្រំដែនយើងជ្រៅៗ ខ្ញុំលែងទាំងអស់ទៅ។ តែសៀមរាប ខ្ញុំអត់បានដឹងទេ។ អំមិញខ្ញុំបានបញ្ជាក់អ៊ីចឹងហើយបាទ។

[០៩:៤៦:១៨]

**លោក ពេជ អង្គ៖**

បាទ អរគុណលោកអ៊ំដែលឆ្លើយសំណួររបស់ខ្ញុំ។ ជាបន្តគឺខ្ញុំសុំផ្ទេរសិទ្ធិជូនសហភាតារបស់ខ្ញុំដើម្បីបន្តសំណួរលើកជូនចំពោះលោកអ៊ំតទៅទៀត។ សូមអរគុណដែលលោកអ៊ំខំប្រឹងឆ្លើយ។ សូមអរគុណ។ សូមអរគុណលោកប្រធាន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោកសាក្សី ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកដោយសម្របទៅតាមពេលវេលាបន្តិចបន្តួចដែលនៅសល់ដូចតាមប្រក្រតី តាមការអនុញ្ញាតរបស់អង្គជំនុំជម្រះ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរតែពាក់ព័ន្ធទៅនឹងសន្តិសុខផ្ទៃក្នុងដែលជាតួនាទីរបស់យោធា។ មុនចូលទៅដល់ចំណុចនេះ ខ្ញុំចង់សួរចំណុចទូទៅ លោកបានបញ្ជាក់ថា ចាប់ពីឆ្នាំ៧៦ លោកត្រូវបានគេតែងតាំងជាអនុប្រធានកងពលធំទី១ ហើយលោកមានកូនទាហាន ៧០០នាក់។ តើលោកអាចជម្រាបបានទេក្នុងចំណោមទាហានទាំងអស់ហ្នឹង តើមានទាហានដែលមានអាយុក្រោម ១៨ឆ្នាំ ដែរឬទេ?

[០៩:៤៧:៤៧]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយ មិនមែនកងពលធំទេ ខ្ញុំកងពលតូចទេ ហើយអាយុក្នុងអាយុទាហានមាន ត្រឹម ១៧ ឡើងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីបញ្ហាសន្តិសុខផ្ទៃក្នុង លោកសហព្រះរាជអាជ្ញាបានសួរលោកអំពីការចាប់ខ្លួនទាហាននៅក្នុងជួរកងទ័ព ហើយបន្ទាប់មកមានការធ្វើបាបទាហានទាំងនេះ។ ខ្ញុំចង់សួរលោកបន្ថែមទៀតអំពីជនស៊ីវិលម្តង នៅពេលដែលលោកជាអនុបញ្ជាការនៅភូមិភាគបស្ចិម ក្នុងឋានៈជាយោធា តើលោកទទួលបញ្ជាឲ្យមានការគ្រប់គ្រងជនស៊ីវិលដែរទេ ពាក់ព័ន្ធទៅនឹងសន្តិសុខផ្ទៃក្នុងនេះ?

[០៩:៤៩:០៩]

**ឆ៖** បាទ ក្នុងភាពសន្តិសុខផ្ទៃក្នុងខាងខ្ញុំអត់មានគ្រប់គ្រងប្រជាជនទេ នៅតាមព្រំដែន មានតែទាហានទាំងអស់ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើខ្ញុំយល់ត្រឹមត្រូវទេថា លោកមិនមានការទទួលបញ្ជាជាក់លាក់ណាមួយឲ្យចាប់ខ្លួនជនស៊ីវិលទេ។ តើអ៊ីចឹងមែនទេលោកសាក្សី?

**ឆ៖** បាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដកស្រង់នូវសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីមួយ ដែលមានលេខ D170/1។ នេះគឺជាដើមបណ្តឹងរដ្ឋប្បវេណី D22/27 កំណត់ហេតុនេះមាននៅជើងនៃដីកាដំណោះស្រាយ ហើយក៏មាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា និងបញ្ជីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំងគឺ 00485416, ភាសាអង់គ្លេស 00338390, ជាភាសាខ្មែរ 00304334-35។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីអាននូវសម្រង់នៃឯកសារមួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:៥១:១០]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** សូមអរគុណ។ សម្រង់នេះគឺជាសម្រង់នៃកំណត់ហេតុដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប ដែលបានឆ្លើយថា "ថ្ងៃមួយនៅពេលយប់ នៅពេលដែលខ្ញុំកំពុងដេកជាមួយប្រពន្ធខ្ញុំ ដែលគេឲ្យទៅរកដំឡូងនៅជុំវិញនោះ មានទាហានមួយដែលមានឈ្មោះ អាត បានមកហៅខ្ញុំ ប្រហែលជានៅម៉ោងប្រាំបួន ឬក៏ម៉ោងដប់យប់ ដែលថាឲ្យខ្ញុំទៅធ្វើម៉ាស៊ីននៅក្នុងស្រែទាំងយប់។ ខ្ញុំគិតថា ប្រហែលមិនមែនគេហៅទៅធ្វើម៉ាស៊ីន ព្រោះតាមធម្មតាខាងស៊ីវិលជាអ្នកមកហៅ មិនមែនទាហានខ្មែរក្រហមជាអ្នកមកហៅអ៊ីចឹងទេ។ ពេលទៅដល់ស្រែ ខ្ញុំឃើញមានទាហានចាំនៅលើថ្នល់ ខ្ញុំដឹងថា គេនឹងចាប់ខ្លួនខ្ញុំ ហើយខ្ញុំបានសុំគេថា ខ្ញុំដឹងថា គេដឹងតែមកចាប់ខ្ញុំហើយ ពីព្រោះថាមានទាហាននៅទីនោះដែរ នៅពេលដែលខ្ញុំឡើងរ៉ឺម៉កនោះ។ ពេលទៅដល់ផ្ទះរបស់មិត្ត ហាក់ ខ្ញុំចុះពីរ៉ឺម៉ក គេចាប់ចងខ្ញុំភ្លាម ហើយយកទៅដាក់ក្នុងរោងមួយ។ គេប្រាប់ខ្ញុំថា សម្រាកសិនទៅ ចាំស្អែកគេនឹងបញ្ជូនខ្ញុំទៅដាក់មន្ទីរឃុំឃាំងទៀត។ ព្រឹកឡើងខ្ញុំចាប់អារម្មណ៍នៅមុខផ្ទះមិត្ត ហាក់ មានសុទ្ធតែប្រមាត់មនុស្ស។

[០៩:៥២:៣៧]

នៅថ្ងៃនោះ គេឲ្យបាយខ្ញុំហូបដែរ ពេលល្ងាចគេបានចងខ្ញុំបណ្ដើរពីវាលរេញ ទៅរហូតដល់គុកកោះខ្យង ស្ថិតនៅក្នុងឃុំស្រែចាម ស្រុកព្រៃនប់ ខេត្តកំពត។ គេចងខ្សែអង្រឹង ហើយបន្លាយខ្សែប្រហែលមួយម៉ែត្រ បណ្ដើរខ្ញុំដូចគោ" សូមបញ្ចប់ការដកស្រង់។

លោកសាក្សី តើមាន -- លោកមាននឹកឃើញទេអំពីស្ថានភាពបែបនេះ ដែលប្រហែលជាទាហានណាមួយអាចបែបនេះប្រាប់លោកនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ចំណុចហ្នឹងបាទ។

**ស៖** សូមអរគុណ។ លោកសាក្សីយោងតាមមុខតំណែងរបស់លោកនោះ តើលោកមានដឹងអំពីបញ្ជាពីថ្នាក់លើទៅឲ្យកូនទាហានក្នុងកសារសួរចម្លើយអ្នកដែលចាប់ខ្លួន ដូចដែលអ្វីដែលខ្ញុំបានអានអម្បាញមិញនេះដែរឬទេ?

**ឆ៖** បាទ អត់ដឹង។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំសូមការអនុញ្ញាតអាននូវសម្រង់មួយទៀត នៃកំណត់ហេតុដដែលនេះ គឺជា

សម្រង់ខ្លីទេ ដែលមានលេខ ERN ជាភាសាបារាំង 00485417, ជាភាសាអង់គ្លេស 00338391, ជាភាសាខ្មែរ 00304335។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអាននូវសម្រង់មួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** សូមអរគុណ។ ខ្ញុំសូមអាននូវសម្រង់នៃដើមបណ្ដឹងរដ្ឋប្បវេណីដដែល ដែលបានរៀបរាប់នៅពេល ដែលក្រោយគេចាប់ខ្លួន ហើយនិងស្ថានភាពនៅក្នុងគុកកោះខ្សង។ "ព្រឹកនោះខ្ញុំជាអ្នកទី៤ដែលត្រូវនាំយកទៅសួរចម្លើយ ហើយនៅក្នុងចំណោមអ្នកមុនខ្ញុំ មានតែម្នាក់ទេ ដែលនៅរស់រានមានជីវិត វិលទៅជាប់ខ្នោះជើងវិញ។ ពេលខ្ញុំនៅមុខទ្វារកន្លែងគេសួរចម្លើយនោះ ខ្ញុំបានឃើញគេអូសខ្មោចអ្នកទោសដែលគេវៃសន្លប់រហូតដល់ងាប់កាត់មុខខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា ខ្នោះដែលជាប់ដំបូងនោះគឺជាខ្នោះឈើ ហើយក្រោយមកទៀតទើបគេដាក់ខ្នោះដែក"។ សំណួររបស់សហចៅក្រមស៊ើបអង្កេត "សូមលោករៀបរាប់អំពីព្រឹត្តិការណ៍ដែលគេវៃសួរចម្លើយលោក"។ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី "ឈ្មោះ ចន ជាមេគុករង។ មេគុក ខ្ញុំមិនចាំឈ្មោះទេ និងមានទាហាននាំខ្ញុំពីរនាក់ ជាអ្នកនៅសួរចម្លើយខ្ញុំ។ ពេលចាប់ផ្ដើមភ្លាម គេឲ្យខ្ញុំឃើញសម្ភារៈសម្រាប់សួរចម្លើយដូចជា ដំបងដែក ដំបងឈើ អាវភ្លៀងកៅស៊ូ ដែលមានលក្ខណៈដូចគ្នាទៅនឹងរូបនៅលើក្របសៀវភៅរបស់ខ្ញុំ"។

លោកសាក្សី តើលោកមាននឹកឃើញអំពីរបាយការណ៍ ឬឃោបល់ណាមួយដែលទាហានបានប្រាប់លោកដែរឬទេ?

[០៩:៥៦:១២]

**ឆ៖** បាទ អត់ដឹងដែរកន្លែងហ្នឹង។

**ស៖** លោកសាក្សី យោងតាមមុខតំណែងឃោធារបស់លោកនៅពេលនោះ តើលោកធ្លាប់ទទួលបញ្ជាពិសេសពាក់ព័ន្ធទៅនឹងអ្នកទោសដែលរត់ចេញពីគុក ឬរត់ចេញពីមន្ទីរសន្តិសុខដែរឬទេ?

**ឆ៖** បាទ អត់មានទេ កន្លែងខ្ញុំអត់មានរត់នៅ ព្រោះកន្លែងឆ្ងាយពីគ្នា ឆ្ងាយណាស់ បាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតសូមអាននូវសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលេខ D22/1328។ ERN ជាភាសាបារាំងគឺ--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកស្រីមេធាវីអានERN ឡើងវិញម្ដងទៀត។ អ្នកបកប្រែតាមអត់ទាន់។

[០៩:៥៧:២៥]

**ប្រធានអង្គជំនុំ៖**

លោកស្រីអានលេខ ERN សាជាថ្មីម្ដងទៀត ព្រោះអ្នកបកប្រែ បកអត់ទាន់ទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអភ័យទោសលោកប្រធាន។ គឺដើមបណ្ដឹងរដ្ឋប្បវេណី D22/1328, ERN ជាភាសាបារាំង 00850561, ERN ជាភាសាខ្មែរ 00525741 ទៅដល់ 42។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអាននូវសម្រង់នៃឯកសារមួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដូចកាលពីមុនដែរ គឺជាដើមបណ្ដឹងរដ្ឋប្បវេណីដែលរស់នៅក្នុងតំបន់ដែលលោកកាន់ជាយោធា។ ដើមបណ្ដឹងរដ្ឋប្បវេណីនោះបានឆ្លើយថា ១០ថ្ងៃក្រោយមក គាត់បានរត់គេចខ្លួន ហើយគាត់បានរៀបរាប់ថា “១០ថ្ងៃក្រោយមក” -- សូមភ័យទោស គាត់អត់បាន -- ទាន់បានរត់ទេ។ គាត់បានរៀបរាប់ថា “១០ ថ្ងៃក្រោយមក ទាហានប្ដូរកន្លែងឃុំខ្លួនទៅកន្លែងកែប្រែ។ កន្លែងនោះនៅពេលយប់ដាក់ខ្នោះជើង។ នៅពេលថ្ងៃ ពួកគេឲ្យធ្វើការដូចជាកាប់គាស់ដាំដំឡូង។ ជារៀងរាល់ថ្ងៃយប់ ទាហានបាននាំយកប្រជាជនថ្មី ឬអ្នកដែលពួកវាចោទថាក្បត់នឹងអង្គការយកទៅសម្លាប់ចោល និងកប់នៅក្បែរគុកនោះ។ នៅពេលថ្ងៃ ពួកទាហានក្នុងគុកនោះ បានបញ្ជាឲ្យអ្នកទោសកាប់រណ្ដៅក្បែរគល់ស្វាយ និងក្បែរគល់ដូង។ ខ្ញុំធ្លាប់ត្រូវបានទាហានប្រើឲ្យកាប់រណ្ដៅបានពីររណ្ដៅ” សូមបញ្ចប់ឃ្លាដំបូង។

[០៩:៥៩:៣៨]

ហើយបន្ទាប់មកទៀត ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយទៀតថា “ថ្ងៃមួយនៅក្នុងឆ្នាំ៧៨នៅរដូវប្រាំង អ្នកទោសមួយឈ្មោះ ចន បានរត់ចេញពីគុក។ ៧ថ្ងៃក្រោយមក ទាហានខ្មែរក្រហម ចាប់គាត់បានវិញ។ ហើយគេដាក់ឲ្យ គេប្រមូលអ្នកទោសទៅចម្ការចេកនៅទល់មុខគុក។ បន្ទាប់មកទៀត ទាហានម្នាក់មិនស្គាល់ឈ្មោះ និយាយថាកុំឲ្យយកតម្រាប់តាម មិត្តឈន។ បន្ទាប់មក ពួកគេយកត្បូង

ចប វាយសម្លាប់តែម្តង រួចធាក់ទម្លាក់ចូលទៅក្នុងរណ្តៅ។ ១ខែក្រោយមក អ្នកទោសពីរនាក់ផ្សេងទៀត រត់ ហើយទាហានចាប់បាន ហើយអ្នកទោស អ៎! សូមទោស ទាហាននេះ ក៏បានហៅអ្នកទោស ទាំងអស់មកមើល រួចពួកវាឲ្យអ្នកទោសរត់ទាំងពីរនាក់ កាប់រណ្តៅមួយ យកបង្គោលមកបោះ បន្ទាប់មកចាប់អ្នកទោសទាំងពីរនាក់ចងឆ្កាង។ មេកងវរៈឈ្មោះ ឡួន បានបញ្ជាឲ្យខ្ញុំ និងអ្នកទោសម្នាក់ ទៀត ឈ្មោះ ធី យកកាំបិតម្នាក់មួយ ទៅវះពោះពួកអ្នកទោសរត់ ម្នាក់មួយ។ ពេលនោះ ដោយខ្ញុំមិន ហ៊ានប្រកែក ខ្ញុំក៏ទៅយកកាំបិតវះតែម្តង"។

**ស៖** លោកសាក្សី តើមានលោក -- លោកធ្លាប់ចាំថា មានកូនទាហានណាមួយដែលបានធ្លាប់ លោកអំពីហេតុការណ៍បែបនេះទេ?

[១០:០១:០៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមជំទាស់ចំពោះសំណួរដែលតាំងឡើងដោយមេធាវី ដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះសាក្សី ដែលហៅថា សាក្សីរូបនេះ គាត់បានទៅកាន់តំបន់ព្រះវិហារ នោះ គឺតាំងពី គឺក្រោយខែ៨ ឆ្នាំ៧៨ ១៩៧៨ ហើយអង្គហេតុដែលបានបង្ហាញនៅក្នុងកំណត់អះអាងនេះ គឺនៅខែប្រាំង ឆ្នាំ១៩៧៨។ ខែប្រាំង យើងអត់ច្បាស់លាស់ថា ជាខែណាទេ ក៏ប៉ុន្តែតាមរដូវនៅស្រុកខ្មែរ ខែប្រាំង គឺមានតែខែ០១ ខែ០២ យ៉ាងខ្លាំងណាស់ ដល់ខែ៣ ឬក៏ខែ៤ យូរបំផុត។

អ៊ីចឹង បានន័យថា វាមុនពេលដែលសាក្សីទៅកាន់តំបន់ព្រះវិហារហើយ ដូច្នេះសាក្សីមិនអាច ផ្តល់សក្ខីកម្មចំពោះបញ្ហានេះបានទេ។ បាទ សូមអរគុណ។

[១០:០២:១០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន តើខ្ញុំអនុញ្ញាតឲ្យខ្ញុំឆ្លើយតបទេ?

សំណួរនេះ គឺជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ផ្សេងទៀត ខ្ញុំមិនសួរថា ឲ្យគាត់ ស្គាល់ឧទាហរណ៍ជាក់លាក់នេះទេ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើគាត់ធ្លាប់ស្តាប់ឮការនិយាយអំពីការរត់គេច

ខ្លួនរបស់អ្នកទោស ហើយនិងមានការចាប់អ្នកដែលព្យាយាមរត់គេចមកវិញ ដោយទាហានខ្មែរក្រហម នោះ ហើយនិងធ្លាប់ឮគេនិយាយអំពីជោគវាសនា ហើយនិងអ្នកដែលរត់គេចនេះដែរឬទេ។ គឺថា វាមិនមែនពាក់ព័ន្ធជាពេលវេលាជាក់លាក់ណាមួយទេ ខ្ញុំគ្រាន់ចង់ដឹងថា តើគាត់ធ្លាប់ឮរឿងបែបនេះ ដែរឬទេ។

[១០:០២:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនសមស្រប។ សាក្សីឆ្លើយតបទៅនឹង សំណួរចុងក្រោយ ដែលសួរឡើងដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញ នេះ។

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ពីព្រោះកន្លែងនុំងជាកន្លែងរបស់លេខាកងពល គាត់ចាំនៅកន្លែង នោះ។ ហើយចេញពីកន្លែងកងពលទៅ កន្លែងខ្ញុំ គឺឆ្ងាយ។ ខ្ញុំមិនបានដឹងដំណឹងអ្វីពីកន្លែងគាត់ ពីកន្លែង នោះទេ បាទ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកសាក្សី នៅពេលដែលលោកកាន់តំណែងនៅកោះកុង តើគេធ្លាប់បញ្ជាលោកឲ្យគ្រប់ គ្រងកងចល័តដែរឬទេ?

**ឆ៖** កន្លែងកោះកុង គ្មានកន្លែងចល័តទេ ហើយគ្មានកន្លែងជីកប្រឡាយ ជីកប្រព័ន្ធទេ។ ហើយ កន្លែងនោះ ក៏គ្មានបីគោន បួនគោនដែរ។ ដូច្នេះ ជាកន្លែងយោធាទាំងអស់ បាទ។

[១០:០៤:៣៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអាននូវសម្រង់នៃកំណត់ហេតុស្ដាប់ចម្លើយ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត។ កំណត់ហេតុនេះ មាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា និង បញ្ជីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលេខ D125/86។ ខ្ញុំសូមអាននូវឃ្លាមួយដែលមានលេខ ERN ជាភាសាបារាំង 00243025, ជាភាសាអង់គ្លេស 00243011, ជាភាសាខ្មែរ 00206389។ ខ្ញុំសូមការ អនុញ្ញាតពីលោកប្រធានដើម្បីអាននូវសម្រង់នៃកំណត់ហេតុមួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំសូមបញ្ជាក់ថា ដើម្បីបណ្ដឹងរដ្ឋប្បវេណីនេះមានលេខ D22/92 គាត់មានអាយុ២០ឆ្នាំ នៅឆ្នាំ៧៥ ហើយគាត់ធ្វើការនៅក្នុងកងចល័តនៃតំបន់ -- នៅភូមិភាគបស្ចិម សូមទោស។ គាត់និយាយថា "ជាទូទៅការងារដែលខ្ញុំធ្វើចម្ការនេះ គឺខ្ញុំត្រូវទៅប្រជុំរាយការណ៍ជាមួយកងវរសេនាធំ និងជាមួយទ័ពក្នុងតំបន់៣៧ រៀងរាល់ខែ។ កាលណោះកន្លែងដែលខ្ញុំធ្វើការហ្នឹង ហៅថា "តំបន់៣៧" ដោយសារខ្ញុំឈឺនោះ ខ្ញុំបានផ្ញើរបាយការណ៍តាមកុមារយោធាដែលគេតែងតែមកហៅប្រជុំនោះ"។ ទៅខាងមុខទៀត ដើមបណ្ដឹងរដ្ឋប្បវេណីនេះឆ្លើយទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេតថា "តើគេចាប់ខ្លួនលោកយ៉ាងម៉េច" គាត់ឆ្លើយថា "ប្រហែលជាម៉ោងប្រាំមួយល្ងាច នៅពេលដែលចាប់ខ្ញុំ នោះកុមារយោធាដែលតែងតែហៅទៅប្រជុំនោះបានមកប្រាប់ថា បងវឿន ហៅឲ្យទៅជួបគាត់មួយភ្លែត ពេលនោះ ហើយពេលដែលមកហៅនោះ ជាពេលព្រលប់ហើយ។ ក្រោយពីប្រាប់រួច ខ្ញុំក៏ដើរតាមកុមារយោធានោះ ពេលទៅដល់កន្លែងចាប់ខ្លួននោះ កុមារបានប្រាប់ខ្ញុំថា បងឯងចាំខ្ញុំនៅទីហ្នឹងហើយ ខ្ញុំទៅហៅ បងវឿន មួយភ្លែត។ ឈ្មោះ វឿន នោះជាអ្នកគ្រប់គ្រងកងចល័តក្នុងតំបន់៣៧ទាំងមូល។ បើនិយាយឋានៈរបស់ វឿន សម័យនោះគឺគេថា ជាប្រធានកងពល។ បន្ទាប់ពីកុមារនោះដើរចេញបានមួយភ្លែត ស្រាប់តែមានទ័ពពីរនាក់ប្រដាប់ដោយអាវុធ អាកាពីរដើម ភ្ជង់ឲ្យខ្ញុំលើកដៃ រួចហើយក៏យកក្រមាដែលស្លៀក --ដែលខ្ញុំស្លៀកពីលើខោ មកចងដៃខ្ញុំទៅក្រោយ" សូមបញ្ចប់ការដកស្រង់។

លោកសាក្សីតើអ្វីដែលខ្ញុំអានលោកនេះ លោកមានធ្លាប់ឮទេ ពីសម័យនោះគេរៀបរាប់ លោកពីហេតុការណ៍អ្វីដែលស្រដៀងគ្នាហ្នឹងហេតុការណ៍ដូចដែលខ្ញុំប្រាប់លោកនេះទេ?

[១០:០៧:៣៤]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់ដែរមកនៅខាងក្រោយផង ខ្ញុំនៅតែខាងមុខរហូត។ ដូច្នេះ ខ្ញុំមិនដឹងទេក្នុងរឿងហ្នឹង នោះ។

**ស៖** លោកសាក្សី យោងតាមមុខតំណែងយោធារបស់លោកនៅក្នុងភូមិភាគបស្ចិម និងជាពិសេស នៅកោះកុង តើលោកធ្លាប់ទទួលបញ្ជាពីថ្នាក់លើដើម្បីបញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខមួយ ដូចជាមន្ទីរសន្តិសុខកោះខ្យងជាដើម ទៅកាន់សហករណ៍នៅជុំវិញខេត្តកោះកុងដើម្បីឱ្យអ្នកទោសទាំងអស់នោះ ទៅធ្វើការនៅក្នុងសហករណ៍។ តើធ្លាប់មានការទទួលបញ្ជាបែបហ្នឹងទេលោកសាក្សី?

**ឆ៖** គ្មានទេ ខ្ញុំអត់ដឹងដែរ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអាននូវសម្រង់ចុងក្រោយមួយទៀត របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/772។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំង គឺ 00850348, ជាភាសាខ្មែរ 00502123។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីអាននូវសម្រង់មួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:០៩:៣១]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** សូមអរគុណលោកប្រធាន។ នេះគឺដើមបណ្តឹងរដ្ឋប្បវេណីដែលធ្លាប់បានជាប់គុកនៅក្នុងភូមិភាគបស្ចិម នៅក្នុងមន្ទីរសន្តិសុខ។ គាត់បានឆ្លើយថា "១៥ថ្ងៃក្រោយមក ប្រធានគុកដែលខ្ញុំអត់ស្គាល់ឈ្មោះ បានឱ្យខ្ញុំចេញទៅធ្វើការនៅក្រៅ ដោយឱ្យខ្ញុំគាស់ដីព្រៃដាំដំឡូង លើកភ្លឺស្រែ ដាំស្រូវជាដើម។ លុះដល់ខែឧសភា ឆ្នាំ១៩៧៧ ពួកទាហានបានយកឡានដឹកខ្ញុំ និងគ្រួសារ និងជាង១០០គ្រួសារទៀតទៅភូមិបាក់រនាស់ ឃុំចំប៉ា ស្រុកកំពង់សិលា ខេត្តកោះកុង។ ពេលទៅដល់ ពួកទាហានបានឱ្យមេកង១០នាក់ សម្រាប់គ្រប់គ្រងក្រុមគ្រួសារអ្នកទោសជាងមួយរយគ្រួសារ"។ លោកសាក្សី តើលោកធ្លាប់ឮគេនិយាយអំពីរឿងហេតុដែលស្រដៀងគ្នាបែបនេះទេ?

**ឆ៖** ខ្ញុំអត់បានឮទេ។

**ស៖** ទាហានដែលជាអ្នកចាប់អ្នកទោស ហើយនិងគ្រប់គ្រងអ្នកទោសនៅមន្ទីរសន្តិសុខ ហើយនិងគ្រប់គ្រងការចាប់ខ្លួននៅពេលដែលមានអ្នកទោសរត់ មានការសម្លាប់ ហើយនិងមានការបញ្ជូនទៅកាន់មន្ទីរសន្តិសុខមួយទៀតនោះ អ៊ីចឹងតើអ្នកណាជាអ្នកធ្វើរបាយការណ៍ បើសិនជាមិនមែនលោកនោះទេបើលោកមិនដឹង? អ៊ីចឹងទាហានទាំងអស់នេះ គាត់ធ្វើរបាយការណ៍ទៅណានៅពេលដែលគាត់ធ្វើ

សកម្មភាពទាំងអស់នេះហើយនោះ?

[១០:១១:១៩]

**ឆៈ** បាទ ទាហានខាងខ្ញុំអត់មានមកគ្រប់គ្រងសន្តិសុខខាងក្រោយ ឬក៏តាមខេត្តខាងក្រោយទេ។ ទាហានខាងខ្ញុំនៅតែខាងមុខជាប់រហូត អត់មានងាកមកក្រោយទេបាទ។

**សៈ** លោកសាក្សី ខ្ញុំមានសំណួរចុងក្រោយមួយទៀត ហើយសំណួរនេះគឺពាក់ព័ន្ធនឹងលោកជាពិសេសតែម្តង។ លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាកាលពីសប្តាហ៍មុននេះថា លោកខ្លួនឯងផ្ទាល់នោះ ក៏លោកខ្លាចសុវត្ថិភាពខ្លួនឯងផ្ទាល់ដែរ។ ហើយលោកមិនហ៊ានប្រឆាំងទេ។ ដូច្នេះគឺថា លោកបើកឲ្យមានការចាប់ខ្លួន។ លោកឆ្លើយបែបហ្នឹងជាមួយសហព្រះរាជអាជ្ញា។ លោកសាក្សី បើយោងទៅតាមឋានៈរបស់លោកដែលខ្ពស់ដែរនោះ តើលោកខ្លាចអ្វីដែរចំពោះសន្តិសុខផ្ទាល់ខ្លួនលោកនោះ?

**ឆៈ** បាទ ខ្ញុំខ្លាចហ្នឹង ត្បិតព្រោះខ្ញុំមិនហ៊ានតបតវាងថ្នាក់ដឹកនាំខាងលើ ខ្ញុំខ្លាចខុស។ ខ្ញុំគិតការងាររបស់គាត់ដែរបាទ។

**សៈ** តើលោកខ្លាចហ្នឹង តើលោកខ្លាចអ្វីឲ្យប្រាកដទៅ?

**ឆៈ** បាទ ខ្លាចគេចាប់ខ្ញុំដែរ ព្រោះខ្ញុំគេចាប់បងខ្ញុំ អ៊ុំនៃ បងថ្លៃខ្ញុំ ខ្ញុំញញើតដែរ។ ហើយទោះបីយ៉ាងណា ក៏ខ្ញុំខ្លាចអ្នកដឹកនាំខាងលើខ្ញុំប្រាប់ធ្វើយ៉ាងម៉េច ខ្ញុំដូចថា ពិសេសខ្ញុំការពារមកខាងមុខ គិតតែខាងមុខ ហើយខាងក្រោយខ្ញុំអត់មកជ្រៀតជ្រែកកិច្ចការងារគេខាងក្រោយទេ។ សំខាន់គឺថា ខាងមុខរៀបចំ គិតតែខាងមុខ។ ខាងក្រោយ អត់មានមកទាក់ទងអ្វីដែលពីរឿងកិច្ចការងារក្របខ័ណ្ឌរបស់ខ្លួនឯងទេ។ អាហ្នឹងយើងឃើញគាត់ប្រាប់អ៊ីចឹងឯងបាទ។

[១០:១៣:៥៩]

**សៈ** អ៊ីចឹងសូមអនុញ្ញាតឲ្យខ្ញុំសួរសំណួរចុងក្រោយមួយទៀត ដែលពាក់ព័ន្ធទៅនឹងសំណួរមុននេះ។ តើមានអ្វីកើតឡើងចំពោះសមាជិកគ្រួសារលោកដែលថាគេចាប់ខ្លួននោះ លោកនិយាយអម្បាញ់មិញនេះ?

**ឆៈ** អាហ្នឹងដូចថា បងប្អូនខ្ញុំគេចាប់ទៅ ខ្ញុំខ្លាចនិន្នាការអ្វីដែលវាទាក់ទង ខ្ញុំខ្លាចគេចាប់ខ្ញុំទៀត ខ្ញុំខ្លាចគេសម្លាប់ខ្ញុំដែរ។ អ៊ីចឹងខ្ញុំកិច្ចការងារទាំងអស់ហ្នឹង ខ្ញុំដឹងតែខាងមុខទេ ខាងក្រោយខ្ញុំអត់បានដឹងទេ បាទ។

**សៈ** លោកអត់ឆ្លើយនឹងសំណួរខ្ញុំទេ ថាតើមានហេតុការណ៍អ្វីកើតឡើងចំពោះពួកគាត់?

**ឆ៖** ខ្ញុំស្តាប់មិនបានថា ពួកគាត់ណា ខ្ញុំមិនដឹងថា ពួកគាត់អ្នកណាទេ ខ្ញុំស្តាប់អត់បានសំណួរហ្នឹង។

**ស៖** គឺខ្ញុំសំដៅទៅដល់សមាជិកគ្រួសារ ហើយនិងសាច់ថ្លៃរបស់លោក ដែលគេចាប់ខ្លួននោះ ក្រោយពីការចាប់ខ្លួនហើយ តើគេធ្វើអ្វីទៀតចំពោះពួកគាត់?

**ឆ៖** បាទ បងថ្លៃខ្ញុំគឺថា ខុសសីលធម៌ ហើយប្អូនខ្ញុំគេចោទដូចគ្នាដែរ ហើយគេយកបងថ្លៃខ្ញុំដាក់គុកទៅ ហើយស្លាប់ទៅខ្ញុំ រឿងអ្វីខ្ញុំមិនបានតបតទេ ខ្ញុំខ្លាចទាក់ទិនដល់ជីវិតខ្ញុំដែរ បាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកសាក្សី។ ជាពិសេស ខ្ញុំសូមអរគុណដែលលោកបានឆ្លើយទៅនឹងសំណួរលំបាកៗមួយចំនួនរបស់ខ្ញុំ។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១០:១៦:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អស់លោក លោកស្រីចៅក្រមមានសំណួរអីសួរ។ បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

[១០:១៦:៣២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោក មាស វឿន ខ្ញុំជាចៅក្រម ឡាវែន៍ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរលោក ប៉ុន្តែមុននឹងសួរសំណួរលោក ខ្ញុំមានឯកសារមួយសម្រាប់ចែកជូន ទាំងជូនសាក្សី និងភាគីទាំងអស់។ នេះគឺជាផែនទីពណ៌ធម្មតានៃរបបកម្ពុជាប្រជាធិបតេយ្យ។ ផែនទីនេះ គឺសម្រាប់ធ្វើឲ្យយើងមានគំនិតអំពីអ្វីដែលយើងនឹងនិយាយនៅពេលដែលពិភាក្សាអំពីភូមិភាគ តំបន់ ឬក៏ស្រុកនោះ។ លោក មាស វឿន លោកបានឆ្លើយសំណួរយ៉ាងច្រើន ហើយលោកក៏បានពន្យល់ថា លោកបានចូលបដិវត្តន៍នៅពេលដែលលោកនៅក្មេង ពេលនោះ គឺលោកចូលទៅក្នុងសម្ព័ន្ធយុវជន លោកទទួលបានការបណ្តុះបណ្តាលពី តាម៉ុក ហើយកាលពីព្រឹកមិញនេះ ក៏គេបានសួរលោកដែរពីរឿងនេះ។

[១០:១៧:៥៦]

ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីរចនាសម្ព័ន្ធយោធាម្តង ខ្ញុំចង់ឲ្យលោកពន្យល់ខ្ញុំឲ្យបានច្បាស់ថា តើស្ថានភាពមុនពេលវាយយកទៅក្រុងភ្នំពេញបាននោះយ៉ាងម៉េចដែរ? ពីព្រោះថាពេលនោះគឺលោកជាអ្នកដឹកនាំនូវកងវរសេនាធំ នៃកងពលលេខ១ ហើយខ្ញុំដឹងថា កងពលលេខ១ នេះស្ថិតនៅក្រោមបង្គាប់របស់ភូមិភាគបស្ចិម សូមទោស! គឺភូមិភាគនិរតី។ លោក មាស វឿន តើខ្ញុំរៀបរាប់នេះត្រឹមត្រូវទេ គឺថាស្ថានភាពនៅសម័យមុនឆ្នាំ៧៥ នោះ គឺពួកកងពលធំលេខមួយនោះ គឺថាស្ថិតនៅក្រោមបង្គាប់របស់លេខានៃ សូមទោស! លេខាភូមិភាគនិរតី?

**លោក មាស វឿន៖**

**ឆ៖** បាទ រៀបរាប់ត្រូវហើយ។

**ស៖** លេខាតំបន់និរតី គឺតាម៉ុក តើមានលេខា -- អនុលេខានោះអ្នកណាខ្លះដែរ លោកសាក្សី?

**ឆ៖** បាទ តំបន់និរតីពីមុនដំបូង គឺមាន តាម៉ុក បន្តពី តាម៉ុកមក តាស៊ី។ ហ្នឹងដែលពីដើមខ្ញុំដឹងថាមានតែពីរហ្នឹងទេ។

[១០:២០:០០]

**ស៖** លេខាភូមិភាគគឺតែងតែមានអនុលេខា គឺគាត់មិនមែនដឹកនាំគណៈភូមិភាគតែម្នាក់ឯងទេ។ តើមានអ្នកណាទៀតដែលជាសមាជិកនៃគណៈភូមិភាគនោះ?

**ឆ៖** បាទ ខ្ញុំអត់ចាំបាន ខ្ញុំចាំបានតែ តាម៉ុក ហើយនិង តាស៊ី តែពីរនាក់ហ្នឹង ហើយ តាម៉ុកហ្នឹងគាត់ធ្វើលេខាតំបន់ នៃ ដូចអត់មានលេខាទេកាលណោះ គឺចាត់តាំងតែគាត់ មិនដឹងគាត់ទទួលខាងអីទៀត ខ្ញុំដឹងតែពីរនាក់ហ្នឹង។ ស្គាល់តែពីរនាក់។

**ស៖** តើមានកងពលអ្វីខ្លះទៀត ដែលស្ថិតនៅក្រោមបង្គាប់របស់ភូមិភាគនិរតី តើភូមិភាគនិរតីគ្រប់គ្រងកងពលធំប៉ុន្មាននៅចន្លោះឆ្នាំ៧៥ មុនពេលវាយបែកទីក្រុងភ្នំពេញនោះ?

**ឆ៖** បាទ មានកងពលតែមួយ ភូមិភាគនិរតីតែមួយហ្នឹង។

**ស៖** លោកមិនដែលធ្លាប់ឮកងពល២ ដែលស្ថិតនៅក្រោមបង្គាប់របស់ សំ ប៊ិត ទេឬ?

**ឆ៖** បាទ ឮឈ្មោះដែរ តែអត់ដឹងថាគាត់ទទួលខាងអីផង ខ្ញុំស្គាល់តែពីរនាក់ហ្នឹងឯង។

[១០:២១:១៣]

**ស៖** តើលោកស្តាប់ឮអ្វីខ្លះអំពីកងពលលេខ២ ឬក៏ពីឈ្មោះ សំ ប៊ិត នេះ?

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះ ក៏ប៉ុន្តែមិនដែលឃើញមុខគាត់ផង គ្រាន់តែឈ្មោះ តាប៊ិត១ ហ្នឹង ឮតែឈ្មោះបាទ។ ប៉ុន្តែគាត់មិនដឹងថា នៅក្នុងភាគ ឬក៏នៅក្នុងកងពល ខ្ញុំមិនបានដឹងកិច្ចការងារ ឬភារកិច្ចរបស់គាត់ដែរ។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីកងពលលេខ៣ ហើយនិងឈ្មោះ មាស មុត ដែរឬទេ?

**ឆ៖** បាទ ឮ មាស មុត ឮ។

**ស៖** កងពលលេខ៣ ស្ថិតនៅក្រោមឱវាទរបស់អ្នកនៅឆ្នាំ៧៥ នោះ?

**ឆ៖** បាទ ស្ថិតនៅ១ មាស មុត នោះឯងតាមមើល។

**ស៖** ចុះ មាស មុត គាត់ត្រូវរាយការណ៍ជូនអ្នកណាដែរ? អ្នកណាជាមេរបស់ មាស មុត?

**ឆ៖** ខ្ញុំមិនដឹងដែរ កាលខាងគេខាងហ្នឹង មិនសូវមានការទំនាក់ទំនងគ្នាដែរ។

[១០:២៤:២៧]

**ស៖** នៅពេលវាយយកទីក្រុងភ្នំពេញ តើលោកមានស្តាប់ឮគេនិយាយអំពីកងពលលេខ៣ ហើយឬក៏ មាស មុត នេះទេ?

**ឆ៖** បាទ ឮ កងពលលេខ៣ ឮ។

**ស៖** ហើយនៅពេលវាយយកទីក្រុងភ្នំពេញនេះ តើកងពលហ្នឹងនៅឯណាដែរ កងពលលេខ៣ នេះ?

**ឆ៖** បាទ មិនដឹងជានៅខាងណា ខ្ញុំមិនបានដឹងអាមុខសញ្ញារបស់គាត់។ ដឹងតែខ្ញុំនៅខាងជើង ប៉ុន្តែខាងកងពលលេខ៣ ខ្ញុំមិនដឹងថា មុខសញ្ញាគាត់នៅខាងណា ខ្ញុំអត់បានដឹង។

**ស៖** ឥឡូវនេះ យើងត្រឡប់មកនិយាយអំពីកងពលលេខ១ នៅពេលវាយយកទីក្រុងភ្នំពេញ។ កងពលលេខ១ តើមានអ្នកណាខ្លះជាលេខា លេខារង ហើយមានគណៈ -- មានស្នងការនយោបាយទេ កងពលលេខ១ ហ្នឹង?

**ឆ៖** បាទ ស្នងការនយោបាយមានតែ តាសឿង គាត់ តែស្នងការនយោបាយតែគាត់។ ហើយនិងម្នាក់ទៀត ខ្ញុំមិនចាំឈ្មោះ អាហ្នឹងបែបជំនួស តាសឿង ដែរ ក៏ប៉ុន្តែខ្ញុំមិនចាំឈ្មោះពេលនោះ។ ខ្ញុំភ្លេចឈ្មោះទៅ។

[១០:២៦:៣៧]

**ស៖** អ្នកដែលជាប្រធានកងពល តើគាត់មានងារជាស្នងការនយោបាយ ឬក៏ជាមេបញ្ជា ឬក៏

មានមុខងារអីផ្សេងទៀត? តើគេហៅប្រធានកងពលហ្នឹងយ៉ាងម៉េចដែរនៅសម័យនុ៎ង?

**ឆ៖** បាទ នែ៎ គេមានប្រធាន មានលេខាកងពល មានបញ្ជាការកងពល មានអនុបញ្ជាការ។ ក៏ប៉ុន្តែគាត់ តាសឿង គាត់ទទួលប្រធានបញ្ជាផង ហើយគាត់មានម្នាក់ទៀត ប៉ុន្តែខ្ញុំមិនចាំឈ្មោះ ខ្ញុំភ្លេច។ ហើយក្រោយមក -- ក្រោមមក អនុមួយទៀត គាត់ស្លាប់ហើយតាមមើលនោះ។ ឈ្មោះ យន នោះ គាត់ស្លាប់។ ដឹងថាគាត់ស្លាប់កាលដែលឆ្នាំ៧៦ បាទ។ ខ្ញុំភ្លេចឈ្មោះបាត់។

**ស៖** ចុះឈ្មោះមេបញ្ជាការ និងមេបញ្ជាការរង តើលោកដឹងឈ្មោះពួកគាត់ទេ លោកនៅចាំទេ?

**ឆ៖** មេបញ្ជាការ គឺ តាសឿង ហ្នឹងឯង គាត់ ជួនកាលគាត់ម្នាក់ឯង ជួនកាលគាត់ឲ្យគេជំនួសគាត់។ ម្នាក់ទៀត និងគាត់ជួនគាត់ឲ្យវរសេនាធំណាមួយដែលជំនួសគាត់បាន។ គាត់ឲ្យជំនួសមុខគាត់មួយភ្លែត ប៉ុន្តែគាត់ដើរតួទាំងអស់ក្នុងពេលដែលប្រយុទ្ធ ក្នុងសមរភូមិហ្នឹងបាទ។

[១០:២៨:៤៥]

**ស៖** សូមអរគុណ។ តើលោកអាចប្រាប់បានទេ តើមានកងពលធំប៉ុន្មានដែរនៅក្នុង -- សូមទោស! កងពលវរសេនាធំប៉ុន្មានដែរនៅក្នុងកងពលធំលេខ១នេះ? ហើយកងវរសេនាធំនេះមានឈ្មោះអ្វីខ្លះ?

**ឆ៖** បាទ ក្នុងពលធំ មិនមែនកងពលធំទេ។ ក្នុងកងពលតូច មានបីវរសេនាធំ មានវរសេនាធំ១៦, មានវរសេនាធំ១៥, មានវរសេនាធំ១៧។ មានបីវរសេនាធំ ហើយមានវរសេនាតូចពិសេសរបស់កងពលមួយទៀត។ មិនដឹងលេខប៉ុន្មានទេ ខ្ញុំភ្លេចលេខវរសេនាតូច កងពិសេសរបស់កងពលមួយទៀត ខ្ញុំភ្លេចលេខ។

**ស៖** ចុះមុខងាររបស់វរសេនាតូចពិសេស តើទទួលខុសត្រូវខាងអ្វីដែរ?

**ឆ៖** បាទ វរសេនាពិសេសរបស់កងពលហ្នឹង មានភារកិច្ចស៊ើបការណ៍ មុខ សមរភូមិមុខ យកស៊ើបកន្លែងការណ៍ពីខ្មាំង។

**ស៖** លោកផ្ទាល់ តើលោកជាប្រធានកងវរសេនាធំណាដែរ?

**ឆ៖** បាទ ខ្ញុំនៅវរសេនាធំ១៦ វរសេនាធំលេខ១៦។

[១០:៣១:១៦]

**ស៖** តើនៅក្នុងកងពលធំ ហើយនៅក្នុងវរសេនាធំហ្នឹង មានកូនទាហានប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ក្នុងមួយវរសេនាធំហ្នឹង មានបីវរសេនាតូច។ ក្នុងវរសេនាតូច យ៉ាងតិចបំផុត៦០០

នាក់។ ចុះមកនៅត្រឹម ៣០០នាក់។

**ស៖** ៣០០នាក់ ក្នុងមួយកងវរសេនាតូច ឬក៏ក្នុងមួយកងវរសេនាធំ?

**ឆ៖** ក្នុងមួយវរសេនាធំហ្នឹងមានបីវរសេនាតូច។ ក្នុងមួយវរសេនាតូច មានពី៣០០ ទៅ៤០០ នាក់ ដោយសភាពការណ៍ដែលវាកំពុងវ៉ៃញ៉ែកអីចឹងទៅ មានការថែមថយៗទៅ មានស្លាប់ មានរបួសអីចឹងទៅ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ អរគុណសាក្សី។ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាប២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់ទាំងពីររូប មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក មាស វឿន លោកទើបតែនិយាយប្រាប់យើងអម្បាញ់មិញថា មានទាហានប្រហែលជា៣០០ ទៅ៤០០នាក់ ក្នុងមួយវរសេនាតូច ហើយមានបីវរសេនាតូចក្នុងមួយកងវរសេនាធំ ហើយនិងមានបីកងវរសេនាធំ នៅក្នុងកងពលតូចឬក៏កងពលធំ។ ដូច្នេះ ចំនួនកងកម្លាំងសរុប ក្នុងកងពលមួយនោះគឺថាវាមានចំនួនប្រហែលប៉ុន្មានដែរ? បើតាមលោកដឹងនោះគឺថា ចំនួនទាហានសរុបក្នុងមួយកងពលធំហ្នឹងមានប្រហែលប៉ុន្មាន?

**លោក មាស វឿន៖**

**ឆ៖** បាទ បើគិតនៅក្នុងចំនួនរចនាសម្ព័ន្ធក្នុងពេលសមរភូមិនោះ វាមិនទៀងទេ។ ជួនកាលមានមួយវរៈ អ៎! មួយអនុសេនា -- មួយអនុសេនាតូចវាមានបីអនុសេនាធំ ប្រហែលជា៣០០នាក់ ក្នុងមួយវរសេនាតូច ហើយបីគុណឲ្យនឹងមួយវរសេនាធំបីទៀត គិតទៅវាប្រហែលជា ២.៧០០ គុណឲ្យទាំងបីវរសេនាធំនេះ ហើយនិងបូកជាមួយនឹងកងពិសេស បើខ្ញុំប៉ាន់ទៅប្រហែលជា ៧.០០០នាក់ គុណជាមួយនឹងកងពលពិសេសរបស់កងពលផងបាទ។

[១០:៥៦:២៣]

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមមិននិយាយអំពីស្ថានភាពនៃរចនាសម្ព័ន្ធកងទ័ពនៅកម្ពុជាប្រជាធិបតេយ្យបន្ទាប់ពីឆ្នាំ១៩៧៥ បានន័យថាចាប់ពីពេលរំដោះភ្នំពេញហើយ។ បើតាមលោកតើរចនាសម្ព័ន្ធនេះមានការប្រែប្រួលដែរឬទេ? តើលោកដឹងដែរឬទេ ថាមានកងពលមួយចំនួនដែលស្ថិតនៅក្រោមឱវាតភូមិភាគ ឬក៏កងពលទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រងនៃអង្គភាពរបស់បក្សផ្ទាល់តែម្តង។ តើមានការប្រែប្រួលនៃរចនាសម្ព័ន្ធយោធាដែរឬទេនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ កងទ័ពទាំងអស់ហ្នឹង គឺនៅក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១០:៥៧:៣៥]

**ស៖** បាទ ខ្ញុំយល់លោកសាក្សី គឺថាយើងទាំងអស់គ្នានៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍គឺថាខ្សែបញ្ជា គឺថារបៀបអនុវត្តអំណាចពីដើមមកនោះ គឺថាកងពលទាំងអស់នោះ សុទ្ធតែនៅក្រោមឱវាតនៃលេខាភូមិភាគ នៅក្នុងភូមិភាគបស្ចិមកងពលទាំងអស់នៅក្រោមអំណាចរបស់ តាម៉ុក។ បន្ទាប់មកទៀត ថាតើមានការប្រែប្រួលដែលថា កងពលមួយចំនួននោះត្រូវស្ថិតនៅក្រោមឱវាតនៃអង្គភាពនៃគណៈមជ្ឈិម ឬក៏អង្គភាពផ្សេងទៀតរបស់បក្ស។

**ឆ៖** កាលណោះខ្ញុំមិនបានដឹងកិច្ចការរបស់មជ្ឈិមទាំងអស់ទេ ខ្ញុំដឹងតែកិច្ចការរបស់ភូមិភាគ ឬ កងពលបញ្ជា ក៏ប៉ុន្តែខ្ញុំដឹងពីត្រឹមមកភូមិភាគ ហើយនិងកងពល បញ្ជាបាននៅក្នុងភូមិភាគរបស់ខ្លួនប៉ុណ្ណោះ។ ឯរឿងរបស់មជ្ឈិមខ្ញុំមិនបានដឹងកិច្ចការរបស់គាត់ថា កងណានៅក្រោមរបស់មជ្ឈិម ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ ឥឡូវនេះគឺយើងនិយាយអំពីភូមិភាគវិញម្តង អម្បាញ់មិញនេះ គឺថាយើងបាននិយាយថាមានការប្រែប្រួលនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល ដែលថានៅក្នុងការបែងចែកភូមិភាគជាដើម ហើយជាពិសេសនោះ ការទាក់ទងទៅនឹងភូមិភាគនិរតីតែម្តង។ គឺវាជាការច្បាស់ណាស់ដែលថាមានការបែងចែក ឬក៏ថាបែងចែកឡើងវិញជាថ្មី គឺថាគេរក្សាភូមិភាគបស្ចិម អ៎! រក្សាភូមិភាគនិរតី ហើយបង្កើតភូមិភាគបស្ចិម។ តើការបែងចែកបែបនេះហ្នឹងកើតមានឡើងនៅពេលណាដែរ?

[១០:៥៩:៤៩]

**ឆ៖** បាទ ខ្ញុំមិនបានចាំថ្ងៃខែ បែងចែកភូមិភាគបស្ចិម និរតី ខ្ញុំមិនបានចាំថ្ងៃខែទេ។ តែដឹងថា -- មិនបានគិតពីរឿងថ្ងៃខែទេ ប៉ុន្តែដឹងថា ក្រោយពី៧៥ មក វាមានការបែងចែកកងទ័ពភូមិភាគនិរតី និងភូមិភាគបស្ចិម។ ហើយខ្ញុំដឹង -- ខ្ញុំអត់ដឹងខែថ្ងៃតែប៉ុណ្ណឹង។

**ស៖** តើការប៉ះពាល់នៃការផ្លាស់ប្តូរនេះយ៉ាងម៉េចដែរ? តើកងពលទី១ ដែលពីដើមមកនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក នោះ បែរមកនៅក្រោមអំណាចរបស់លេខាភូមិភាគផ្សេងមួយ តើអ៊ីចឹងទេ?

**ឆ៖** បាទ អ៊ីចឹង។

**ស៖** ជាបឋម លោកបាននិយាយថា បន្ទាប់ពីវ៉ៃបានភ្នំពេញហើយ លោកបានចេញ គឺថាចេញទៅខេត្តកំពត។ តើលោកចេញទៅកំពតហ្នឹងធ្វើអ្វីដែរ? ហើយទៅជាមួយមនុស្សប៉ុន្មាននាក់? ហើយនៅកំពតនោះអស់រយៈពេលប៉ុន្មានដែរ?

[១១:០១:៣៨]

**ឆ៖** បាទ ក្រោយពីចេញទៅកំពតនោះ ខ្ញុំទៅទទួលការងារ នាំកងទ័ពទៅដោះមីនតាមផ្លូវរទេះភ្លើង គឺថាប្រុងធ្វើផ្លូវរទេះភ្លើងហ្នឹង ក៏នាំកងទ័ពទៅដោះមីនតាមផ្លូវហ្នឹង ដើម្បីឲ្យខាងគេធ្វើផ្លូវរទេះភ្លើង ប្រហែលជា៣ខែ។

**ស៖** តើកងកម្លាំងរបស់លោកនោះ ត្រូវគេចាត់ទៅធ្វើការបង្កបង្កើនផល ឧទាហរណ៍ដូចជា

ដាំស្រូវ ធ្វើស្រែនៅកំពតដែរឬទេ?

**ឆ៖** បាទ ទៅដល់នុំងអត់បានធ្វើស្រែទេ ធ្វើតែ ឆ្ការតែផ្លូវ ហើយនិងដោះតែមីន តាមផ្លូវពីទូកមាសមកត្រាំសរសរ។ ដោះមីនហ្នឹង ប៉ុណ្ណឹង ធ្វើតែប៉ុណ្ណឹង។

**សៈ** កន្លែងដែលលោកឈរជើងនោះ នៅក្រោមឱវាទតំបន់កំពត ហើយអ្នកណាជាប្រធានតំបន់កំពតនោះ?

**ឆ៖** កាលខ្ញុំទៅហ្នឹង មានឈ្មោះតារិន ៗតំបន់កំពតនោះ ប៉ុន្តែឥឡូវមិនដឹងគាត់ទៅណា ខ្ញុំមិនដឹងដែរ។

**សៈ** តើតំបន់កំពតនោះ ឈ្មោះថាតំបន់៣៥ ហើយតើមានមនុស្សម្នាក់ដែលឈ្មោះ កង ចាប ហៅ ស៊ី ហ្នឹង អ្នកណាគេ? បាទ ជាសមាជិកគណៈតំបន់?

[១១:០៣:៥២]

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ផង កង ចាប។ គឺឈ្មោះមិនដែលស្គាល់គាត់ផង មិនដែលជួបផង។

**សៈ** តើលោកទៅភូមិភាគបស្ចិមនៅពេលណា?

**ឆ៖** ដូចជាទៅឆ្នាំ ចុងឆ្នាំ៧៦ ៗ ប៉ុន្តែខ្ញុំមិនដឹងថាខែប៉ុន្មាន ខ្ញុំភ្លេច មិនចាំខែថ្ងៃ។

**សៈ** ការចេញដំណើររបស់លោកទៅភូមិភាគបស្ចិមនោះ គឺថាលោកចេញទៅក្នុងពេលដែលគេតែងតាំងលោកធ្វើជាអនុប្រធានកងពលទី១ អ៊ីចឹងមែនទេ គឺថាចេញទៅនៅពេលដែលគេតែងតាំងលោកហ្នឹង?

**ឆ៖** បាទ នៅ នៅឡើយទេ ខ្ញុំតែ ១ឆ្នាំមួយទៀត។ ខ្ញុំនៅឈរតាមព្រំកោះកុង ១ឆ្នាំ បានគេតែងតាំងព្រោះ ខ្ញុំវាប្រធានវរសេនាធំនោះ ដល់ពេលខ្ញុំឈរ ១ឆ្នាំបានគេតែងតាំងខ្ញុំ។

**សៈ** នៅពេលនោះ កងកម្លាំងនៃកងពលលេខ១ ទាំងអស់នោះត្រូវចាត់ទៅភូមិភាគបស្ចិម ឬក៏មានអង្គភាពមួយចំនួនដែលស្ថិតនៅ -- ចាត់តាំងទៅភូមិភាគផ្សេងទៀត ក្រៅពីភូមិភាគនិរតី?

**ឆ៖** បាទ ពេលដែលខ្ញុំទៅៗឈរនៅកោះកុង ១ឆ្នាំជាង ប៉ុន្តែទៅមិនអស់គ្នាទេ កងពលហ្នឹងទៅតែមួយវរៈ ជាមួយវរសេនាធំទេ ប្រហែលជា ២.៧០០ ប៉ុណ្ណឹងឯង។ ភាគច្រើននៅឯក្រោយនេះ នៅលង្វែកឯនេះ។ ហើយពេលខ្ញុំទៅនៅបានប្រហែលជាង ១ឆ្នាំ គេនៅខាងក្រោយនេះ គេចាត់កម្លាំងខាងក្រោយឲ្យទៅភូមិភាគខាងពាយព្យ ទៅប្រហែលជា ១០០នាក់ៗ ប៉ុណ្ណឹងខាងកងពល -- លេខាកងពលគាត់ចាត់តាំងទៅមិនដឹងជាគាត់ពិភាក្សាជាមួយអ្នកណាខ្ញុំអត់បាននៅក្រោយដែរបាទ។

[១១:០៧:០៦]

**ស៖** លោកសាក្សី ខ្ញុំយល់ហើយប្រហែលជាមានបញ្ហាបកប្រែហើយ ខ្ញុំស្តាប់ឮថា លោកក៏ជាប្រធានកងពលធំដែលទទួលបន្ទុកនៅខេត្តកោះកុង។ ខ្ញុំក៏បានឮផងដែរថា កម្លាំងផ្សេងទៀតនៅខាងក្រោយ ក៏ប៉ុន្តែយើងមិនបានឮអំពីឈ្មោះទីកន្លែងដែលកងទ័ពរបស់លោកឈរជើងនោះទេ តើនៅកន្លែងដដែលតែមួយទេ ឬក៏នៅកន្លែងផ្សេងខុសគ្នា? លោកអាចឆ្លើយនឹងសំណួរនេះបានទេ?

**ឆ៖** សូមលោកបញ្ជាក់ម្តងទៀត ផ្នែកសំណួរនេះ។ ខ្ញុំមិនបានយល់។

**ស៖** បាទ លោកសាក្សី ខ្ញុំឮថាលោកបាននិយាយថា លោកជាប្រធានកងវរសេនាធំដែលឈរជើងនៅតំបន់កោះកុង ក៏ប៉ុន្តែកងកម្លាំងមួយចំនួន ខ្ញុំមិនដឹងថា ជាកងកម្លាំងរបស់លោក ឬក៏កម្លាំងរបស់កងពលណាទេ នៅខាងក្រោយ។ ក៏ប៉ុន្តែខ្ញុំមិនដឹងថា នៅកន្លែងណាទេ ដែលកងកម្លាំងនេះឈរជើងនោះ គ្រាន់តែអ្វីដែលខ្ញុំចង់ដឹងនោះ គឺថា តើឈរជើងនៅកន្លែងតែមួយ ឬក៏មានកន្លែងផ្សេងខុសគ្នាដែលថាកន្លែងឈរជើងរបស់កងពលលេខ១ នោះ?

**ឆ៖** បាទ ចង់បញ្ជាក់អ៊ីចេះ ខ្ញុំប្រធានវរសេនាធំក្នុងពេលនោះ មិនមែនប្រធានកងពលទេ គឺប្រធានវរសេនាធំ។ ហើយដែលទៅឈរជើងកន្លែងនោះ ហើយដែលគេតែងតាំងខ្ញុំបាន១ឆ្នាំ ហើយបានគេតែងតាំងខ្ញុំអនុកងពល ប៉ុន្តែកងពលខ្ញុំទាំងពីរនេះវានៅពីរផ្នែក។ មួយផ្នែកដែលខ្ញុំនៅកោះកុង ហើយមួយផ្នែកទៀតនៅបន្ទាយលង្វែកទៅមិនអស់ទេ។ ហើយប្រធានកងពលហ្នឹងគាត់នៅខាងក្រោយបន្ទាយលង្វែកផង ពេលដែលកម្លាំងទៅពាយ័ព្យ ១០០នាក់នោះ គឺប្រធានកងពលគាត់ចាត់ចែងទៅ។ ហើយមិនមែនខ្ញុំចាត់ចែងទៅទេ ហើយគាត់ចាត់ចែងកម្លាំងដែលទៅនោះ គឺកម្លាំងដែលនៅខាងក្រោយបន្ទាយលង្វែកបាទ។

[១១:០៩:៤៩]

**ស៖** តើចំនួនសរុបរបស់កូនទាហានលោកទាំងអស់នុ៎ងមានប៉ុន្មាននាក់ដែរ នៅពេលដែលលោកឈរជើងនៅកោះកុង?

**ឆ៖** ទៅប្រហែលជា២៧០០ ប៉ុណ្ណឹងទេ ទៅបានតែ១ខែ គឺគ្រុនចាញ់មកវិញអស់ខ្លះ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមនិយាយ -- ក្រឡេកមើលផែនទីរបស់កម្ពុជាប្រជាធិបតេយ្យដែលខ្ញុំបានចែកចាយអម្បាញ់មិញនេះ ហើយខ្ញុំសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផងដែរលោកប្រធាន។ បាទ ដើម្បីឱ្យច្បាស់លាស់តែម្តង ភូមិភាគបស្ចិម គឺជាភូមិភាគដែលមានពណ៌១បៃតងខ្ចី។ បាទ ខ្ញុំសូមបញ្ជាក់

ផងដែរថា ផែនទីនេះមិនមែនជាឯកសារថ្មីនោះទេ គ្រាន់តែជាឯកសារដែលយើងបានបកប្រែឈ្មោះជាភាសាខ្មែរនៅក្នុងនេះ។ ពីព្រោះជាផែនទីដែលបោះពុម្ពនៅក្នុងឆ្នាំ១៩៧៦ ជាភាសាខ្មែរ ហើយដើម្បីឱ្យយើងយល់ទាំងអស់គ្នា។ ដូច្នេះយើងបកប្រែជាន់លើផែនទីនេះតែម្តង។ ទាក់ទងទៅនឹងសំណៅជាភាសាបារាំង ដែលមាននៅក្នុងសំណុំរឿង គឺថាមានការភ័ន្តច្រឡំមួយ ពីព្រោះថាភូមិភាគ៤០១ សូមទោស! ៤០៥ ទេ គឺជាភូមិភាគពាយ័ព្យ ក៏ប៉ុន្តែតាមពិតភូមិភាគនិរតី។ ភូមិភាគបស្ចិម គឺថាលាតសន្ធឹងពីកំពង់ឆ្នាំងរហូតដល់កោះកុង ហើយគ្រប់ដណ្តប់ផ្នែកខាងលិចនៃទីក្រុងភ្នំពេញ ហើយនេះមានផ្នែកធំមួយនៃឆ្នេរសមុទ្រខ្មែរ។ លង្វែក ដែលយើងបាននិយាយនេះ តើលង្វែកនេះជាទីបញ្ជាការរបស់កងពលលេខ១ដែរឬទេ?

[១១:១២:១៦]

**ឆ៖** បាទ លង្វែកទីបញ្ជាការរបស់កងពលលេខ១។

**ស៖** ភូមិភាគបស្ចិម មើលទៅហាក់ដូចជាគ្របដណ្តប់តំបន់ចំនួន៣ គឺថាតំបន់៣១, ៣២, ៣៧ ហើយខ្ញុំឃើញលើផែននេះផងដែរ ថាមានតំបន់មួយដែលមានឈ្មោះថា តំបន់១១។ តើលោកអាចបញ្ជាក់អំពីចំនួនតំបន់ ហើយនិងឈ្មោះតំបន់ទាំងនេះបានដែរឬទេ? ហើយលោកអាចចង្អុលបង្ហាញជូនតុលាការបានទេ នៅទីតាំងនៃលង្វែកនេះនៅកន្លែងណាដែរ?

**ឆ៖** តំបន់១១ វាអត់មានផង មានតែ៣១។ មាន៧កំពង់ស្ពឺ តំបន់៣១, កំពង់ឆ្នាំង តំបន់៣២ ហើយនិងកោះកុង ៣៧ បាទ។

**ស៖** បាទ ដូច្នេះតំបន់១១ ឃើញថាមាននៅលើផែនទីនេះ ដែលឃើញថាមាននៅលើផែនទីនេះ គឺថាមានតំបន់១១។ អ៊ីចឹងតើតំបន់១១នេះ ដែលនៅព្រំដែននេះ ដែលនៅជាប់នឹងភូមិភាគពាយ័ព្យ។ លោកឃើញទេសរសេរលេខ ១១ នៅជាប់ព្រំដែន? លោកចង់និយាយថា តំបន់១១នេះ ពុំមានទេនៅក្រោមរបបខ្មែរក្រហមនោះ? អ៊ីចឹងឬក៏យ៉ាងម៉េច?

[១១:១៤:២៣]

**ឆ៖** បាទ ខ្ញុំអត់បានដឹងផង តំបន់១១ អត់ដែលឮផង។

**ស៖** បាទ យើងឃើញតំបន់៣២ នៅជាប់នឹងកំពង់សោម នៅពីលើកំពង់សោមនេះ។ តើលោកអាចជម្រាបជូបបានទេថា ទីក្រុងកំពង់សោមនេះមានឋានៈពិសេស ឬក៏ថានៅក្រោមឱវាទភូមិភាគបស្ចិម ឬក៏ភូមិភាគនិរតី? ឬក៏ភូមិភាគនិរតី ឬក៏ទីក្រុងកំពង់សោមនេះ មានឋានៈពិសេសណាមួយ?

**ផ៖** បាទ នៅខាងកំពង់សោម ខ្ញុំមិនដែលទៅទេ ខ្ញុំទៅឆ្លងតាមនេះ បើខ្ញុំទៅកោះកុង ខ្ញុំទៅតាមស្រែអំបិល ផ្លូវក្នុងទេ ខ្ញុំអត់ដែលទៅខាងកំពង់សោមផង មិនដឹងពី -- ក្រុងកំពង់សោម ក៏ខ្ញុំអត់ដែលចុះទៅខាងហ្នឹងដែរ។

**ស៖** តើលោកដឹងថា អ្នកណាជាប្រធានក្រុងកំពង់សោមដែរឬទេនៅសម័យនោះ? តើមានគណៈកម្មការដែលទទួលបន្ទុកអំពីការ -- ទទួលបន្ទុកដឹកនាំក្រុងកំពង់សោមនេះដែរឬទេ?

**ផ៖** បាទ អត់ផង អត់ដឹងផង។

[១១:១៦:១៨]

**ស៖** តើលោកធ្លាប់ ឮគេនិយាយអំពីកងពល -- បាទ សូមកែប្រែ ថាតើលោកអាចនិយាយអ្វីជូនតុលាការបានទេ ទាក់ទងនឹងកងពលលេខ១ ហើយដែលកងពលលេខ៣ ដែលមានឈ្មោះ មាស មុត នេះ?

**ផ៖** បាទ កងពលខ្ញុំ ខ្ញុំពីត្រឹមកោះកុង។ ដូចខ្ញុំនិយាយអ៊ីចឹង ត្រឹមពីកោះស្ដេច កោះកុង ទៅជើងទៅ អាហ្នឹងខាងកង១ពល ខ្ញុំ។ ឯមកត្បូងវិញ គេហៅថា កងពលលេខ៣ហ្នឹងហើយ ប៉ុន្តែគេ កងពលប្រធានកងពលហ្នឹង គេមិនដែលមកទាក់ទងខ្ញុំនឹងផង។ ទាក់ទងត្រឹមតែវរសេនាធំ ឬក៏វរសេនាតូច។ បើវរសេនាតូច គេមកញឹកញាប់ ប៉ុន្តែវរសេនាធំ គេមិនដែលមកញឹកញាប់។ គេមិនដែលមកផង និយាយរួមមកតាំងពីខ្ញុំនៅ៣ឆ្នាំ។ មានការទាក់ទងតែវរសេនាតូច មកជាមួយនឹងខ្ញុំជាប់គ្នាបាទ។

**ស៖** តើលោកធ្លាប់ឮនិយាយអំពីកងពល១៦៤ ដែរឬទេ?

**ផ៖** បាទ ក្នុងពេល១ដែលនៅព្រំដែនខាងលិចអត់មានឮទេ តែដល់ពេលទៅវៃ១ព្រំដែនខាងកើត បានឮកងពល១៦៤ ពីព្រោះ១៦៤ហ្នឹង បានវៃនៅតាមព្រំដែនខាងកើត ហើយពួកខាងខ្ញុំមួយចំនួនដែលគេចាត់ទៅហ្នឹង ក៏បានទៅជាប់គ្នាហ្នឹង ស្គាល់គ្នាថាដឹងថា ១៦៤ មាននៅខាងនុំង បាទ។

**ស៖** តើអ្នកណាជាមេកងពល១៦៤?

[១១:១៩:០០]

**ផ៖** បាទ ខ្ញុំដូចជាមិនបានចាំទេ ប្រហែលជាការដែលទៅវៃតាមព្រំដែនហ្នឹង ឮពួកខាងខ្ញុំនិយាយថា តាមុត ទទួលខាង១៦៤ ស្លៀកខោអាវខៀវ។ អាហ្នឹងដែលពេលវៃហើយ ដែលមានការឈ្លោះជាមួយនឹងកងពលខាងខ្ញុំហ្នឹង បានឮពួកទាហានខាងខ្ញុំនិយាយប្រាប់។

**ស៖** បាទ ដូច្នេះលោកដឹងថា មាស មុត ជាមេកងពល១៦៤នុំង អ៊ីចឹងមែនទេ លោកបានដឹងថា

គាត់ជាមេហ្នឹង? អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំដឹងអ៊ីចឹងមែន។

[១១:២០:០៦]

**ស៖** បាទ ឥឡូវនេះសូមលោកប្រាប់ ថាតើលោកដឹងថាមានអត្ថិភាពនៃកងកម្លាំងទាហានជើងទឹករបស់ប្រទេសកម្ពុជា តើការរៀបចំកងកម្លាំងជើងទឹកនេះ ធ្វើឡើងរបៀបណាដែរ ហើយអ្នកណាជាមេបញ្ជាការ?

**ឆ៖** បាទ ខ្ញុំដឹងថា កងជើងទឹកហ្នឹងមានៗ តាមុត ហ្នឹងហើយតាមមើល។ ១៦៤ ប៉ុន្តែខ្ញុំដឹងច្បាស់តែពេលឆ្នាំ៧៩ ហើយទេ ពេលវៃហ្នឹង ប៉ុន្តែដឹងថា គាត់ជាអ្នកទទួលខុសត្រូវនៅក្នុងកងពលហ្នឹង បាទ។ ប៉ុណ្ណឹង។

**ស៖** តើកងជើងទឹកកម្ពុជាហ្នឹង ឈរជើងនៅឯណាដែរ?

**ឆ៖** បាទ កងជើងទឹកហ្នឹងឈរជើងនៅកំពង់សោមហ្នឹង។ ព្រោះនេះកំពង់សោម ហើយពីផ្នែកទៅកំពង់សោមទៅកោះៗពូលូវៃ កោះតាង ហើយនិងកោះត្រង់ណាទៀតទេ ខ្ញុំមិនដឹងច្បាស់អស់។ មុខផ្នែកគេនៅខាងហ្នឹង។

[១១:២១:៤២]

**ស៖** បាទ ឥឡូវសូមត្រឡប់មកនិយាយអំពីការងារលោកវិញម្តង ហើយនិងបេសសកម្មរបស់លោកនៅកោះកុង។ តើលោកអាចជម្រាបជូនបានដែរឬទេថាបេសកកម្មរបស់លោកនុ៎ង គឺថាកម្រិតមកត្រឹមតែកោះកុងទេ ឬក៏បេសកកម្មរបស់លោកគ្របដណ្តប់លើតំបន់៣៧ទាំងមូលតែម្តង ដែលថាដែលយើងឃើញ ដូចដែលយើងឃើញនៅលើផែនទីដែលខ្ញុំបានចែកពីព្រឹកមិញនេះ?

**ឆ៖** បាទ ភារកិច្ចខ្ញុំមិនៗមានសិទ្ធិអីមកគ្រប់គ្រងតំបន់ទាំងមូលទេ។ តំបន់ទាំងមូលនៅលើតែខាងតំបន់ ហើយពិសេសអាចមានភូមិភាគគេចុះដែរក៏មិនដឹង ខ្ញុំមិនបានដឹង។ នាទីខ្ញុំ ភារកិច្ចខ្ញុំត្រឹមតែព្រំដែន កោះ ហើយនិងទឹកប៉ុណ្ណឹង។

**ស៖** តើលោកទាក់ទងជាមួយអាជ្ញាធរតំបន់៣៧ ដែរឬទេ នៅសម័យនោះ?

**ឆ៖** បាទ ខ្ញុំទៅមិនទាន់ទេ ពីព្រោះតំបន់ហ្នឹងម្តងអ្នកនេះ ម្តងអ្នកនោះ ប៉ុន្តែខ្ញុំទៅគេ -- អ្នកដែលខ្ញុំទៅហ្នឹង គឺគ្មានទេ ប្រជាជនគ្មាននៅកន្លែងខ្ញុំទាំងអស់ អត់មានទេ។ ឯតំបន់ កាលដំបូងគឺ តាសារីហ្នឹង តាសារី ដែលគាត់មកហ្នឹង គាត់ពិការជើង គាត់មកហ្នឹង ថាទទួលតំបន់ ដល់ក្រោយខ្ញុំទៅទៀត ថា

តាសារី ហ្នឹង បាត់ តាសារី, តារ៉ន ណា -- បាត់គាត់ តាញ៉ឹក ឯណានោះ។ ខ្ញុំអត់បានទាន់គាត់ទេ។ ដឹងថាកន្លងទៅកិច្ចការងាររបស់ខាងក្រោយ មិនដឹងគេផ្លាស់ប្តូរយ៉ាងណា ខ្ញុំមិនសូវដឹងដែរ។ ខ្ញុំដឹងតែទៅមុខហើយ ទៅមុខប៉ុណ្ណឹងឯងបាទ។

[១១:២៤:១៥]

**ស៖** បាទ លោកបាននិយាយថា មាន តាសារី, តាញ៉ឹក ហើយពួកគាត់ទាំងអស់គ្នានោះ តើមានរឿងអីកើតឡើងចំពោះគាត់ គាត់ផ្លាស់ទីដូរទៅកន្លែងណាណី ឬក៏គាត់បាត់ខ្លួន? លោកដឹងថាមានរឿងអីកើតឡើងចំពោះគាត់ដែរឬទេ?

**ឆ៖** បាទ តាសារី ហ្នឹង គាត់មេខ្ញុំ គាត់មេបញ្ជាការខ្ញុំ គាត់ពិការជើង។ ហើយគាត់ធ្វើអីមិនកើតទៅ ឲ្យទៅឈរជើងស្រែអំបិល។ ហ្នឹងខ្ញុំដឹងរឿងគាត់មួយ ពេលដែលគាត់ដើរបាត់ហ្នឹងប្រហែលគាត់មកកន្លែងភាគ ហើយក្រោយមកទៀតមក តារ៉ន។ តារ៉ន ក៏គាត់ពិការដែរ។ ហើយនៅជាប់មុនដំបូងហ្នឹង គឺដឹងថា តាញ៉ឹក ឈ្មោះ តាញ៉ឹកៗ ខ្ញុំទៅអត់ទាន់ទេ ទៅអត់ទាន់គាត់ទេ ហើយឈ្មោះ តាអ៊ីវ ហ្នឹងគាត់ជាៗ ប្រធានកងតំបន់៣៧ ហ្នឹង ក៏ប៉ុន្តែខ្ញុំទៅអត់ទាន់គាត់ទេ ដឹងតែឈ្មោះ ហើយពេលដែលខ្ញុំទៅហ្នឹង ក៏គាត់មិនទៅខាងណា គាត់ផ្លាស់ប្តូរមកខាងភាគហើយ ប៉ុន្តែគាត់មកប្រជុំគ្នាខាងមន្ទីរកន្លែង -- មកកន្លែង តាស៊ី កំពង់ស្ពឺ។ ប៉ុន្តែមិនដឹងផ្លាស់ប្តូររបៀបណា ខ្ញុំមិនបានដឹងកិច្ចរបស់គាត់នៅខាងក្រោយ បាទ។

[១១:២៥:៥២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំមានឯកសារមួយ ដើម្បីដាក់ជូនដល់សាក្សី គឺថាឯកសារ D43/IV ជាអក្សររម៉ាំង ហើយនិងឧបសម្ព័ន្ធ១១៨។ បាទ សូមជូនឯកសារនេះទៅសាក្សី។ សូមការអនុញ្ញាតលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ គឺជាចម្លើយសារភាពរបស់ ប៉ុក ពិន ហៅ ស៊ីវ ដែលជាសមាជិកនៃតំបន់បស្ចិម ភូមិភាគបស្ចិម ERN 001747--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកចៅក្រមអានលេខ ERN ឡើងវិញ លោកប្រធាន។ ស្តាប់អត់ទាន់។

**ប្រធានអង្គជំនុំ៖**

អាន១ លេខ ERN ឡើងវិញ លោក ឡាវ៉ែន៍! អ្នកបកប្រែបកមិនទាន់ទេ។

[១១:២៧:១៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ ERN ជាភាសាខ្មែរ គឺ 00174775 ទៅដល់ 81, ERN ជាភាសាអង់គ្លេស គឺ 00782272 ទៅដល់ 78 ហើយមានលេខ ERN មួយទៀត គឺថា 00224640។ ខ្ញុំអត់មានលេខ ERN ជាភាសាបារាំងទេ។

**ស៖** តើលោកស្គាល់ឈ្មោះ លោក ប៉ុក ពិន ហៅ ស៊ីវ នេះដែរឬទេ លោកសាក្សី?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ អត់ស្គាល់ដែរ។

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំសូមបញ្ជាក់ថា ចម្លើយសារភាពនេះ គឺថាចុះនៅថ្ងៃទី២៦ សីហា ឆ្នាំ៧៧ ហើយយើងមានចំណារនៅទំព័រទី១ ហើយដូចជាចំណារដែលនិយាយអំពីការពាក់ព័ន្ធរបស់មនុស្សផ្សេងទៀត ដូចជា គឹម ហើយនិង តានរ។ តើលោកសាក្សី លោកធ្លាប់ឮឈ្មោះ គឹម ហើយនិង តានរ នេះឬទេ?

[១១:២៨:០៣]

**ឆ៖** បាទ ស្គាល់។ ខឹម មិនមែន គឹម ទេ ខឹម ហើយនិង តានរ។ គាត់មិនមែនឈ្មោះ គឹម ទេ ខឹម។

**ស៖** បាទ បន្ទាប់ពីចម្លើយសារភាពរបស់ ប៉ុក ពិន នេះ ដែលបានត្រូវបានផ្ញើជូនទៅតំបន់៤០០ ហើយនិងបស្ចិម ហើយ ខឹម នេះ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ហើយ តានរ នេះ មិនដឹងថា គាត់ទៅណាទេ។ តើលោកដឹងថា តានរ នេះ បាត់ខ្លួនដែរឬទេ?

**ឆ៖** បាទ សូមបញ្ជាក់ ខឹម នេះ គាត់នៅតំបន់ -- មុនគាត់នៅតំបន់ ៣១ កំពង់ស្ពឺហ្នឹង គាត់ប្រធានយោធាតំបន់ហ្នឹង។ ហើយខាង តានរ នោះគាត់ធ្លាប់ចេញចូលព្រៃជាមួយខ្ញុំឆ្នាំ១៩៦៨ ក៏ប៉ុន្តែពេលដែលខ្ញុំធ្វើទ័ពគាត់ក៏នៅខាងការងារមូលដ្ឋាន ហើយបែកគ្នារហូតពីឆ្នាំ៧០ មក។

**ស៖** អ៊ីចឹងលោកមិនដឹងថា តានរ នេះ នៅរស់ ឬក៏ស្លាប់នោះទេ អ៊ីចឹងមែនទេ?

**ឆ៖** ដឹងថាស្លាប់ ដឹងគេប្រាប់ថាស្លាប់។

**សះ** តើលោកស្គាល់មេភូមិភាគបស្ចិម ឧទាហរណ៍ដូចជា ជូត ជេត ស៊ី នេះ តើលោកស្គាល់គាត់ដែរឬទេ?

**ឆះ** បាទ ស្គាល់។ ពីដើមគេអត់ហៅ ជូ ជេត ទេ គេហៅតែ តាស៊ីៗអ៊ីចេះឯង។

**សះ** តើលោកដឹងថា ជូ ជេត នេះត្រូវបានគេចាប់ខ្លួននៅពេលណាដែរឬទេ?

**ឆះ** បាទ ខ្ញុំមិនបានដឹងដែរ។ ដឹងថាបាត់ ប៉ុន្តែមិនដឹងថាទៅណា ខ្ញុំមិនដឹងកិច្ចការរបស់គាត់។

**សះ** បាទ យើងមានការចង្អុលបង្ហាញមួយចំនួន គឺថាយើងមានចម្លើយសារភាពរបស់ ជូ ជេត ហៅ ស៊ី នេះ គឺឯកសារ E3/1682 ហើយយើងមានផងដែរ ថា ERN ជាភាសាខ្មែរ គឺថា 00013660 ទៅដល់ 00013990។ យើងក៏ដឹងផងដែរថា អ្នកស្រី លី នារី ខ្ញុំមិនដឹងថាត្រូវអានឈ្មោះហ្នឹងយ៉ាងម៉េចទេ ជាប្រពន្ធរបស់ ជូ ជេត ជាប្រធានតំបន់បស្ចិម។ តើលោកស្គាល់ លី នារី នេះទេ?

**ឆះ** បាទ ឃើញគាត់ម្ដង ឃើញគាត់ក្នុងឆ្នាំ៧៥ ឃើញគាត់ម្ដង តែមិនច្បាស់ថាប្រពន្ធ តាស៊ីផង។

[១១:៣៣:៤៣]

**សះ** បាទ ខ្ញុំសូមបំភ្លឺចំណុចមួយចំនួន។ ចម្លើយសារភាពរបស់ ជូ ជេត គឺថា មានលេខ ERN ដូចទៅនេះ ERN ជាភាសាអង់គ្លេស -- ព្រោះខ្ញុំបានឲ្យ ERN ជាភាសាខ្មែរហើយ គឺថា 00818951 ទៅដល់ 00819084, ជាភាសាបារាំង គឺ 00842835 ទៅដល់ 00842896។ ទាក់ទងទៅនឹងប្រពន្ធរបស់ ជូ ជេត នេះ ហើយយើងដឹងថាគាត់ត្រូវបានគេចាប់ខ្លួន ហើយនិងបញ្ជូនទៅភ្នំពេញបើតាមមើលទៅ។ ហើយមានសំបុត្រមួយចុះនៅឆ្នាំ១៩៧៨ E3/1918, "ខ្ញុំមានកិត្តិយសណាស់ ដែលបញ្ជូន លីនី ជាប្រពន្ធរបស់ ស៊ី តាមរយៈក-៧"។ ដូច្នេះមានការចាប់ខ្លួនមួយទ្រង់ទ្រាយធំ នៅខែមីនា ឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំសូមឲ្យលោកប្រាប់ថា តើអ្នកណាជាអ្នកជំនួស ជូ ជេត ដែលជាប្រធានតំបន់ភូមិភាគបស្ចិម បាទ?

**ឆះ** បាទ ដូចជាបាត់គាត់ទៅ ដូចជាគ្មាន។ មាន តាសៀង ម្នាក់ឯង។ តាសៀងកងពល ប្រធានកងពលម្នាក់ឯង។

**សះ** តាសៀងនេះជាសមាជិកគណៈតំបន់ ពីលើមុខងារគាត់ជាលេខាកងពលលេខ១ តើអ៊ីចឹងមែនទេ?

**ឆះ** បាទ គាត់អត់ទទួលទេគណៈតំបន់នោះ គាត់ទទួលតែលេខាកងពល ហើយបានរងពីតាស៊ី

ហ្នឹងឯងបាទ។

[១១:៣៦:៤០]

**ស៖** តើអ្នកណាជំនួសញ៉ើក បន្ទាប់ពីគាត់ត្រូវបានគេចាប់ខ្លួននៅតំបន់៣៧ នោះ?

**ឆ៖** បាទ តាមដឹងខ្លះ បាត់តាញ៉ើក ឃើញតាដូចជា តារស់ អ៎! តារដ្ឋ តែគាត់ហៅឈ្មោះគាត់ដើម ហៅតារស់ ប៉ុន្តែគេហៅគាត់តារដ្ឋៗ ផ្លាស់ទៅ។ ហើយផ្លាស់ទៅតែម្នាក់គាត់ទេ ហើយបន្ទាប់ទៀតមិនដឹងអ្នកណាមួយទៀតទេ ខ្ញុំភ្លេចឈ្មោះទៅ។

**ស៖** ហើយតារដ្ឋហៅៗអី--

**អ្នកបកប្រែ៖**

អ្នកបកប្រែស្តាប់មិនច្បាស់ទេ អំមិញលោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ហើយគាត់ហ្នឹងជាអនុលេខាតំបន់៣១មែនទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ តារស់ ៗហៅរដ្ឋ គាត់នៅតំបន់៣១ កំពង់ឆ្នាំង។ កំពង់ឆ្នាំង៣១ អ៊ីចឹងហើយ ៣១អ៊ីចឹងហើយ ដកគាត់ទៅហ្នឹង។ ហ្នឹងហើយ តារស់ ហៅ រដ្ឋ បាទ។

**ស៖** បាទ ឥឡូវសូមនិយាយអំពីតំបន់៣៧ វិញម្តង គឺថា តំបន់៣៧ មានផ្នែក -- មួយផ្នែកនុ៎ងថា នៅលើដីគោក ហើយផ្នែកមួយទៀតជាកោះ នៅក្នុងផ្នែកដែលថាជាឆ្នេរសមុទ្រនោះ នៅកន្លែងនោះ តើលោកធ្លាប់មានឮគេនិយាយ អំពីស្រែអំបិលដែរឬទេ? ហើយនៅស្រែអំបិលនេះមានអ្វីដែរ?

[១១:៣៩:០៩]

**ឆ៖** បាទ មានដែរ មានតំបន់ស្រែអំបិល។ ស្រែអំបិលហ្នឹងមានវត្តស្រែអំបិល ហើយមន្ទីរកន្លែងមន្ទីរតាញ៉ើកនៅកន្លែងហ្នឹង ពីដើមពីមុននោះ ទីកន្លែងគាត់នៅមុននោះ នៅកន្លែងហ្នឹងឯង។

**ស៖** តើស្រែអំបិលនេះ ថាគេស្គាល់ស្រែអំបិលហ្នឹង ដោយសារនៅទីនោះមានស្រែអំបិល ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំអត់ដែលទៅដល់អាកន្លែងអំបិល ប៉ុន្តែគេហៅស្រែអំបិល ហៅតាមតែគេអ៊ីចឹងទៅ។ គេហៅពីដើមមក ក៏ស្រែអំបិលអ៊ីចឹងដែរ កោះកុងស្រែអំបិលៗ។

**ស៖** តើលោកស្គាល់ស្រុកព្រៃនប់ដែរឬទេ?

[១១:៤០:២១]

**ឆ៖** បាទ ទីរួមស្រុកខ្ញុំអត់ដឹងដែរ ពីសង្គមនៅឡើយ ក៏ខ្ញុំដែលមិនដែលទៅដែរទីរួមស្រុក ដឹងតែស្រុកព្រៃនប់ ៗ ប៉ុន្តែទីរួមស្រុកគេមិនដឹងនៅត្រង់ណាទេ ខ្ញុំមិនដែលចូលកន្លែងស្រុកផង។

**ស៖** តើមន្ទីរសន្តិសុខដែលលោកនិយាយជាច្រើនដងហើយថា គឺកោះ -- មន្ទីរសន្តិសុខកោះខ្យងនោះ នៅក្នុងស្រុកព្រៃនប់មែនឬទេ?

**ឆ៖** បាទ នៅក្នុងស្រុកព្រៃនប់ហ្នឹងឯង។

**ស៖** ហើយមន្ទីរសន្តិសុខនុ៎ងស្ថិតនៅក្រោមការដឹកនាំរបស់អ្នកណាដែរ?

**ឆ៖** បាទ អង្គាល់នុ៎ងនៅតំបន់របស់ -- កាលដំបូងខ្ញុំទៅមិនទាន់ទេ ប៉ុន្តែកាលនោះមាន តាញ៉ឹក គាត់នៅតំបន់ស្រែអំបិលហ្នឹង ស្រុកព្រៃនប់ហ្នឹង។ ប៉ុន្តែដល់យើងទៅ ៗ នៅកោះកុងនៅកន្លែងហ្នឹងមានផ្លាស់ៗ តារស់ ហ្នឹងគាត់ទៅនៅនុ៎ង គាត់ទៅនៅស្រុកព្រៃនប់នុ៎ងដែរ ខេត្តកោះកុងហ្នឹង ហើយក្រោយបន្ទាប់មកទៀតបាន លេខាកងពល តាសឿង គាត់នៅហ្នឹងដែរ។ ដឹងប៉ុណ្ណឹង។

[១១:៤២:១៧]

**ស៖** បាទ លោកទទួលបន្ទុកក្នុងការពារឆ្នេរ លោកនិយាយផងដែរថា លោកទទួលបន្ទុកកោះកុង កោះស្ដេច ហើយនិងកោះមួយទៀត ហើយផ្នែកផ្សេងទៀតនោះស្ថិតនៅក្រោមឱវាទរបស់កងពលលេខ៣។ លោកក៏បាននិយាយផងដែរ ថាបើ -- លើកលែងតែខ្ញុំភ័ន្តច្រឡំទេ គឺថាលោកពុំមានទំនាក់ទំនងជាមួយកងពលទេ ក៏ប៉ុន្តែលោកមានទំនាក់ទំនងជាមួយកងវរសេនាធំនៃកងពលលេខ៣ ឬក៏កងពល១៦៤។ តើលោកអាចបញ្ជាក់បានដែរឬទេ អំពីតួនាទីរបស់លោក និងបេសកកម្មរបស់លោកក្នុងការការពារឆ្នេរសមុទ្រខ្មែរនេះ?

**ឆ៖** បាទ ខ្ញុំបានទាក់ទង -- គេមកទាក់ទងខ្ញុំ និងវរសេនាតូច កងពលលេខ៣ហ្នឹង គេគ្រាន់តែមកប្រាប់ថា បងឲ្យមកជួបនឹងបង ដើម្បីទំនាក់ទំនងសហការគ្នា កុំឲ្យមានអ្វីក្នុងការទាក់-- អ៎! ប៉ះពាល់គ្នា ២-៣ថ្ងៃ អ៊ីចឹងទៅយើងជួបគ្នាម្ដង ៗ ក្នុងខាងក្រោម។ ឯកងពលគេ គេអត់ដែលដែលមកជួបយើងទេ តែគេប្រាប់តាមរយៈវរសេនាធំ ឬក៏វរសេនាតូច ដែលមកចែកព្រំដែនគ្នាហ្នឹង កុំឲ្យការ មានការច្រឡំគ្នា ឬក៏មានការបាញ់គ្នាអី ក្នុងពេលទំនាក់ទំនងគ្នាឲ្យហើយអ៊ីចឹង។ ហ្នឹងគេមានការទំនាក់ទំនងមកខាងខ្ញុំអ៊ីចឹង ហើយឲ្យគេជួយការពារមើលកប៉ាល់ មើលអីគេ ដែលគេបើកល្បាតយប់ព្រលប់អ៊ីចឹងផង។ គឺទំនាក់ទំនងគ្នាប៉ុណ្ណឹងឯង។

[១១:៤៤:៤0]

**ស៖** តើលោកអាចប្រាប់បានទេ ថាមានមធ្យោបាយអ្វីខ្លះដែលលោកមាននោះ? ឧទាហរណ៍ ដូចជាលោក មានកប៉ាល់ លោកមានកាំភ្លើងធំ លោកមានវ៉ាដាសម្រាប់ចាប់ ឬក៏មានមូលដ្ឋានអ្វីខ្លះ ឬក៏មានការសាងសង់ជាកំពង់ផែ ឬយ៉ាងម៉េចសម្រាប់ឲ្យលោកការពារឆ្នេរនេះ? សម្រាប់បំពេញការងារប្រចាំថ្ងៃរបស់លោកនោះ? តើមានជាអ្វីខ្លះដែរ? មានជាមូលដ្ឋានយន្តហោះ ឬក៏អ្វីអីចឹងដែរទេ?

**ឆ៖** បាទ មិនទាន់មានមូលដ្ឋានយន្តហោះទេ ហើយក៏មិនទាន់មានកំពង់ផែអីត្រឹមត្រូវដែរ។ ឯកាំភ្លើងធំអាចដឹកយកទៅដាក់តាមកោះ ត្រឹម១០៥មីល្លីម៉ែត្រអី ដាក់នៅកោះកុង ធ្វើកន្លែងដាក់នៅកោះកុង ហើយកាំភ្លើងមួយចំនួនទៀតដាក់នៅកោះយ៉។ តែកាំភ្លើងពីដើមស្រេចហើយ អាហ្នឹងគឺដាក់រូបមន្តវាចាក់គ្រឹះវាជាប់ហ្នឹងស្រេច យើងគ្រាន់តែថែរក្សាការពារ និងការដែលរៀបចំ មិនទាន់រៀបចំអ្វីធំដុំទេ ហើយនិងយកកម្លាំងដាក់តាមកោះតូចៗខ្លះ ហើយនិងកោះណាដែលវែង យើងដាក់មួយកន្លែងមួយអនុសេនាធំទៅៗ យើងគ្រាន់តែដាក់តាមហ្នឹងទេ។ ឯការរៀបចំឲ្យមានឧបករណ៍សម្រាប់ទប់ទល់សត្រូវនោះ វាមិនទាន់មានគ្រប់គ្រាន់ទេ វ៉ាដាក៏មិនទាន់មានដែរ ក្នុងរយៈកំពុងគេរៀបចំមិនទាន់បាន។ អីចឹងយើងការពារក្នុងហ្នឹង ហើយយើងឆ្ការព្រៃតាមកោះអីទៅ កុំឲ្យវាមានមូស មានអីវាខាំ ដើម្បីឲ្យមានវាលមានអីខ្លះ។ ប៉ុណ្ណឹងឯង។

[១១:៤៦:៥៩]

**ស៖** តើលោកមាននាវាដែរឬទេ? ឬក៏នាវានេះសម្រាប់តែកងទ័ពជើងទឹកទេ? ហើយអ្នកជាអ្នកគ្រប់គ្រងលើកម្លាំងកងទ័ពជើងទឹកនេះ?

**ឆ៖** ឯកម្លាំងនាវាៗ បើមានតែកម្លាំងខាងកងពលលេខ៣ ទេ ដែលគេមាន ហើយតែគេមកចតនឹងកោះខាងខ្ញុំគ្រប់គ្រងហ្នឹង ការពារហ្នឹង ក៏ប៉ុន្តែគេឲ្យគ្រាន់តែ គេឲ្យជួយមើលថែរក្សា ជួយការពារគ្នា។ ប៉ុន្តែកប៉ាល់ ៗរបស់គេគ្រប់គ្រងខាងណោះ ប៉ុន្តែបើមកធ្វើការខាងខ្ញុំ ខ្ញុំជួយការពារគ្រប់គ្រង បាទ។

**ស៖** ឧទាហរណ៍ដូចជា បើសិនជាលោកឃើញកប៉ាល់របស់ថៃ តើលោកមានចេញបញ្ជាអ្វីទេសម្រាប់បញ្ជាក់អំពីវត្តមាននាវាថៃនៅក្នុងទឹកដីខ្មែរនេះ? ហើយលោកប្រាប់វត្តមានកប៉ាល់ហ្នឹងទៅអ្នកណាដែរ? លោករាយការណ៍ថាមានកប៉ាល់ចូលមកអីចឹង លោករាយការណ៍ទៅអ្នកណា?

**ឆ៖** បាទ កប៉ាល់ បើសិនជាកប៉ាល់របស់ថៃវាចូលចាប់ ឬក៏យើងមើលឃើញអី យើងប្រើតាមតេឡេ ប្រាប់តាមនាវារបស់កងពល ដែលគេមកសហការយើងនឹងទៅ ប្រាប់គេឲ្យគេទៅមើលទៅ ឬក៏

វាចូលជ្រៅ ឬក៏វានៅដីគេ ហ្នឹងយើងអាចប្រាប់គេតាមៗ តេអូ ដែលអាចនិយាយឆ្លើយឆ្លងគ្នាបាន។

**ស៖** ព័ត៌មានទាំងអស់នេះត្រូវបានប្រាប់ទៅដល់ សំ ឬក៏ប្រាប់ទៅកងពលលេខ៣ គឺ មាស មុត?

**ឆ៖** គេប្រាប់ទៅខាងកងពលគេទៅ ខ្ញុំប្រាប់ទៅខាង តាសឿង ខាងណេះទៅ ខ្ញុំប្រាប់គេពីរចំណែកទៅ គេៗប្រាប់ខាងណោះទៅ ខ្ញុំប្រាប់មកខាង តាសឿង ខ្ញុំនេះមក ដើម្បីឲ្យដឹងកិច្ចការងារបាទ។

**ស៖** ខ្ញុំសោកស្តាយ ខ្ញុំស្តាប់អត់យល់ ប្រហែលជាមានបញ្ហាបកប្រែ។ តើលោកធ្លាប់រាយ-ការណ៍ទៅកងពលលេខ៣ ឬក៏ផ្ញើសារទៅកងពលលេខ៣ ដើម្បីស្នើសុំជំនួយ ដើម្បីចាប់កប៉ាល់ចូលមកអីអ៊ីចឹង តើធ្លាប់ទេ?

[១១:៥០:១៧]

**ឆ៖** បាទ ខ្ញុំអត់ដែលរាយការណ៍ទៅកងពលលេខ៣ទេ ក៏ប៉ុន្តែអ្នកដែលកាន់កាប់កប៉ាល់ហ្នឹងប្រាប់ -- ខ្ញុំប្រាប់តាម អ្នកកប៉ាល់ហ្នឹង អ្នកបើកបរកប៉ាល់ហ្នឹង មួយភ្លែតគេប្រាប់តាមមេគេទៅកងពលលេខ៣ហើយ។ ហើយខ្ញុំរាយការណ៍ទៅខាងកងពលខ្ញុំណេះផ្សេង ទៅខាងតាសឿង ណេះផ្សេងនៅឯក្រោយឯណេះផ្សេង ដើម្បីឲ្យគាត់ដឹង។ ឯគាត់សហការគ្នាយ៉ាងណានោះ ខ្ញុំមិនបានដឹង។

**ស៖** កប៉ាល់ដែលលោករាយការណ៍ជូននោះ តើជាកប៉ាល់របស់កងវរសេនាធំ ឬក៏អង្គភាពយោធាណា? លោកមានឈ្មោះទេ? ឈ្មោះអង្គភាពយោធានោះ?

**ឆ៖** យោធាកងពលលេខ៣ ហ្នឹង ដែលមកសហការជាមួយខ្ញុំហ្នឹង ប៉ុន្តែវរសេនាធំលេខប៉ុន្មានទេ ខ្ញុំមិនបានចាំ។

**ស៖** ឯកសារមួយចំនួន ប្រហែលជាមានសារៈសំខាន់ គឺឯកសារលេខ D108/28.48, ERN ជាភាសាអង់គ្លេស 00233647 ទៅដល់ 48, ភាសាបារាំង 00623217 ទៅដល់ 18, ជាភាសាខ្មែរ 00000860។ នេះជាទូរលេខចុះថ្ងៃទី១៣ សីហា ឆ្នាំ៧៦ ដែលរាយការណ៍អំពីការជួបគ្នា រវាង តាសឿង, តាហុង ហើយនិងសមមិត្ត មុត។ តើលោកដឹងអំពីការជួបគ្នា រវាង តាសឿង និង មាស មុត ដែរឬទេ?

[១១:៥២:៤២]

**ឆ៖** បាទ អត់ដឹងដែរ។

**សៈ** ឯកសារមួយទៀត ដែលត្រូវបានបង្ហាញជូនដោយសហព្រះរាជអាជ្ញារួចហើយ គឺឯកសារលេខ E3/1037 ជាទូរលេខ ដែលមានលេខ ERN ដូចតទៅនេះ។ ជាភាសាខ្មែរ 00161790, ERN ជាភាសាអង់គ្លេស 00233645, ជាភាសាបារាំង 00710220។ ទូរលេខនេះ រាយការណ៍អំពីឧប្បត្តិហេតុជាមួយនឹងកប៉ាល់ខ្មាំង នៅជិតកោះកុង ហើយនិងអំពីការចាប់បាននូវនាវារបស់ថៃ។ ទូរលេខនេះមានចុះហត្ថលេខដោយ ម-០៩ កោះកុង ហើយផ្ញើជូន៨៩ ផ្ទាល់ ហើយនិងមានចម្លងជូនមន្ទីរឯកសារ។ មន្ទីរ០៩ នេះគឺមិនស្ថិតនៅក្រោមកងពលធំលេខ១ ទេ។ តើលោកដឹងទេថា មន្ទីរ០៩នេះ ស្ថិតនៅក្រោមកងពលធំលេខ៣ ឬក៏ស្ថិតនៅក្រោមខាងកងទ័ពជើងទឹក? តើមានមន្ទីរកងទ័ពជើងទឹកទេនៅកោះកុង?

**ឆៈ** អត់មានទេ កន្លែងកងពលលេខ១ អត់មាននៅកោះកុងទេ។ ឯកងពលលេខ៣ មិនដឹងជាទីបញ្ជាការគេនៅកន្លែងណា ខ្ញុំមិនដឹងលេខ ចំណុចគេដែរ។

[១១:៥៤:៥៣]

**សៈ** នៅកោះកុង តើមានរ៉ាដាដែរឬទេ? ឬក៏លោកធ្លាប់ទទួលព័ត៌មានពីរ៉ាដា ដែលដំឡើងនៅតាមឆ្នេរសមុទ្រដែរឬទេ?

**ឆៈ** បាទ ដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺមិនទាន់មានរ៉ាដាឆ្លុះមើលទេ មើលទៅតាម*អាសឹរ៉ែល*ឆ្លុះ។

**សៈ** ខ្ញុំមានឯកសារមួយទៀតដែលបង្ហាញជូនលោក។ ខ្ញុំសូមប្រគល់ឯកសារជាក្រដាសជូនសាក្សីលោកមន្ត្រីតុលាការ។ ឯកសារនេះមានលេខ E3/1007។ នេះគឺជាទូរលេខ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨។ ERN ជាភាសាខ្មែរ 00001111, ERN ជាភាសាអង់គ្លេស 00324834, ជាភាសាបារាំង 00811278។ ទូរលេខនេះ ត្រូវបានចុះហត្ថលេខាដោយឈ្មោះ រដ្ឋ។ តើ រដ្ឋ នេះជាលេខាតំបន់៣៧ហ្នឹងមែនទេ?

**ឆៈ** បាទ អង្គាល់បាត់ មុនដកគាត់ទៅក្រោយគេបង្អស់ តារដ្ឋ ហ្នឹងហើយ រស់ ហៅ រដ្ឋ ហ្នឹង។

[១១:៥៧:៤០]

**សៈ** ខ្ញុំគិតថា មានបញ្ហាបន្តិចបន្តួច ពាក់ព័ន្ធនឹងការបកប្រែឯកសារនេះជាភាសាបារាំង។ ឯកសារនេះត្រូវបានផ្ញើចេញនៅថ្ងៃទី១២ ខែមេសា ហើយជាភាសាបារាំង មានបញ្ហាបន្តិចបន្តួច។ ភាសាអង់គ្លេសគឺបកត្រូវ។ ដូច្នេះ ប្រហែលជាថ្ងៃទី១០ ខែមេសា រដ្ឋ បាននាំសំបុត្រ និងបញ្ញើមួយចំនួនទៅកាន់ឯកអគ្គរដ្ឋទូតថៃ។ ខ្ញុំសូមអាន "កាលពីថ្ងៃទី១០ ខ្ញុំបានយកសំបុត្រ និងមតិណែនាំបងជម្រាបជូនស្ថានទូតថៃ ហើយគេរីករាយនឹងផ្ញើទៅក្រសួងការបរទេសគេនូវសំបុត្រ និងពីការដែលយើងទៅជួប

គេ។ ពេលជួបគ្នា ថៃនៅតែលើករឿងដដែលៗថា មានកងទ័ពយើងរួមជាមួយកុម្មុយនីស្តថៃ ចូលវាយគេ។ គេថា គេបានរាយការណ៍ទៅក្រសួងការបរទេសគេហើយថា គ្មានកងទ័ពកម្ពុជារួមនឹងកុម្មុយនីស្តថៃទេ។ ក្រសួងការបរទេសគេជឿហើយ ក៏ប៉ុន្តែខាងយោធាបានរាយការណ៍មកវិញថា ប្រាកដជាមានការរួមដៃគ្នារវាងកងទ័ពកម្ពុជា និងកុម្មុយនីស្តថៃ”។

ហើយបន្ទាប់មកទៀត កថាខណ្ឌចុងក្រោយ គេនិយាយអំពីលក្ខខណ្ឌសហការគ្នារវាងខ្មែរ និងថៃ។ “ថៃគេឆ្លើយតបមកវិញថា តាម អ៊ិន តាំ ក្រសួងការបរទេស គេប្រាប់ថា ចេញទៅស្រុកបារាំងជាមួយគ្រួសារ ហើយគេបញ្ជាក់បន្ថែមទៀតថា រង់ចាំសំណូមពរកម្ពុជាក្នុងការដោះស្រាយព្រំដែនថៃកម្ពុជាឲ្យបានឆាប់រហ័ស ហើយគេសង្កត់ឲ្យយើងប្រគល់ប្រជាជន និងទ្រព្យសម្បត្តិ ដែលថាវាសព្វថ្ងៃនេះស្ថិតនៅក្នុងទឹកដីរបស់យើង”។ ខ្ញុំសូមបញ្ជាក់ថា ទូរលេខនេះត្រូវបានផ្ញើជូនអ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, មន្ទីរឯកសារ”។ លោកសាក្សីតើលោកមាននឹកឃើញអ្វីទេ អំពីព្រឹត្តិការណ៍បែបនេះ លោកដឹងថា មានជម្លោះរវាងថៃ ខ្មែរ ហើយនិងមានការចរចាគ្នារវាងកម្ពុជាថៃទេនៅពេលនោះ?

[១២:០០:០៨]

**ឆ៖** បាទ ខ្ញុំឃើញថា ឈ្មោះ រដ្ឋ នេះ មិនមែនជា រដ្ឋ តំបន់៣៧ ទេតាមមើល ព្រោះគាត់អត់ដែលទាក់ទងទៅរឿងកិច្ចការងារបរទេសអីយ៉ាងម៉េចផង។ ក្រែងតែ រដ្ឋ នៅក្នុងក្រសួងការបរទេសមិនដឹង ខ្ញុំមិនបានដឹងដែរ ប៉ុន្តែកន្លែងគាត់មិនមានការរាយការណ៍អ៊ីចឹងទេ។ ខ្ញុំចំណាំមើលគាត់មិនចេះ -- គាត់មិនមានការទំនាក់ទំនងអីជាមួយនឹងខាងការទូតផង។ តាមខ្ញុំដឹងមានប៉ុណ្ណឹងឯង ដែលឈ្មោះគ្រាន់តែថា ដឹងតែឈ្មោះនេះ រាយការណ៍អ៊ីចេះ ខ្ញុំដឹងថា មិនមែន រដ្ឋ លេខាតំបន់៣៧ ទេ។ រដ្ឋ ឈ្មោះណាទៀត ខ្ញុំមិនដឹងបាទ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា មានរឿងអ្វីកើតឡើងដែរ នៅពេលដែលមាននាវា ឬក៏កប៉ាល់វៀតណាម ឬក៏អ្នកនេសាទវៀតណាម ត្រូវបានចាប់ខ្លួន ឬក៏នៅពេលមានជនជាតិថៃត្រូវបានចាប់ខ្លួននោះ។ តើគេធ្វើអ្វីចំពោះអ្នកទាំងអស់នេះ? ហើយនិងកប៉ាល់ទាំងអស់នោះ?

[១២:០១:២៩]

**ឆ៖** បាទ ពេលដែលនុ៎ង ខ្ញុំដូចបានបញ្ជាក់ម្តងហើយ ពេលដែលចាប់បាន គឺយើងរាយការណ៍មកខាងកងពល មកទទួលយកនៅកំពង់សោម។ ក៏ប៉ុន្តែកន្លែងគាត់មិនមែននៅកំពង់សោមទេ ក៏ប៉ុន្តែផ្លូវចេញចូលកន្លែងហ្នឹងវាៗ មានកប៉ាល់របស់កងពលហ្នឹង អាចជិះបាន ឬក៏តាមនាំយកទាំងទូក ទាំង

មនុស្សទៅបាន។ ឧបមាថា ផ្លូវខាងកោះកុងក្នុងវាលំបាក អ៊ីចឹងពេលដែលចាប់បាន គឺយកទៅខាងនុំងឯង ដើម្បីឲ្យគេដោះស្រាយគ្នាខាងការងារទូតខាងហ្នឹង ឬក៏ការងារយ៉ាងម៉េច ខ្ញុំមិនសូវដឹងកិច្ចការងាររបស់គណៈទាក់ទងពីខាងណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណលោកចៅក្រម។ ឥឡូវនេះដល់ពេលសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សាសាក្សី នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០២:៥៩]

**លោក អេនគ្រូ អ៊ីន្ធូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុចបី ដែលចង់លើកឡើង ទី១ គឺចង់ បញ្ចប់ការដកស្រង់របស់ខ្ញុំ ដែលខ្ញុំព្យាយាមចង់បង្ហាញនៅពេលព្រឹកនេះ គឺខ្ញុំចង់និយាយអំពីការដែលយើងផ្តុះបញ្ចាំងទៅលើអ្វីមួយដែលធ្វើតាមវិធាន៣១។ ចំណុចទី២ របស់ខ្ញុំគឺ--

**ប្រធានអង្គជំនុំ៖**

យើងបានសម្រេចរួចហើយព្រឹកមិញ មិនឲ្យលោកនិយាយអ្វីទៀតទេ លើអ្វីដែលលោកបានមានបំណងលើកឡើងកាលពីព្រឹកមិញ។ អ៊ីចឹងបញ្ហាដែលលោកលើកឡើងព្រឹកមិញនេះ គឺមិនអាចនិយាយបានទៀតទេ។

**លោក អេនគ្រូ អ៊ីន្ធូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ចំណុចមួយទៀត គឺនិយាយអំពីការដកស្រង់ចេញនូវផ្នែកមួយចំនួនដោយយោងទៅលើឯកសារ ដែលបាននិយាយរួចមកហើយគឺឯកសារ E1/129/1។ ហើយសំណើទី៣ គឺ ខ្ញុំសូមជម្រាបថា កូនក្តីរបស់ខ្ញុំឈឺខ្នង ឈឺក្បាល ឈឺចង្កេះមិនអាចផ្តង់អារម្មណ៍បាន ហើយគាត់ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធី នៅពេលរសៀលនេះ ពីបន្ទប់ឃុំខ្លួនខាងក្រោម។ សូមលោកប្រធាន

មេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយយូរក្នុងបន្ទប់សវនាការ ដើម្បីតាមដានកិច្ចដំណើរការសវនាការបាន។

[១២:០៤:៤០]

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី លោក នួន ជា ផ្តល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា ស្ថិតនៅក្នុងបន្ទប់ដែលរៀបចំជាស្រេច នូវឧបករណ៍សោតទស្សន៍ សម្រាប់ឲ្យគាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក មាស វឿន យើងនឹងចាប់ផ្តើមសវនាការបន្តទៅទៀត។ ខ្ញុំបន្តសួរសំណួរលោកមួយចំនួនទៀត ស្តីអំពីអ្នកទោសដែលបានចាប់ខ្លួននៅលើសមុទ្រ។ កាលពីព្រឹកមិញនេះលោកឆ្លើយថា “អ្នកនេសាទថៃ ឬអ្នកដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវនាំទៅកំពង់សោម។ យើងបានដឹងហើយថាកំពង់សោម ស្ថិតនៅកន្លែងណាហើយ យើងដឹងទាំងអស់គ្នាហើយ ហើយនៅទីនោះ មានលោក មាស មុត ជាអ្នកមេដឹកនាំ”។ ខ្ញុំមានឯកសារថ្មីមួយទៀត គឺឯកសារ E3/928, ERN ជាភាសាខ្មែរ 00017026, ERN ជាភាសាបារាំង 00611668, ERN ជាភាសាអង់គ្លេស -- សូមអភ័យទោស ខ្ញុំអត់មានលេខ ERN ជាភាសាអង់គ្លេសទេ។ នៅក្នុងទូរលេខនេះ គឺមាននិយាយថា “ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៨ មានចំនួនជនជាតិវៀតណាមគឺ ១២០នាក់ ហើយមានទូក១០សេះ ដល់៣៧សេះ ចំនួន៥គ្រឿង អាវុធមួយចំនួន ក្នុងនោះមានអឹម៧៩ មួយដើម និងសម្ភារៈផ្សេងទៀតមួយចំនួនទៀត ត្រូវបានរឹបអូស។ កថាខណ្ឌទី២ “សៀម ដែលត្រូវដោះលែង មានការយឺតយ៉ាវ មិនបានតាមការកំណត់មូលហេតុមកពីមានការខុសឈ្មោះ អ្នកដែលមកទទួលខ្លះ តែខុសនេះតាមការពិនិត្យគឺ មិនមានខុសទាំងស្រុងទេ គឺខុសចុងឈ្មោះបន្តិចៗ ជាមូលដ្ឋាន ត្រូវ”។ ដូច្នេះ យើងឃើញហើយនៅក្នុងឯកសារនេះ គឺមានគម្រោងក្នុងការដោះលែងអ្នកដែលចាប់ខ្លួនបាន។ ខ្ញុំសូមបញ្ជាក់ថា របាយការណ៍ទូរលេខនេះ គឺចុះថ្ងៃទី០១ ខែមេសា ឆ្នាំ៧៨ ចុះហត្ថលេខាដោយឈ្មោះ នុត -- មុត (សូមទោស) ហើយ ចម្លងជូនអ៊ំ, អ៊ំនួន, បងវ៉ាន់ និងឯកសារ”។

[១៣:៣៤:៣៥]

លោក មាស វឿន តើលោកដឹងថា មានការចរចាគ្នាតាមផ្លូវការទូត ឬក៏ការចរចាគ្នាធម្មតា រវាងថៃ ហើយនិងខ្មែរទេ ដើម្បីឲ្យមានការដោះលែងអ្នកដែលចាប់ខ្លួនបាននោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ដល់កន្លែងកំពង់សោមហើយ។ ហ្នឹងកិច្ចការងាររបស់ខាងអ្នកទាក់ទងផ្សេង ខ្ញុំអត់បានដឹងរឿងយ៉ាងណានោះទេបាទ។

**ស៖** ដើម្បីឲ្យមានលក្ខណៈពេញលេញនៃឯកសារនេះ គឺថានៅក្នុងសំណុំរឿងមានអត្ថបទមួយចំនួន ដែលបានផ្សាយអំពីការចរចាតាមផ្លូវការទូតរវាងថៃនិងកម្ពុជា។ ឧទាហរណ៍ដូចជាឯកសារ D56-doc.098 ជាពិសេសគឺទំព័រដែលមានលេខ ERN S00008979។ ឯកសារនេះនិយាយអំពីទស្សនកិច្ចនៃគណៈប្រតិភូថៃនៅកម្ពុជា។ ហើយគណៈប្រតិភូនេះត្រូវបានទទួលស្វាគមន៍ដោយលោក អៀង សារី។ ឯកសារនេះ និយាយអំពីការចរចាដើម្បីឲ្យមានការដោះលែងអ្នកនេសាទថៃ។ នៅលើប្រធានបទដដែលនេះ យើងមានឯកសារលេខ E3/1275 ជាពិសេសទំព័រ ERN S00010313 និងជាចុងក្រោយមានអត្ថបទមួយទៀតដែលមាននៅលេខ D108/28.292 ដែលជាអត្ថបទរបស់ *ហ្វាអេសស្ទឺន អេកូណូមិក រីវីយូ* ឆ្នាំ៧៨, មានលេខ ERN ដូចតទៅនេះ។ ជាភាសាអង់គ្លេស S00008277, ERN ជាភាសាខ្មែរ S00965923 ទៅដល់ 25, ជាភាសាបារាំង S007693 -- សូមទោស 8339។

[១៣:៣៧:២២]

ខ្ញុំសូមបញ្ជាក់ថា ចំណងជើងនៃអត្ថបទនេះជាភាសាបារាំងគឺថា "ការប្រុងប្រយ័ត្នខ្ពស់ចំពោះទីក្រុងបាងកក និងការឃោសនារបស់ភ្នំពេញ"។ ឯកសារនេះនិយាយអំពីទស្សនកិច្ចរបស់លោក អៀង សារី នៅថៃ ហើយនិងការជួបជាមួយឧត្តមសេនីយ៍ ឃៀង សាក់ជូម៉ាណាន់។ អត្ថបទនេះចុះខែកក្កដា ឆ្នាំ១៩៧៨ គឺថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៨។

ឥឡូវនេះ ខ្ញុំចង់ត្រឡប់ទៅនិយាយអំពីទំនាក់ទំនងជាមួយនឹងភូមិភាគ ជាពិសេសគឺក្រោយពីការបាត់ខ្លួនរបស់លោក ជូ ជេត។ ក្រោយការបាត់ខ្លួនរបស់ ជូ ជេត ពីភូមិភាគនោះ គឺនៅសល់តែ សឿង ទេមែនទេដែលជាអ្នកដឹកនាំភូមិភាគ? ហើយនៅក្នុងសំណុំរឿង គឺយើងមានឯកសាររបាយការណ៍ជាច្រើនដែលផ្ញើដោយភូមិភាគបស្ចិម ដែលត្រូវបានហៅថា "ភូមិភាគ៤០១ ផ្ញើជូនអង្គការ"។ ឥឡូវនេះ ខ្ញុំចង់សង្កត់ធ្ងន់ទៅលើរបាយការណ៍មួយ ដែលមានលេខ E3/1094។ ខ្ញុំចង់ដឹងថា តើលោកទទួល បានសេចក្ដីណែនាំពីអាជ្ញាធរភូមិភាគដែរឬទេ ពាក់ព័ន្ធទៅនឹងយោធា ដែលមិនមានប្រវត្តិរូបល្អនោះ គឺមាន

ន័យថា យោធាដែលអាចមានទំនាក់ទំនងជាមួយនឹងអតីតយោធារបបចាស់ ឬក៏មន្ត្រីរបបចាស់ ឬក៏លោកទទួលបានការណែនាំ ពាក់ព័ន្ធទៅនឹងយោធាដែលមានបុព្វញាតិចិន ឬក៏អ្នកដែលមានជាប់ខ្សែអីវៀតណាមអីទេ?

[១៣:៣៩:៥២]

**ឆ៖** បាទ អត់មានទេ។

**ស៖** ឥឡូវនេះយើងនឹងពិនិត្យមើលរបាយការណ៍ដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ ដែលជារបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ១៩៧៨ នៃតំបន់៤០១ ផ្ញើជូនអង្គការ។ នៅទំព័រ៨ ជាភាសាបារាំង ERN 00593530 ខ្ញុំជឿថាឯកសារនេះត្រូវបានសហព្រះរាជអាជ្ញាលើកយកមកចោទសួររួចហើយ ពាក់ព័ន្ធទៅនឹងការបោសសម្អាតទៅលើជនជាតិវៀតណាម ភ្នាក់ងារ សេ.អ៊ី.អា ហើយនិងសមាសភាពមិនល្អ។

[១៣:៤០:០០]

"ទី១ យើងបានកម្ទេចវៀតណាម១០០នាក់ទាំងធំទាំងតូច ទាំងចាស់ទាំងក្មេង។ ទី២ យើងបានសម្លាប់មនុស្ស៦០នាក់ ដែលជាអ្នកមានឋានៈ ហើយនិងជាភ្នាក់ងារ សេ.អ៊ី.អា ពួកចក្រពត្តិអាមេរិកដែលបង្កប់ខ្លួននៅក្នុងអង្គភាព និងក្នុងសហករណ៍។ ៣) ក្នុងកងទ័ពតំបន់ យើងបានធ្វើការបោសសម្អាតពួកយុទ្ធជនចិន ដែលនៅក្នុងជួរកងទ័ព។ យោធាចិន៤០នាក់ត្រូវបានរក្សាទុកដើម្បីឲ្យធ្វើការបង្កបង្កើនផល។ ៤) វិធានការពាក់ព័ន្ធទៅនឹងយោធាវៀតណាម។ ៥) មនុស្ស១០នាក់មកពីកងអនុសេនាតូចអនុសេនាធំ និងសហករណ៍មួយចំនួនត្រូវបានបោសសម្អាតចោល។ អ្នកខ្លះគឺជាមនុស្សខ្ជិលច្រអូសអ្នកខ្លះជាអ្នកជំទាស់ ហើយអ្នកខ្លះជេរចំពោះប្រជាជន។ អ្នកខ្លះទៀតត្រូវបានប្រកាសដោយខ្លាំង ហើយអ្នកខ្លះមិនចង់ធ្វើការ។ វិធានការយើងចំពោះការប្រតិបត្តិការរបស់ខ្មាំងដែលបានលើកឡើងខាងលើនេះ៖ បន្តតាមដាន និងស្វែងរកខ្សែខ្មាំងគ្រប់ទាំងអស់ ដែលបានបង្កប់ស៊ីរូងផ្ទៃក្នុង។ ហើយនៅពេលដែលយើងចាប់បានហើយ យើងបន្តធ្វើការបោសសម្អាតនៅតាមមូលដ្ឋាន អង្គភាព មន្ទីរ និងនៅក្នុងក្រសួងនានាដើម្បីកម្ទេចឲ្យស្អាតបរិសុទ្ធ"។

[១៣:៤២:៣០]

លោក មាស វឿន របាយការណ៍ហ្នឹងចុះខែកក្កដា ឆ្នាំ១៩៧៨ គឺថានៅក្នុងរបាយាការណ៍មានន្ទូវការបញ្ជាក់ កាលបរិច្ឆេទច្បាស់លាស់ណាស់ ហើយលោកបានបញ្ជាក់ថា មនុស្សតែមួយគត់ដែលទទួល

បន្ទុកភូមិភាគនោះគឺ សឿង គឺប្រធានកងពលធំលេខ១។ តើលោកមានបានពិភាក្សាជាមួយ សឿង ពាក់ព័ន្ធទៅនឹងសេចក្តីណែនាំ ឬក៏គោលនយោបាយបែបនេះទេ ក្នុងការបោសសម្អាតខ្មាំងនេះ?

**ឆ៖** បាទ តាមខ្ញុំដឹងខ្លះអំពីផែនការហ្នឹង មានតែ គឺថា “ផែនការតែកម្ទេចខ្មាំងយួន” មាន។ ហើយនិង “សម្អាតក្រែងលោខ្មាំងយួនបង្កប់នៅក្នុងជួរអង្គភាព ស៊ីរ៉ូងបង្កប់ហ្នឹង” គឺមាន។ ឯការដែលគេកម្ទេចរួចហើយនោះ ខ្ញុំអត់បានដឹងដែរ។

**ស៖** នៅក្នុងឯកសារនេះ គេនិយាយអំពីកងទ័ពតំបន់។ ក្រៅពីកងពលលេខ១នោះ តើកងទ័ពតំបន់នោះមានអ្វីខ្លះទៅ?

**ឆ៖** បាទ ខ្ញុំអត់បានគ្រប់គ្រងក្នុងកងទ័ពតំបន់ផង គឺកងទ័ពតំបន់ និងកងទ័ពភាគដាច់គ្នាដោយឡែក គេនៅក្នុង ហើយខ្ញុំនៅក្រៅឯណោះ មិនបានដឹងដែរ។

[១៣:៤៤:២៧]

**ស៖** តើលោកមានចាំអំពីការណែនាំពាក់ព័ន្ធទៅនឹងគោលនយោបាយផ្សេងៗទៀត ឧទាហរណ៍ ដូចជាគោលនយោបាយពាក់ព័ន្ធទៅនឹងជនជាតិខ្មែរដែលប៉ុនប៉ងគេចខ្លួនទៅប្រទេសថៃជាដើម តើលោកមានធ្លាប់ឮអំពីគោលនយោបាយបែបហ្នឹងទេ? លោកបាននិយាយថា បើសិនជារត់អ៊ីចឹងមានការបញ្ជូនមកក្រោយវិញ។ តើនៅពេលដែលគេចាប់បាននោះ តើគេប្រគល់អ្នកដែលរត់គេចហ្នឹងមកឲ្យអ្នកណាវិញដែរ នៅខ្មែរយើងហ្នឹង?

**ឆ៖** បាទ បើរត់ទៅខាងខ្ញុំ ខ្ញុំចាប់បញ្ជូនមកឲ្យគេខាងក្រោយដែរ ខាងតំបន់ដែលទទួលខុសត្រូវ។ បើរត់ចំមុខសញ្ញា ខ្ញុំចាប់បញ្ជូនមកតំបន់។ តែក្រៅកន្លែងគេដទៃ ខ្ញុំមិនដឹងដែរ។

**ស៖** តើមានការណែនាំជាក់លាក់ពាក់ព័ន្ធទៅនឹងការខុសសីលធម៌ដែរឬទេ? ហើយចំពោះលោកនោះ តើលោកដឹងទេថាពាក្យថា “ខុសសីលធម៌” នេះមានន័យបែបណាដែរ?

**ឆ៖** បាទ ការដែលខុសសីលធម៌នោះ ចំពោះអ្នកដឹកនាំ ខូចជាមួយនឹងនារី ខូចជាមួយនឹងស្រីអាហ្នឹងគឺជាសីលធម៌មួយដែរ។ ហើយការដែលខុស ខូចខាតហ្នឹងហើយ ដែលនាំចំណុច គេហៅថា “សីលធម៌” ហ្នឹងគឺមិនឲ្យប៉ះពាល់ជាមួយនឹងស្រី ឬ/និង អ្វីដែលយើងប្រព្រឹត្តខុស ឬក៏សីលធម៌របស់ខ្លួនឯងដែរ តែសំខាន់រឿងស្រីដែលគេហាម ដូចថា កុំឲ្យមានស្រឡាញ់គ្នា ឬក៏ខុសអំពីវិន័យរបស់កងទ័ព។ អាហ្នឹងគឺថា ត្រង់ហ្នឹងហើយដែលគេសំខាន់កុំឲ្យមានការច្របូកច្របល់។ ប៉ុណ្ណឹងឯង។

[១៣:៤៦:៣៦]

**ស៖** តើលោកធ្លាប់ឮការនិយាយ ការណែនាំពាក់ព័ន្ធទៅនឹងការរៀបការដែលរៀបចំដោយអង្គការដែរទេ?

**ឆ៖** បាទ ការរៀបចំ អង្កាល់នោះក្នុងភាគហ្នឹងបានប្រជុំឲ្យរៀបការ គឺប្រុសឲ្យមានអាយុ២០ ស្រីដូចជា១៨ អីចេះ ខ្ញុំមិនចាំច្បាស់។ ក៏ប៉ុន្តែការរៀបការនោះ គេឲ្យរៀបការរបៀបប្តេជ្ញា ក៏ប៉ុន្តែមុននឹងរៀបការនោះ គឺចំណែកនៅខាងខ្ញុំដែលខ្ញុំឃើញ គេរៀបការឲ្យស្គាល់គ្នា គេឲ្យយុទ្ធជនទៅមើលនារី គេស្រឡាញ់អ្នកណា គេប្រាប់ឲ្យគេប្រាប់ឈ្មោះដល់យើងមក យើងនឹងសួរបញ្ជាក់គេដែរ។ ដើម្បីថាគេស្រឡាញ់អ្នកនេះ ឬឈ្មោះនេះ ឈ្មោះនោះអី បើគេត្រូវបានយើងរៀបឲ្យគេ។ បើគេមិនត្រូវទេ យើងអត់បាច់បង្ខំគេទេ អាហ្នឹងគឺថា -- ចំណែកខាងយោធាអីចឹង។ ហើយខ្ញុំបានរៀបអីចឹងមែន ខ្ញុំតាមដំណើរដែលគេប្រាប់ រៀបឲ្យក្រុមយោធា។ បើគេស្រឡាញ់គេប្រាប់ថា អ្នក! ខ្ញុំស្រឡាញ់នេះមួយនោះមួយអីចឹង រៀបឲ្យខ្ញុំ។ ខ្ញុំរៀបតាមរបៀបការ ប៉ុន្តែគ្មានភ្លេងគ្មានភ្លាត់អីទេ មានតែបាយទឹកអីហ្នឹង ហើយផ្កាបន្តិចបន្តួច គេឲ្យចាប់ដៃគ្នា ប្តេជ្ញាប៉ុណ្ណឹងឯង។

**ស៖** សូមអរគុណ។ ខ្ញុំអានសម្រង់នៃរបាយការណ៍នេះគឺឯកសារដដែលហ្នឹងគឺ E3/1094 ទំព័រ ៧ ដែលជាភាសាបារាំងគឺ ERN 00593529 “ការសម្លាប់ខ្លួនដោយការព្យួរ-ក”។ “នៅក្នុងតំបន់៣៧ ស្រុកត្រាំកក់ ឈ្មោះ អុល កាលពីមុននៅក្នុងអង្គភាព -- អ៎! កងចល័ត ក្រោយការរៀបការដោយអង្គការហើយ គេបញ្ជូនគាត់ទៅរស់នៅសហករណ៍។ ១៥ថ្ងៃក្រោយមក គឺថ្ងៃទី២៦ ខែកក្កដា ឆ្នាំ៧៨ ឈ្មោះនេះស្រាប់តែចងកសម្លាប់ខ្លួន។ យើងបានពិនិត្យរកមើលមូលហេតុហើយ តែមិនឃើញមានអ្វីដែលគួរឲ្យកត់សម្គាល់ក្នុងរយៈកាលកន្លងមកនេះទេ”។ តើលោកមានដឹងអំពីអ្នកដែលធ្វើអត្តឃាតសម្លាប់ខ្លួនដោយការចងកទេ?

[១៣:៤៩:៣២]

**ឆ៖** បាទ អត់ទេ។ មិនដែលទៅតាកែវនោះផង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅផ្នែកមួយផ្សេងទៀតនៃការសួរសំណួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងសកម្មភាពរបស់លោក នៅក្នុងភូមិភាគឧត្តរ។ ជាបឋម ខ្ញុំចង់ឲ្យលោកបញ្ជាក់ប្រាប់ខ្ញុំថា តើលោកដឹងអំពីប្រវត្តិរបស់តំបន់មួយចំនួន ដែលបង្កើតបានទៅជាភូមិភាគឧត្តរបានដែរឬទេ? ខ្ញុំដឹងថា ភូមិភាគឧត្តរនេះ មានតំបន់ពីរ គឺតំបន់១០៦ គឺថាពាក់ព័ន្ធទៅនឹងតំបន់ព្រៃ -- ព្រះវិហារ ហើយ១០៣ គឺសៀមរាប ឬឧត្តរមានជ័យ។ តើលោកដឹងទេថា តំបន់ទាំងអស់នេះ មួយផ្នែកនេះ កាលពីមុនគឺស្ថិតនៅក្រោមការគ្រប់

គ្រងរបស់បុគ្គលម្នាក់ឈ្មោះថា កុយ ធួន តើលោកដឹងទេ?

**ឆ៖** បាទ អត់ដឹងផង។

**ស៖** ចុះលោកធ្លាប់ឮគេនិយាយអំពីឈ្មោះ កុយ ធួន ហៅ ឃួន ហៅ ធុច ដែរឬទេ? គាត់ជាអតីតលេខាតំបន់ឧត្តរ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លោកធ្លាប់ឮឈ្មោះគាត់នេះទេ?

**ឆ៖** បាទ ខ្ញុំឮឈ្មោះដែរ ក៏ប៉ុន្តែនៅខាងឧត្តរ ដូចគ្មានទេ បើនៅខាងបូព៌ា ឮគេ កុយ ធួន នៅខាងបូព៌ា។ ហើយនៅខាងបូព៌ានោះទេ នៅខាងឧត្តរអត់មានឈ្មោះ កុយ ធួន នៅខាងនុ៎ងផង។

**ស៖** តើលោកមានធ្លាប់ឮថា គេចាប់ខ្លួន កុយ ធួន ទេ?

**ឆ៖** បាទ ឮតើ។

**ស៖** តើលោកដឹងទេ កុយ ធួន គាត់បានឆ្លើយសារភាពអ្វីទេ នៅពេលគេចាប់ខ្លួនគាត់នោះ?

**ឆ៖** អត់ដឹងទេ។

[១៣:៥២:៤០]

**ស៖** សម្រាប់ប្រតិចារឹកសវនាការ ខ្ញុំសូមប្រាប់ ជម្រាប កុយ ធួន ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅ ស-២១ បន្ទាប់មកគាត់បានឆ្លើយសារភាព ឧទាហរណ៍ ដូចជានៅក្នុងឯកសារ D108/24។ ហើយនៅក្នុងឯកសារនេះ គាត់បានឆ្លើយដាក់បុគ្គលមួយចំនួន ដែលរស់នៅក្នុងតំបន់១០៦។ តើលោកមានធ្លាប់ស្តាប់ឮការបោសសម្អាតនៅក្នុងតំបន់១០៦ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានឮទេ។ ខ្ញុំដឹងតែតំបន់១០៣ទេ។ កាលនោះ សៀមរាប មិនដឹងជាតំបន់ប៉ុន្មាន ហើយ កំពង់ធំ ដឹងតំបន់ប៉ុន្មាន ខ្ញុំដឹងតំបន់ព្រះវិហារ ដឹងតែ១០៣។ សៀមរាប អត់ដឹង គេដាក់តំបន់ប៉ុន្មាន អត់ដឹង។

[១៣:៥៣:៤៤]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាត។ ខ្ញុំសូមលើកឡើង ចៅក្រម ហាក់ដូចជាលើកឡើងអំពីខ្លឹមសារនៃចម្លើយសារភាព។ សាក្សីទីនេះ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា ផ្នែកនៅក្នុងចម្លើយរបស់គាត់គឺបង្ហាញអំពីរបៀបមធ្យោបាយដែលគាត់ទៅដល់ ស-២១ ដែលនៅក្នុងចម្លើយដែលបានលើកឡើងអម្បាញ់មិញនេះ។ ចៅក្រម ឡាវែន៍ នៅពេលនេះ គឺលើកឡើងផ្តល់យោបល់ ឲ្យផ្តល់យោបល់ទៅលើខ្លឹមសារនៃចម្លើយសារភាព។ ដូច្នេះហើយ វាហាក់ដូចជាស្តង់ដា យើងអនុវត្តពីរនៅទីនេះ។ ខ្ញុំមិនដឹងថា

វិធានហ្នឹងយ៉ាងម៉េចទេ ក៏ប៉ុន្តែខ្ញុំហាក់ដូចជាយល់ឃើញថាដូច្នេះ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំសូមបញ្ជាក់ផងដែរលោកប្រធាន។ សូមអរគុណ។ សួស្តីអស់លោក លោកស្រី ខ្ញុំគាំទ្រការលើកឡើងរបស់មេធាវីក្តីនេះ ដើម្បីឲ្យមាននៅក្នុងប្រតិចារឹក។

[១៣:៥៤:៤៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

យើងនឹងបន្តទៅទៀត ខ្ញុំកត់សម្គាល់ការអន្តរាគមន៍របស់អស់លោក គឺខ្ញុំមិនបានដកយកឯកសារព័ត៌មានចេញពីឯកសារចម្លើយសារភាពទេ។ ខ្ញុំគ្រាន់តែប្រាប់ពីឈ្មោះមនុស្សមួយចំនួន ដែលមានឆ្លើយដាក់នៅក្នុងឯកសារនោះ។ ហើយចង់ដឹងថា តើគាត់មានមុខងារអ្វីខ្លះ? ហើយគេចាប់ខ្លួនគាត់យ៉ាងម៉េចខ្លះនៅតំបន់នោះ ហើយបញ្ជូនទៅ ស-២១ យ៉ាងម៉េចខ្លះនោះ? ហើយខ្ញុំដឹងថាតើគាត់ដឹងអ្នកទាំងអស់ហ្នឹងដែរឬទេ? តាផល ហៅ សុត លេខាតំបន់១០៦ តើលោកដែលឮគេហៅឈ្មោះថា តាប៉ាល់ ហៅ សុត លេខាតំបន់១០៦ ដែលចម្លើយសារភាពនោះមាននៅក្នុងចម្លើយ នៅក្នុងឯកសារ D306.1.91 (ស៊ីក)។ ប្រសិនបើលោកមិនដឹងទេ លោកឆ្លើយថាមិនដឹងទៅ ខ្ញុំមិនចង់ឲ្យលោកឆ្លើយនូវអ្វីដែលលោកមិនដឹងនោះទេ បើថាមិនដឹងប្រាប់ថាមិនដឹង។

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកធ្លាប់ឮ នឹម នុន ហៅ ហួន លេខាស្រុកស្វាទ្រនិគមដែរ? ប្រាក់ សំ ហៅ បាំង, ទុប សាគន្ធ ហៅ សាន់ សមាជិកគណៈពាណិជ្ជកម្មតំបន់១០៦។ យ៉ង់ ពៅ ប្រធានសន្តិសុខតំបន់១០៦។ នៅ ឆាន់ ហៅ អ៊ីន លេខាកងពល១០៣។ អ្នកទាំងអស់នេះគឺមានឈ្មោះ នៅក្នុងបញ្ជីកែប្រែរបស់អ្នកទោស ស-២១ តើលោកធ្លាប់ឮឈ្មោះទាំងអស់នេះទេ?

[១៣:៥៧:១៤]

**ឆ៖** បាទ អត់ឮទេ។

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថា លោកមិនបានជួប ចាន់ សំ ហៅ កង ចាប ហៅ សែ នោះទេ។ ទោះបីជាមិនបានជួបគាត់ តើលោកមានធ្លាប់ជួបអ្នកណាម្នាក់ដែលនិយាយអំពីឈ្មោះ សែ នេះទេ នៅពេលដែលគាត់កាន់តំណែងនៅភូមិភាគឧត្តរនោះ។ តើលោកដឹងទេថា សែ ឬក៏ កង ចាប នេះគាត់មានទំនាក់ទំនងអ្វីខ្លះជាមួយ តាម៉ុក ឬក៏ជាមួយនឹង កែ ពក?

**ឆ៖** បាទ ខ្ញុំឮតែឈ្មោះទេ តែការទំនាក់ទំនងរបស់គាត់យ៉ាងណានោះ ហើយការដែលជួបយ៉ាងណានោះ ខ្ញុំមិនដែលបានជួបទេ ឮតែឈ្មោះ។

[១៣:៥៨:២១]

**ស៖** កែ ពក ជាលេខានៃតំបន់ណាដែរ?

**ឆ៖** បាទ ខ្ញុំដឹងថា ពេលដែលវត់យួនហើយ ដឹងថា កែ ពក ខ្ញុំដឹងតាមរយៈកងនារីដែលយួនវ៉ៃចូលស្រុកខ្មែរហើយទេ ដឹងថា កែ ពក នៅកំពង់ធំ។

**ស៖** ខ្ញុំសូមបញ្ជាក់ថា នៅក្នុងសំណុំរឿងយើងមានទូរលេខមួយ ដែលមានលេខ E3/239 ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ ចុះហត្ថលេខាដោយសមមិត្ត ពក ហើយគាត់ឆ្លើយថា "គាត់បានផ្តល់មតិណែនាំទៅដល់បង សែ រួចហើយ។ ជាពិសេសគឺពាក់ព័ន្ធទៅនឹងស្រុកអំពិល ហើយការរាយការណ៍នេះគឺក្រោយពីមានឧប្បត្តិហេតុមួយកើតឡើងនៅក្នុងស្រុកនេះ ពីព្រោះថាស្រុកនេះស្ថិតនៅក្នុងភូមិភាគស្រុកឧត្តរ -- តំបន់ឧត្តរមានជ័យ ហើយមានការបោះគ្រាប់បែកមកលើតំបន់ មន្ទីររបស់តំបន់"។ តើលោកមិនដឹងទេឬ ថាមានហេតុការណ៍បោកគ្រាប់បែកនេះទៅលើមន្ទីរតំបន់នោះ?

[១៣:៥៩:៥៨]

**ឆ៖** មិនបានដឹងទេ ខ្ញុំ។

**ស៖** តើលោកមានដឹងទេថា លោក កែ ពក បានធ្វើការបោសសម្អាតនៅក្នុងតំបន់មួយចំនួននៃភូមិភាគឧត្តរនោះ?

**ឆ៖** បាទ ខ្ញុំដូចខ្ញុំបញ្ជាក់អ៊ីចឹង ដល់ពេលយួនវ៉ៃចូលស្រុកខ្មែរ បានដឹងថា កែ ពក ផ្តាំតាមនារីដែលគាត់រត់មកពីកំពង់ធំមកព្រះវិហារ។ ឯផែនការគាត់យ៉ាងណានោះ ខ្ញុំមិនបានដឹងទេហ្នឹង ពីមុនមកខ្ញុំមិនបានដឹង កែ ពក នៅកំពង់ធំ អីណានៅហ្នឹងផង ខ្ញុំមិនដឹងទេ។

**ស៖** តើមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលលោកបានជួប ឬក៏លោកបានទាក់ទងមានធ្លាប់និយាយប្រាប់លោកអំពី កែ ពក ដែរឬទេ? ហើយមានការនិយាយអំពីការបោសសម្អាតដែលបានធ្វើនៅក្នុងភូមិភាគឧត្តរដែរឬទេ?

**ឆ៖** អត់ គាត់មិនបានប្រាប់។

[១៤:០១:២៩]

**ស៖** ខ្ញុំសូមបញ្ជាក់ថា នៅក្នុងសំណុំរឿង យើងមានទូរលេខជាច្រើន ដែលផ្ញើដោយសមមិត្ត

សែ ជូនអង្គការ ជាពិសេសគឺមន្ទីរ៨៧០។ ហើយទូរលេខទាំងអស់នេះ គឺផ្ញើទៅអ្នកទទួលមួយចំនួនជាពិសេសគឺផ្ញើជូនអ៊ំ ដែលយើងអាចសន្និតបានជា ប៉ុល ពត, នួន ជា, បងវ៉ាន់, ហើយជួនកាលទៅក៏មាន បងវន, បងខៀវ, មន្ទីរ និងឯកសារ។ ស្ទើរតែទាំងស្រុងនៃទូរលេខនេះ គឺមានការនិយាយអំពីការបោសសម្អាត និងការធ្វើឱ្យស្អាត។ លោកមិនដឹងអ្វីសោះនៅពេលដែលលោកទៅភូមិភាគឧត្តរនោះ? លោក កែ ពក មិនដែលនិយាយអ្វីប្រាប់លោក ហើយលោកក៏មិនដែលដឹងថាមានអ្វីកើតឡើងនៅភូមិភាគឧត្តរដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំទៅព្រះវិហារមិនបានជួប មិនបានចូលកំពង់ធំទេ ប៉ុន្តែខ្ញុំទៅព្រះវិហារមិនបានជួបអ្នកណាទេ ជួបៗតែអ្នកដឹកនាំកន្លែងនុំងតែម្នាក់ទេ។ ឯតំណាងភូមិភាគ ខ្ញុំមិនដឹងថាព្រះវិហារហ្នឹងនៅក្រោមភូមិភាគណាផង ខ្ញុំដឹងថាតំបន់ស្វយ័តដែលខ្ញុំបានបញ្ជាក់រួចហើយ។ ហើយខ្ញុំទៅហ្នឹងគឺជួបតែ ខឹម មួយទេ ឯរឿងភូមិភាគអីយ៉ាងណានោះ ជាកិច្ចការរបស់ភូមិភាគ ខ្ញុំមិនបានដឹងទេ។ សំដៅកិច្ចការភារកិច្ចរបស់ខ្ញុំ គឺតំបន់តែព្រះវិហារតែមួយទេ។

[១៤:០៥:០៣]

**ស៖** តាខឹម តើគាត់ជាអនុរបស់អ្នកណាដែរ? តើ តាខឹម រាយការណ៍ជូនអ្នកណា?

**ឆ៖** បាទ ខ្ញុំដឹងថា តាខឹម ដែលជាចុងបង្អស់។ ប៉ុន្តែមុនដំបូងប្រហែលជា តាហង្ស, តាហង្ស ខ្ញុំទៅអត់ទាន់ទៀត មិនដឹងពីប៉ុន្មានមក។ តាហង្សៗ ខ្ញុំទៅអត់ទាន់ គាត់ស្លាប់ទៅ ប្រហែលជាគេបាញ់គាត់ ឬក៏យ៉ាងណា ខ្ញុំភ្លេចកាលណោះ។ ហើយបានតមកខ្ញុំទៅជំនាន់ តាខឹម ហ្នឹងដែលជាចុងក្រោយហើយ តាខឹម អត់នៅមន្ទីរទន្លាប់ទេ គាត់ទទួលតំបន់ ក៏ប៉ុន្តែឃើញតែម្នាក់ឯងទេ។ ហើយឈ្មោះ បងផែន មួយទៀត ជាអនុតំបន់ហ្នឹងដែរ ជាចុងក្រោយដែរ គេដកគាត់ចេញមកនៅផ្ទះ ខ្ញុំជួបគាត់នៅផ្ទះ ហើយក៏សួរសុខទុក្ខគាត់។ គាត់នៅហ្នឹងផ្ទះហ្នឹងទៅ ហើយគាត់មានការរស់នៅក្នុងពេលដែលយួនវ៉ៃហ្នឹង គាត់រស់នៅទេ។ ហើយដល់អ៊ីចឹងរឿងភូមិភាគខាងឧត្តរទាំងអស់ ប៉ុន្មាននោះខ្ញុំអត់ដឹងកិច្ចការទេ ពីព្រោះតំបន់ហ្នឹងជាតំបន់ ដូចខ្ញុំបញ្ជាក់ថាតំបន់ស្វយ័ត ហើយគេប្រាប់ថាខ្ញុំទៅពីនេះគឺមានភារកិច្ចតែ ១០៣ តែប៉ុណ្ណឹង។

**ស៖** សម្រាប់ជាប្រតិចារឹកសវនាការ ខ្ញុំសូមបញ្ជាក់ថា ទូរលេខផ្ញើដោយ កង ចាប ជូនមន្ទីរ ៨៧០នោះមានដូចតទៅនេះ គឺមានលេខ E3/1091 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារមួយទៀត គឺ E3/1144 ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារ E3/800 -- សូមទោស គឺ 8498

ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៧។ ឯកសារ E3/918 ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨។ ឯកសារ E3/987 ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨។ E3/1077 ចុះថ្ងៃទី -- ចុះខែមេសា ឆ្នាំ១៩៧៨ ហើយនិងឯកសារមួយទៀត គឺ E3/1209។

[១៤:០៧:១៥]

លោកបានឆ្លើយថា "តំបន់នៃភូមិភាគឧត្តរ គឺជាតំបន់ស្វយ័ត"។ តើលោក នៅពេលដែលលោកឆ្លើយបែបនេះលោកចង់មានន័យថាម៉េចដែរ តំបន់ស្វយ័តហ្នឹង?

**ឆ៖** បាទ តំបន់ស្វយ័តហ្នឹង ខ្ញុំបានបញ្ជាក់ហើយថា តំបន់របស់ការចេញចូលរបស់ ខៀវ សំផន និងតាអ៊ំ លោក នួន ជា។ ប៉ុន្តែពេលដែលខ្ញុំទៅហ្នឹង គាត់មិនបានចេញចូលទេ មិនបានឃើញគាត់ចេញចូលទេ ពីព្រោះខ្ញុំទៅបានពេលវេលាខ្លី បានតែ៤ខែប៉ុណ្ណឹង។

**សៈ** ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ លោកឆ្លើយថា លោកបានទទួលទូរលេខមួយពីលោក ខៀវ សំផន។ តើលោកចាំទេថា លោកទទួលទូរលេខពី ខៀវ សំផន នេះនៅពេលណាដែរ? លោកចាំកាលបរិច្ឆេទទេ គឺនៅពេលដែលលោកនៅភូមិភាគបស្ចិម ឬក៏លោកនៅតំបន់ព្រះវិហារ?

[១៤:០៨:៤៨]

**ឆ៖** ខ្ញុំមិនបានឆ្លើយទៀតទេ ខ្ញុំឆ្លើយបានពីមុនរួចហើយ។

**សៈ** លោកសាក្សី បើសិនជាលោកបានជួបលោក ខៀវ សំផន ហើយបើសិនជាលោកបានពិភាក្សាអំពីស្ថានភាពនៅភូមិភាគឧត្តរនោះ តើលោកអាចបញ្ជាក់បានទេថា គាត់និយាយអំពីអ្វី? លោកនិយាយអំពីអ្វីខ្លះដោយពិតប្រាកដតែម្តងជាមួយគាត់?

**ឆ៖** ខ្ញុំមិនបាននិយាយអ្វីជាមួយគាត់ទេ។ និយាយពីមុន ខ្ញុំនិយាយតែពីរឿងក្រុមគ្រួសាររបស់គាត់រួចហើយ ដូចខ្ញុំបញ្ជាក់ពីថ្ងៃមុននោះ។ ដូច្នេះ ខ្ញុំមិនបានរៀបរាប់អ្វីទៀតទេ។ សូមអស់។

[១៤:១០:០០]

**សៈ** លោកសាក្សី ខ្ញុំគិតថាមានបញ្ហាបកប្រែហើយ។ ខ្ញុំៗមិនបានសួរលោកៗថាតើលោកនិយាយអ្វីទៅ ខៀវ សំផន នោះទេ។ ខ្ញុំសួរថាតើ ខៀវ សំផន និយាយអ្វីខ្លះមកៗដោយផ្ទាល់មកលោក ឬក៏តាមរយៈទូរលេខ? តើ ខៀវ សំផន និយាយអ្វីខ្លះមកកាន់លោក? ហើយគាត់ទាក់ទាញចំណាប់អារម្មណ៍លោកនោះទៅលើអ្វីខ្លះ? តើគាត់បានផ្តល់សេចក្តីណែនាំជាក់លាក់ណាដែរឬទេ? ហើយបើសិនជាមាននោះសេចក្តីណែនាំអ្វីខ្លះ?

**ឆ៖** គាត់មិនបាននិយាយអីមកទល់មាត់ជាមួយខ្ញុំទេ។ គាត់បានតែសរសេរសារទូរលេខឲ្យមើលម្ដាយ មើលពុក មើលបងគាត់។ ដូចខ្ញុំបានជម្រាប់មុនអ៊ីចឹង។ ឯកិច្ចការអ្វីទៅទៀត គាត់មិនបានសរសេរ គាត់មិនបានបញ្ជាក់ហេតុផលឲ្យខ្ញុំបានច្បាស់ទេ។ នេះ សូមបញ្ជាក់មានប៉ុណ្ណឹង។

[១៤:១១:១៤]

**សះ** ហើយនៅពេលដែលគាត់និយាយអំពីគ្រួសាររបស់គាត់នោះ តើគាត់មានផ្ដល់ការចង្អុលបង្ហាញជាក់លាក់ណាទេ ទាក់ទងទៅនឹងបុគ្គលដែលត្រូវ ដែលគាត់ស្វែងរកនោះ?

**ឆ៖** គាត់ចង្អុលប្រាប់ថា បងគាត់ គាត់មិនបានប្រាប់ឈ្មោះទេ គាត់ថា មានក្រុមគ្រួសារគាត់ម្ដាយឪពុកគាត់ចាស់ សូមគាត់មើលថែ អំ! សូមឲ្យមើលថែគាត់ផង តើគាត់នៅកន្លែងណា គាត់សុខទុកយ៉ាងម៉េច គាត់បានបញ្ជាក់ថាខ្លីៗប៉ុណ្ណឹង។

**សះ** លោកអាចពិពណ៌នាអំពីស្ថានភាព ដែលលោកបានជួបគាត់ ពេលដែលលោកទៅដល់ព្រះវិហារ។ តើលោកបានឃើញថាអ្នកនៅនោះៗសប្បាយចិត្ត ហើយមានចំណីអាហារហូបចុកគ្រប់គ្រាន់ដែលមិនមានការភ័យខ្លាចអ្វីទេ? តើលោកយល់ឃើញថាមនុស្សដែលរស់នៅទីនោះមានបញ្ហា ហើយបើមានបញ្ហាៗអ្វីដែរ?

**ឆ៖** បាទ មនុស្សដែលរស់នៅក្នុងស្រុករៀង មុនដំបូងខ្ញុំទៅដល់ស្រុករៀងមុនគេ ហើយក្នុងស្រុករៀងហ្នឹងមានគេកំពុង -- ជំនាន់ តាខឹម ហ្នឹង គាត់ -- គេ -- ខ្ញុំមិនចោទ តាខឹម ទេ ក៏ប៉ុន្តែនៅក្នុងប្រជាជនស្រុករៀង និងកំពុងតែភ័យខ្លាច កំពុងតែគេចាប់។ ចាប់ពេលយប់ក៏ចាប់ ហើយទៅដល់ស្រុកផែបទៀត។ ដូច្នេះប្រជាជនកំពុងតែភ័យ ខ្លាច ហើយខ្ញុំទៅដល់ហ្នឹងមានប្រជាជនគេមកពីផែប មកប្រាប់ខ្ញុំថា "ខ្ញុំដេកអត់លក់ទេ បងអើយគេចាប់។ តើគេចាប់ម៉េចខ្លះ? ជួនកាលមានឃើញឡានហ្ស៊ីបទៅដល់ឯនុ៎ង"។ ហើយដូចយប់ជ្រៅអ៊ីចឹងទៅ មានពេទ្យពីផែបមក រត់មកប្រាប់ទាំងយប់។ ហើយបន្តិចនៅផ្ទា មកប្រាប់ ខ្ញុំថា "មិនបាច់ភ័យទេ ឈប់ភ័យទៅ ថាខ្ញុំមកថ្មីនេះ គឺមិនបាច់ឲ្យភ័យទេ ហើយអ្នកណាចាប់ចងអីយ៉ាងម៉េចឲ្យដឹងដំណឹងដល់ខ្ញុំ"។ ហើយបន្តិចពីជាំក្សាន្តមកទៀត គឺថាប្រជាជនខ្លាចមែនទែន "សួរថាគេចាប់នៅណា? ចាប់យកទៅទុកឯណា? យកទៅដាក់ឯណា?" ពេលនុ៎ងគាត់ថា " អឺ!មិនដឹងជាយកទៅណាទេ ខ្ញុំចេះតែខ្លាចចេះតែភ័យ"។

[១៤:១៤:១២]

ហើយអង្កាល់ណោះ គេប្រើពាក្យ "អង្គការ" ឈ្មោះហៅថា "អង្គការៗ" "អ៊ូ! បានអង្គការមកថ្មី

អ៊ីចឹង ខ្ញុំកក់ក្ដៅហើយ ខ្ញុំលែងភ័យហើយ ខ្ញុំលែងព្រួយហើយ។ ខ្ញុំថាកុំព្រួយ”។ គេហៅខ្ញុំអង្គការ។ ហើយខ្ញុំទៅថ្មី ខ្ញុំដឹងថាភូមិសាស្ត្រខ្ញុំអត់ក្ដាប់បានផងអីផង។ ហើយការចាប់ គឺចាប់មែន។ ដល់ពេលៗចាប់ចងអ៊ីចឹង ខ្ញុំបានរាយការណ៍ខ្លះសារទូរលេខហ្នឹង ប្រាប់មកលោក ខៀវ សំផន ក៏ប៉ុន្តែគាត់បានទទួល មិនបានទទួលខ្ញុំក៏អត់បានដឹងដែរ។ គាត់អត់បានឆ្លើយតបវិញ ព្រោះសភាពការណ៍តាមព្រំដែនហ្នឹង វាដូចថាវាអត់ស្រួល។ ដល់អ៊ីចឹងទៅ ខ្ញុំថា “ឈប់ភ័យព្រួយអី ខ្ញុំមកអ៊ីចេះហើយ អត់ឲ្យអ្នកណាធ្វើបាបអីបានទេ”។ ហ្នឹងរឿងមួយ។

[១៤:១៥:០៥]

រឿងពីរទៀត ប្រជាជនដែលត្រូវខ្វះខាតស្បៀងអាហារ ភ្លួយមុង។ ការពិតគឺខ្ញុំទៅដល់ឃ្លាំងភួយមុង គឺគរនៅពេញឃ្លាំងទាំងអស់។ ហើយអាក្រោម កណ្ដៀរស៊ីអស់ អត់មានឲ្យគាត់ស្លៀកពាក់ នៅកន្លែងនុំងកន្លែងរងារទៀត ត្រជាក់ទៀត។ អាហ្នឹងខាងជីវភាព។ ដូច្នេះ ជីវភាពគាត់ខ្វះខាតមិនគ្រប់គ្រាន់ទេ។ ហើយខ្ញុំទៅរៀបរាប់បន្តិចចុះ វែង-- ទៅមើលអំបិលមើល កន្លែងអំបិលកន្លែងអី គាត់ដាក់កណ្ដាលវាលចោលទាំងអស់ អត់ឲ្យហៅប្រជាជន អត់ឲ្យប្រជាជនមកយកហូបទេ។ អ៊ីចឹងបានន័យថាជីវភាពរស់នៅរបស់គាត់ អត់បានគ្រប់គ្រាន់ទេ ហ្នឹងមួយ។ ហើយខ្ញុំទៅដល់ជាំក្សាន្តទៀត ហ្នឹងគេហៅម្លូព្រៃអីណាអីណី ជិតជើងភ្នំឯណោះ ឃើញធ្វើសហករណ៍មួយទៀត ធ្វើសុទ្ធតែក្លួច ហ្នឹងខ្ញុំរៀបរាប់ប្រាប់បន្តិចចុះ។ នេះដែលខ្ញុំផ្ទាល់ហើយ ដែលខ្ញុំឃើញ។

[១៤:១៦:១៧]

ហើយទៅដល់ដូនទន់ គេហៅ ដូនទន់ ហ្នឹងគេហៅនែ៎ ដំណាក់ត្រាច ត្រង់ហ្នឹងឃើញគេ កន្លែងគេថា គេចាប់ប្រជាជនត្រង់ហ្នឹង ហើយខ្ញុំទៅប្រជុំប្រជាជនត្រង់មួយកន្លែងទៀត ប្រាប់កុំឲ្យគាត់ភ័យ។ អ៊ីចឹងបានន័យថា ខ្ញុំបានប្រាប់ប្រជាជនក្នុងការដែលគាត់ភ័យខ្លាច ពីរឿងចាប់នោះ។ ក្រោយខ្ញុំទៅអត់មានអ្នកណាចាប់ទៀតទេ មានតែរួច លែងច្រើន។ ហ្នឹងនែ៎អំពីប្រជាជនហើយ មើលបងម្ដាយឪពុកគាត់ ម្ដាយឪពុកលោក ខៀវ សំផន ខ្ញុំទៅដល់ផ្ទះគាត់ ផ្ទះគាត់ៗក៏គ្មានអ្នកណាមករកដែរ កាលនោះគេប្រមូលប្រជាជនដាក់សហករណ៍ ហើយគាត់ចាស់ហ្នឹងក៏នៅពីរនាក់ប្ដីប្រពន្ធគាត់។ ហើយកូនគាត់ក៏បែកគ្នាទៅឯណាសៀមរាបទាំង -- ដូច្នេះហើយបានជាកិច្ចការទាំងអស់ហ្នឹង ខ្ញុំបានរាយការណ៍ម្ដងប៉ុន្តែគាត់បានទទួល មិនបានទទួលនោះ មិនឃើញគាត់តបវិញទេ។ អាហ្នឹង ខ្ញុំបាទសូមបញ្ចាក់ប៉ុណ្ណឹងចុះ។

**ស៖** លោក មាស រឿន តើលោកមានភ្ញាក់ផ្អើលដោយស្ថានភាព ដែលលោកទើបតែរៀបរាប់ប្រាប់អម្បាញ់មិញនេះដែរឬទេ? តើលោករំពឹងទុកថានឹង -- ស្ថានភាពហ្នឹង នឹងដូចយ៉ាងដូច្នេះ ឬក៏លោករំពឹងទុកថា ស្ថានភាពហ្នឹងវាអស្ចារ្យនៅសម័យនោះ?

**ឆ៖** ខ្ញុំថា មិនអស្ចារ្យទេ។ បើសិនជា ខ្ញុំមិនទៅ ប្រហែលជាអាចប្រជាជនគ្រោះថ្នាក់លើសនេះទៅទៀត។ ដូចខ្ញុំបញ្ជាក់អ៊ីចឹង។

[១៤:១៨:៣៦]

**ស៖** បាទ ខ្ញុំនឹងសួរឲ្យច្បាស់ជាងហ្នឹង។ នៅពេលដែលលោកទៅតំបន់ព្រះវិហារនេះ គេមានបានប្រាប់លោកមុនថា លោកនឹងជួបប្រទះនឹងស្ថានភាពដែលលោកបានជួបប្រទះនុ៎ង តើគេមានបានប្រាប់លោកទេថា នឹងមានការទង្វើហួសហេតុ ដែលមាននៅតំបន់ព្រះវិហារនុ៎ង?

**ឆ៖** បាទ គាត់មិនបានប្រាប់ឲ្យអស់ថា អ្ហ៊ូ តំបន់ព្រះវិហារវាមានឧបសគ្គអ៊ីចេះមួយ គាត់ប្រាប់តែប៉ុណ្ណឹង ហើយថាមិត្តទៅព្រះវិហារទៅមើលប្រជាជនគេកំពុងចាប់ ហើយទៅដល់យើងដើរ កត់ពិនិត្យមើលការជីវិភាពរស់ទាំងអស់ហ្នឹង ហើយចុងក្រោយគាត់ប្រាប់ថា "ទៅមិនបាច់ធ្វើអីទេ មិនបាច់នាំប្រជាជនធ្វើអីទេ ធ្វើតែស្រែហូបដូចសម័យឆ្នាំ៧០ទៅ ហ្នឹងទី១។ ទី២ ធ្វើតែផ្ទះឲ្យគាត់នៅបានហើយ"។ គាត់ប្រាប់តែពីរបញ្ហាហ្នឹងសំខាន់ប៉ុណ្ណឹងឯង។

**ស៖** បាទ លោកបាននិយាយជូនតុលាការថា មានការប្រជុំមួយនៅទីក្រុងភ្នំពេញ ដែលនៅពេលនោះលោកនៅជាមួយ សឿង ដែលជាមេបញ្ជាការកងពលលេខ១។ តើនៅពេលនោះ គេមានផ្តល់ការណែនាំដល់លោក ដើម្បីបង្ហាញតាមលក្ខណៈណាមួយនោះ ដើម្បីឲ្យលោកធ្វើការអនុវត្តមាគ៌ាបក្សដោយលក្ខណៈគេហៅ "មានភាពបត់បែន"?

[១៤:២០:៥៧]

**ឆ៖** បាទ កាលដែលខ្ញុំទៅព្រះវិហារហ្នឹង ខ្ញុំចូលភ្នំពេញហ្នឹង ដូចខ្ញុំបានបញ្ជាក់លើកមុនរួចហើយសំណួរលើកមុខរួចហើយតើ។ គឺថាទៅ ប៉ុល ពត បង្ហាញពីសភាពការណ៍ខ្មាំងមុន។ ខ្មាំងយួនដែលវ៉ៃព្រំដែនខាងកើត។ ថ្ងៃទី -- ខែ៨ ៧៨៧ ថ្ងៃមិនដឹងថ្ងៃប៉ុន្មាន ខ្ញុំស្តាប់ អ៉! ខ្ញុំមិនបានចាំ។ ដំបូងគឺគាត់បង្ហាញពីសភាពការណ៍ខ្មាំងយួនមុននៅតាមព្រំដែន ដែលកំពុងវ៉ៃប្រទង់ប្រទាញគ្នា ពិសេសនៅខាងស្នួល ខាងស្វាយរៀង ព្រំដែនកំពង់ចាម។ ហ្នឹងដែលគាត់បង្ហាញមុនដំបូង។ ហើយបន្ទាប់ទី២ទៅ គាត់បានប្រាប់ឲ្យខ្ញុំថា "មិត្តទៅតំបន់ព្រះវិហារ ទៅមើលកន្លែងនោះ ឮថាគេចាប់ប្រជាជនច្រើន

ព្រមជាមួយនេះអាចប៉ះពាល់ដល់ក្រុមការការពាររបស់អ្នកដឹកនាំខាងលើផង។ ហើយទៅមើលកន្លែងនោះអ៊ីចឹងមែន ឬយ៉ាងម៉េច។ ហើយទី៣ មិត្តកុំទៅ អ៎! កុំធ្វើអ្វីមិនបាច់លើកប្រព័ន្ធភ្លឺប្រឡាយអីនឹងគេទេ ដឹកនាំគាត់ធ្វើស្រែដូចឆ្នាំ១៩៧០។ ចំណុចទី៤ ធ្វើផ្ទះឲ្យគាត់នៅ ធ្វើម៉េចធ្វើតែផ្ទះឲ្យគាត់នៅបានហើយ ពីព្រោះតំបន់ហ្នឹងជាតំបន់ខ្ពង់រាប មិនអាចធ្វើប្រព័ន្ធប្រឡាយបានទេ"។ ហ្នឹងគាត់ប្រាប់ប៉ុណ្ណឹង។

[១៤:២៣:០៧]

**ស៖** លោកក៏បាននិយាយផងដែរ ហើយជាច្រើនដងទៀតផង។ និយាយថា "មានមន្ទីរសន្តិសុខនៅវវៀង" ខ្ញុំមិនដឹងថា ខ្ញុំអានឈ្មោះនេះត្រូវដែរឬក៏អត់ទេ ប៉ុន្តែលោកនិយាយថា មានអ្នកទោសប្រហែលជាជាង១០០នាក់នៅ -- រាប់រយនាក់នៅក្នុងមន្ទីរសន្តិសុខនោះ។ តើៗស្ថានភាពនៅមន្ទីរសន្តិសុខនោះយ៉ាងម៉េចដែរនៅពេលដែលលោកទៅដល់ភ្លាមនោះ?

**ឆ៖** បាទ មន្ទីរសន្តិសុខនៅវវៀង មាន ហើយមានអ្នកយាមការពារ អ្នកទាំងអស់នោះដែរ។ ហើយក្នុងហ្នឹងមានខ្មែរយើងច្រើនជាង វៀតណាមមានប្រហែលជា -- ប៉ុន្តែមិនមែនវៀតណាមចូលមកទេ វៀតណាមជំនាន់ឥស្សរៈហ្នឹងមកនៅយូរមកហើយ ប្រហែលជាបីគ្រួសារនៅជាមួយគ្នានឹងខ្មែរ។ ហើយនារីៗប្រហែលជាខ្ទង់ ១០០ ដឹង។ យើងមិនអាចចាំចំនួនទាំងអស់ បើសរុបទៅប្រហែលជាច្រើនដែរ ៣០០ ដឹង។ មិនអាចយកជាកំណត់បានទេ ពីព្រោះខ្ញុំមិនបានរាប់។ ហើយក្នុងចំណោមអ្នកជាប់ចោទនោះ មិនមានរបងអីការពារទេ មានតែខ្នមត្រង់ណោះៗទៅ ហើយគាត់ដេក គាត់នៅតាមដំណើរទៅ ហើយមានកន្លែងគេចិញ្ចឹមជ្រូក។ បាទ កន្លែងចិញ្ចឹមជ្រូកហ្នឹង។ អ៊ីចឹង ខ្ញុំទៅឃើញហ្នឹង ខ្ញុំក៏មិនទាន់ថាម៉េចដែរ គ្រាន់តែឃើញសិន។ ហើយពេលដែលខ្ញុំទៅហើយ មានមនុស្សជាច្រើនកងនារីខ្លះ ឆ្កួតដែលនាំ -- ដែលមកយកដាក់កន្លែងនុំង យកដាក់កន្លែងឃុំឃាំង។ ដល់នេះហើយ ខ្ញុំសួរសាកនារីម្នាក់ យកមកកន្លែងខ្ញុំនឹងសាលាវិទ្យាល័យវវៀងហ្នឹង។ សួរសាកគាត់មើល តើគាត់ឈឺយ៉ាងម៉េច បានគេឲ្យមកនៅក្នុងមន្ទីរឃុំឃាំង។ សួរខ្លះទៅថា អ្នកខ្លះថា "ខ្ញុំសុំគេទៅលេងផ្ទះ គេអត់ឲ្យទៅ" អាហ្នឹងមួយទៅ។

[១៤:២៥:៤៥]

មួយទៀត ខ្ញុំសួរបានមួយទៀត "តើនាង -- តើក្មួយ ន៎ែ! ហេតុអីបានជាមកនៅក្នុងកន្លែងគេឃុំឃាំង?" "អ៊ូ! ខ្ញុំលួចពងមាន់គេស៊ី" អាហ្នឹងម្យ៉ាងទៅ។ ហើយម្យ៉ាងទៀត នារីមួយដែលថាត្រូវស្នេហ៍គេហ្នឹង ខ្ញុំហៅសួរទៀត ហៅសួរយកពីកន្លែងពេទ្យមកសួរ។ សួរទៅថា "ខ្ញុំចេះតែឈឺតែក្បាល។ ពូឯង

ឈឺៗក្បាល" ដល់និយាយជាមួយខ្ញុំមួយសន្ទុះ អេះក្បាលទៅៗ យកក្រមួនមកឲ្យខ្ញុំមើលពីក្បាលហ្នឹង ប៉ុនកូនដៃហ្នឹង រុំក្រណាត់។ អាហ្នឹងមួយផ្នែកទៅ គេយកមកដាក់ឃុំឃាំង។

ដល់ខ្ញុំគិតឃើញអ៊ីចឹង ឃើញតែយំស្រែកតគ្នាទៅ ខ្ញុំក៏ដឹកពីរឡានមក យកមកសៀមរាបឲ្យមកពេទ្យសៀមរាប។ ហើយមិនទាន់អស់ទេ យំស្រែកតាមផ្លូវលើឡានហ្នឹង។ អាហ្នឹងមួយផ្នែកទៅ។ មួយផ្នែកនៅក្នុងមន្ទីរឃុំឃាំងហ្នឹង ក្នុងឆ្នាំ៧៨ ខែ៨ ហ្នឹង ប្រហែលជាបាន១ខែកន្លងមកហ្នឹង ខ្ញុំគិតខ្លួនឯងថា មន្ទីរឃុំឃាំងហ្នឹង គ្មានបាយ គ្មានទឹក ខ្ញុំគិតថា -- ហើយម្យ៉ាងយួនវៃតាមព្រំដែន ស្លាប់ទៅកាន់តែខ្លាំង ខ្ញុំសម្រេចខ្លួនឯង ហើយនិងស្រុកម្នាក់ ដែលខ្ញុំយកទៅជាប់ជាមួយហ្នឹង កំពុងឲ្យទៅថាឡាបរិវ៉ាត់។ ក៏ប៉ុន្តែគាត់សម្រាកហ្នឹងទៅ ក៏សម្រេចថា លែង។ លែងមក ក៏កាប់ជ្រូកអាក្នុងទ្រុងប៉ុន្មានហ្នឹង ឲ្យគាត់ហូបទៅ លែងទៅ បានប្រហែលជាកន្លះខែ យួនវៃចូលស្រុកហ្នឹងមក។ សូមអស់។

[១៤:២៧:៥៩]

**ស៖** បាទ លោកនិយាយអំពីការដោះលែងអ្នកទោសនៅមន្ទីរសន្តិសុខរវៀង ដើម្បីឲ្យច្បាស់លាស់តែម្តង ខ្ញុំចង់ដឹងថាតើមូលហេតុអ្វីបានជាមានការដោះលែងពួកគាត់? តើមកពីវៀតណាមជិតចូលមកដល់ ដោយធ្វើសង្គ្រាម ឬក៏ដោយសារតែលោកបទបញ្ជា ឬក៏ដោយសារលោកខ្លួនឯងផ្ទាល់ លោកយល់ឃើញថា ការដោះលែងអ្នកទោសទាំងអស់នេះ វាជាការចាំបាច់?

**ឆ៖** បាទ ខ្ញុំសម្រេច ដោយចិត្តខ្លួនឯង។ សម្រេចថា បើទុកក៏គ្មានអ្នកណាថែមើល ហើយម្យ៉ាងក៏វាឈឺផង វាឈឺខ្លួនផង ហើយម្យ៉ាងក៏បងប្អូន ក៏នឹកផ្ទះផង។ ខ្ញុំសម្រេចដោយចិត្តខ្ញុំ ហើយនិងស្រុកម្នាក់ដែលប្រុងយកមកតាមខ្ញុំហ្នឹង ប្រុងយកទៅឯនេះណោះ ប៉ុន្តែមិនទាន់បានយកទៅដាក់ ហើយសួរថា សភាពការណ៍ខាងមុខវាតឹងតែង ខ្ញុំសម្រេចខ្លួនឯង ថាលែងបណ្តោយទៅ។ រួចទាំងអស់ទៅ។

[១៤:២៩:២៥]

**ស៖** បាទ ដើម្បីឲ្យច្បាស់មែនទែនតែម្តងទៅនោះ គឺថាលោកថាមិនដែលធ្លាប់បានទទួលសេចក្តីណែនាំអំពីអាជ្ញាធរ ឬក៏ពី -- នៅៗ ភ្នំពេញ ឬក៏ពីអ្នកណាម្នាក់ ឲ្យដោះលែងអ្នកទោសនៅក្នុងតំបន់ព្រះវិហារនេះទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** ហើយក្រោយមកទៀត តើលោកមានធ្លាប់បានជួបលោក ខៀវ សំផន ដែរឬទេ ពេលក្រោយមកទៀតនោះ?

**ឆ៖** បាទ អត់រហូត។

[១៤:៣០:០៩]

**ស៖** ឥឡូវនេះ ខ្ញុំសូមលើកសេចក្តីប្រកាសរបស់លោក ខៀវ សំផន មួយចំនួនដែលថាគាត់បាននិយាយចំពោះមុខសាធារណជនជាច្រើនដង។ ខ្ញុំយោងទៅលើឯកសារ E3/198 គឺជាកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់គាត់។ ERN ជាភាសាបារាំងគឺ 00296212, ជាភាសាអង់គ្លេសគឺ 00184680 និងជាភាសាខ្មែរ គឺ 00078213។ នេះគឺជាកិច្ចសម្ភាសន៍នៅប៉ៃលិន ថ្ងៃទី១៧ សីហា ឆ្នាំ២០០៥។ អ្នកដែលធ្វើកំណត់ហេតុនេះ និយាយយ៉ាងដូច្នេះ បើតាម -- "ចំពោះគាត់នៅក្នុងរបបខ្មែរក្រហមភូមិភាគនីមួយៗជាពិសេស គឺលេខាភូមិភាគ ដូចជា ស្តេចត្រាញ់ ដែលធ្វើការនៅក្នុងភូមិភាគនុ៎ងតាមតែក្បាលចិត្តរបស់ខ្លួន។ គណៈមជ្ឈិមពុំមានសមត្ថភាពគ្រប់គ្រងនោះទេ បានត្រឹមតែទទួលរបាយការណ៍តែប៉ុណ្ណោះ។ នៅក្នុងភូមិភាគជើង ក្រោយពី កង ចាប ត្រូវបានតែងតាំងជាប្រធាន មានការចាប់ខ្លួន។ នៅឆ្នាំ១៩៧៨ គណៈមជ្ឈិម និងបងទី១ បានបញ្ជូនមនុស្សទៅទទួលភ្ញៀវទេសចរណ៍ ហើយទើបដឹង ហើយមករាយការណ៍"។ តើលោកធ្លាប់ឮនិយាយអំពីបេសកកម្មរៀបចំការទទួលនៅក្នុងតំបន់ព្រះវិហារ ឬសៀមរាបគឺថារៀបចំទទួលភ្ញៀវទេសចរណ៍ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានមកទទួលទេ។

[១៤:៣២:៥៨]

**ស៖** ហើយក្រៅពី ប៉ុល ពត ឬក៏ ខៀវ សំផន តើលោកទទួល -- បានទទួលសេចក្តីណែនាំពីមេរបស់លោកឈ្មោះ សឿង ទំនងជាអ្នកទទួល ដែលជាប្រធានភូមិភាគឧត្តរថ្មី?

**ឆ៖** ខ្ញុំអត់បានទទួលអីពីគាត់ទេ។ គាត់បានទៅកន្លែងខ្ញុំម្តងនិយាយពីការរៀបរយ បានទៅមើលប្រជាជននៅគ្រប់ស្រុកហើយឬនៅ? អីយ៉ាងម៉េច? ហើយខ្ញុំបានប្រាប់គាត់ថា ខ្ញុំបានទៅបានតែពីរស្រុកទេ វាស្រុកឆ្ងាយៗពេក។ ពីររៀងទៅជាំក្សាន្ត ប្រហែលជិត១០០គីឡូនោះ ហើយមធ្យោបាយដើរហើរវាលំបាកដែរ ផ្លូវព្រៃ ហើយអាទៅថាឡាក៏ផ្លូវឆ្ងាយដែរ។ ដូច្នេះ គាត់បានទៅពិភាក្សាតែពីកិច្ចការងារដែលតាមស្រុកហ្នឹងយ៉ាងម៉េច អីយ៉ាងម៉េចប៉ុណ្ណឹងទេ។ ឃើញការរស់នៅការស៊ីចុក ជីវភាពឬក៏គ្រុនឈឺយ៉ាងម៉េច ខ្ញុំប្រាប់តាមដំណើរដែលខ្ញុំឃើញនោះទៅ បាទ។

[១៤:៣៤:២៥]

**ស៖** បាទ សូមលោក លោក មាស វឿន សូមលោករំឭកថា តើលោកទៅដល់តំបន់ព្រះវិហារ

នេះនៅពេលណាដែរ ឲ្យប្រាកដប្រជាតែម្តងទៅនោះ?

**ឆ៖** ខ្ញុំទៅខែ៨ ឆ្នាំ៧៨ ហ្នឹងប្រាកដ ថ្ងៃខ្ញុំអត់បានចាំ។

**ស៖** នៅខែសីហា ឆ្នាំ១៩៧៨ នៅពេលដែលលោកទៅដល់នោះ តើលោកមានមន្ទីរមួយដែលអាចឲ្យលោកផ្ញើតេឡេក្រាម ឬក៏មានបុគ្គលដែលផ្ញើទូរលេខ ឬក៏ទទួលទូរលេខដែរឬទេ នៅពេលដែលលោកទៅដល់នោះ?

**ឆ៖** បាទ មាន។ មានតែពីរនាក់ទេ បុគ្គលិកហ្នឹងសល់ពីបុគ្គលិកពីកន្លែង តាហង្ស មក ហើយខ្ញុំចេះតែហៅគាត់ប្រើប្រាស់។ ខ្ញុំយកពីនេះទៅ គឺអត់បានយកទេ។ ទៅដល់ហ្នឹង គាត់នៅតែពីរនាក់មែនបុគ្គលិកហ្នឹងមានតែឈ្មោះ អើយ ហ្នឹង ហើយនិងឈ្មោះ អុល ហ្នឹង ពីរនាក់ហ្នឹង។

**ស៖** បាទ ដូច្នេះច្បាស់លាស់តែម្តង គឺថាពេលដែលលោកទៅដល់ពីនោះហ្នឹង គឺថាលោកមានបុគ្គលិក ហើយមានសម្ភារៈដើម្បីទទួល ហើយនិងផ្ញើសារមកភ្នំពេញ ឬក៏ទទួលពីភ្នំពេញ។ តើអ៊ីចឹងមែនទេ?

[១៤:៣៦:២១]

**ឆ៖** បាទ មុនដំបូងខ្ញុំទទួលមុនពីភ្នំពេញមុន។ ឯទទួលមុនគឺសាររបស់លោក ខៀវ សំផន មុនគេ ហើយបន្ទាប់មកអត់ទាន់មានបានទទួលសារពីណាទៀតទេ។ ហើយខ្ញុំក៏អត់បានរាយការណ៍ទៅខាងណាទៀតដែរ គឺខ្ញុំរាយការណ៍តែទៅខាងលោក ខៀវ សំផន តែអំពីរឿងកិច្ចការរឿងក្រុមគ្រួសារគាត់តែប៉ុណ្ណឹង។ ហើយក្រោយមកអាសភាពការណ៍វាអត់ស្ងួវស្រួល អ៊ីចឹងក៏មិនសូវរាយការណ៍ប៉ុន្មានដែរ គឺរាយការណ៍ទៅក៏មិនដឹងអាកន្លែង អ្នកកាន់ទទួលខាងណោះ ជួនកាលបាត់ ជួនកាលឃើញទៅ ខ្ញុំមិនបានរាយការណ៍ទេ ហើយដាច់គ្នាមួយរយៈអ៊ីចឹងទៅ។

**ស៖** នៅខែសីហា ឆ្នាំ១៩៧៨ តើវៀតណាមនោះខិតចូលមកជិតដល់តំបន់ព្រះវិហារ ហើយនិងភ្នំពេញហើយ ហើយដោយសារមូលហេតុនេះហើយបានជាលោកមិនអាចផ្ញើសារ ឬក៏លោកបានផ្ញើសារតិចបំផុតទៅខាង -- ចេញពីកន្លែងលោកនោះ។ តើអ៊ីចឹងមែនទេ? ដោយសារមូលហេតុហ្នឹងមែនទេ?

**ឆ៖** បាទ មែន។

[១៤:៣៧:៥៤]

**ស៖** តើលោកបានឃើញវៀតណាម ទាហានវៀតណាមទី១ នៅពេលណាដែរ នៅព្រះវិហារ?

**ឆ៖** បាទ ទាហានវៀតណាមចូលភ្នំពេញមុនគេ ឯកន្លែងខ្ញុំនៅព្រះវិហារ មិនទាន់ចូលទេ។ ហើយមក -- តាមមើលមិនដឹងជាថ្ងៃណា ខ្ញុំមិនចាំទេ ប៉ុន្តែក្នុងឆ្នាំ អ៎! ខែ១១ ខែ១២ ហ្នឹងឯង។ មិនដឹងជាថ្ងៃប៉ុន្មាន ខ្ញុំមិនបានចាំ។

**ស៖** លោក មាស វឿន តើលោកដឹងថាកងទ័ពវៀតណាមមកដល់ទីក្រុងភ្នំពេញនៅថ្ងៃណាដែរឬទេ?

**ឆ៖** បើតាមខ្ញុំ -- កាលហ្នឹងខ្ញុំមិនបានដឹងថាវៀតណាមវ៉ៃចូលភ្នំពេញថ្ងៃប៉ុន្មាន ប៉ុន្តែខ្ញុំព្រឹកឡើងខ្ញុំបើកស្តាប់អាមេរិកាំងប្រាប់ថា ថ្ងៃ០៧ មករា ហ្នឹងវៀតណាមវ៉ៃចូលភ្នំពេញ។ ដល់នេះថ្ងៃហ្នឹងតាសឿង គាត់មិនទាន់ទៅពីខ្ញុំទេ គាត់នៅដេកជាមួយខ្ញុំមួយយប់ បានគាត់ទៅកន្លែងគាត់។ ហើយខ្ញុំប្រាប់គាត់ថា "បង! បងឯងមើលវៀណាម -- យួនវ៉ៃចូលភ្នំពេញបាត់ហើយ!។ អ្ហែ កុំចេះតែថា! យួនវ៉ៃឯណាចូលភ្នំពេញ។ យី! ខ្ញុំស្តាប់អាមេរិកាំងផ្សាយព្រឹកមិញ។ អ្ហែ មិនមែនទេ!"។ គ្រាន់តែប្រាប់គាត់អ៊ីចឹង គាត់ថា "អ៊ីចឹងខ្ញុំទៅសៀមរាបហើយអ៊ីចឹង"។ ហើយក៏គាត់មកសៀមរាបមក ខ្ញុំក៏នៅម្នាក់ឯងហ្នឹង រវៀងហ្នឹងទៅ ស្រុករវៀងហ្នឹង។ ហើយស្អែកឡើង១ បានឃើញកងទ័ពមកពីព្រំដែនមក កាត់តាមតំបន់ព្រះវិហារហ្នឹងមក ឆ្លងតាមស្ទឹងត្រែងហ្នឹងមក កាត់តំបន់ព្រះវិហារហ្នឹងមក ឆ្លងតាមស្ទឹងត្រែងហ្នឹងមក កាត់តំបន់ព្រះវិហារហ្នឹងមក ឃើញកងទ័ពមក ហើយខ្ញុំសួរថា "អ្ហែ ហ្នឹងមកពីខាងណាហ្នឹង?" "ខ្ញុំមកពីព្រំដែន ថាយួនវ៉ៃចូល១កំពង់ចាម ចូលស្នួលអត់ហើយ។ អ៊ីចឹងឃើញកងទ័ពវាមក។ "ខ្ញុំថាមែន? អ្ហែ មែន"។ ខ្ញុំគ្រាន់តែសួរវាអ៊ីចឹង ១ខ្ញុំដឹងថាកំណត់តែថ្ងៃ ដែលវៀតណាមចូលមកដល់ព្រះវិហារហ្នឹង ប្រហែលជាថ្ងៃ១០ -- ថ្ងៃ០៧ ឬក៏០៨ បានដល់ព្រះវិហារ ០៨មករា មកដល់ព្រះវិហារបានខ្ញុំថយចេញមក។

[១៤:៤០:៥១]

**ស៖** លោក មាស វឿន ចន្លោះខែសីហា ឆ្នាំ១៩៧៨ ហើយនិងមករា ឆ្នាំ១៩៧៩ មិនអាចធ្វើការទាក់ទងជាមួយទីក្រុងភ្នំពេញទេឬ? តើយើងត្រូវយល់អ្វីដែលលោកនិយាយយ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អត់ទាក់ទងបានតាមភ្នំពេញ កន្លែងសារទូរលេខហ្នឹងគឺអត់ ដាច់គ្នារហូត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ អរគុណសាក្សី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ច

ដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅក្នុងអំឡុងពេលឈប់សម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សី និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៤១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ក្នុងដំណាក់កាលនេះ ខ្ញុំសូមឆ្លើយតបទៅនឹងការកត់សម្គាល់របស់មេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ព័ត៌មាន ដែលចេញមកពីចម្លើយសារភាព របស់ជនដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១។ ខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះមិនបានផ្លាស់ប្តូរនូវសេចក្តីសម្រេចរបស់ខ្លួនទេ ហើយការយោងទៅលើខ្លឹមសារ នៃឯកសារចម្លើយសារភាពត្រូវបានហាមឃាត់ដដែល។ ពាក់-ព័ន្ធទៅនឹងសំណួរដែលខ្ញុំចោទសួរនោះ គឺមិនផ្អែកទៅលើខ្លឹមសារនៃចម្លើយសារភាពនោះទេ ក៏ប៉ុន្តែគឺផ្អែកទៅលើប្រភពទេ គឺជាជាពិសេសគឺ ពាក់ព័ន្ធទៅនឹងករណីរបស់ កុយ ធួន ដែលថា តាមរយៈមុខងាររបស់គាត់ គាត់មានទំនាក់ទំនងជាមួយតំបន់១០៦។ ជាឧទាហរណ៍ ខ្ញុំចង់ដកស្រង់នូវឯកសារមួយ ដែលជាឯកសារលេខ E3/232 ដែលនៅក្នុងភាសាបារាំង មានចំណងជើងថា “កំណត់ហេតុកិច្ចប្រជុំភូមិនៅខែមីនា ឆ្នាំ១៩៧៦” ERN ជាភាសាខ្មែរ 00017116 ទៅដល់ 123, ERN ជាភាសាបារាំង 00323932 ទៅដល់ 00323936, ជាភាសាអង់គ្លេស 00182628 ទៅដល់ 31។

[១៥:០៥:០៦]

ឯកសារនេះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំ ដែលមានសមាសភាពអ្នកចូលរួមដូចតទៅនេះ៖ សមមិត្តលេខា សមមិត្តអនុលេខា, សមមិត្ត ហែម, សមមិត្ត ឡឿន, សមមិត្ត ស្រែង, សមមិត្ត ហង្ស សមមិត្ត សុត និងសមមិត្ត ទូច។ ដូច្នេះ យើងអាចសន្និតថា ទូត នេះហើយគឺជាឈ្មោះ កុយ ធួន នោះ។ របៀបវារៈ គឺពាក់ព័ន្ធទៅនឹងបញ្ហាបោះឆ្នោតថ្ងៃ២០ មីនា ៧៦ ក៏ដូចជាសភាពការណ៍នៅឧត្តរ ជាពិសេសនៅតំបន់១០៦ និង ១០៣។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា "កុយ ធួន ពិតជាត្រូវបានជាប់ -- ចាប់ខ្លួនមែន ក៏ដូចជាអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះមួយចំនួនទៀត លើកលែងតែ ប៉ុល ពត, នួន ជា និង ខៀវ សំផន តែប៉ុណ្ណោះ"។ សមមិត្ត ហង្ស ទទួលបន្ទុកតំបន់១០៣ ក៏ត្រូវបានចាប់ខ្លួន សមមិត្ត សុត ហៅ តាផល ក៏ត្រូវបានចាប់ខ្លួន ហើយ កុយ ធួន ក៏ដូចគ្នា គឺត្រូវបានចាប់ខ្លួន។

[១៥:០៦:២៥]

ខ្ញុំសូមបញ្ជាក់ថា ខៀវ សំផន បានចូលរួមនៅក្នុងកិច្ចប្រជុំមួយនេះ ហើយគាត់បានប្រាប់ឲ្យអ្នកទទួលខុសត្រូវរាយការណ៍ជាប្រចាំទៅដល់គណៈអចិន្ត្រៃយ៍អំពីស្ថានភាព ដែលបានកើតឡើងទោះជាពាក់ព័ន្ធទៅនឹងការសាងសង់ទំនប់សម្រាប់ស្រោចស្រព ឬក៏ពាក់ព័ន្ធទៅនឹងសភាពការណ៍ទូទៅនៅក្នុងតំបន់នីមួយៗ ហើយក៏គាត់បានស្នើឲ្យរាយការណ៍តាមទូរលេខផងដែរ ដើម្បីឲ្យគណៈអចិន្ត្រៃយ៍បានដឹងអំពីហេតុការណ៍ដែលបានកើតឡើង ហើយនិងអាចធ្វើសំណួរពរ ឬសេចក្តីណែនាំទាន់ពេលវេលា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ ហើយខ្ញុំសូមអរគុណសាក្សីដែលបានចូលរួមឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។ ម៉េចទៅលោក មាស វឿន មានបញ្ហាអីទេ?

**លោក មាស វឿន៖**

ខ្ញុំបាទ អត់មានបញ្ហាអីទេ។ ខ្ញុំអត់ដឹងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បើមិនមានបញ្ហាទេ អង្គជំនុំជម្រះនឹងបន្តការស្តាប់សក្ខីកម្មរបស់លោកតទៅទៀត។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីលោក មាស វឿន។

សូមអញ្ជើញ!

[១៥:០៨:០៦]

**លោក សុន អរុណ៖**

សូមគោរពលោកក្រុមប្រឹក្សាអង្គជំនុំជម្រះ សូមគោរពលោកប្រធាន និងសូមជម្រាបសួរលោក មាស វឿន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំជាដំបូងនេះ ខ្ញុំសូមសួរបន្ត។ ពីរចនាសម្ព័ន្ធរបស់លោកចៅក្រមស៊ើបអង្កេតបានសួរម្តង រួចទៅហើយ ប៉ុន្តែនៅ -- ខ្ញុំនៅមានការងឿងឆ្ងល់ ការលម្អិតអំពីរចនាសម្ព័ន្ធរបស់យោធា។ លម្អិតហ្នឹង គឺថា មុនដំបូងបំផុត ខ្ញុំចង់សួរថា ពេលដែល -- នៅឆ្នាំ១៩៧០ ពេលហ្នឹងលោកអាយុនៅក្មេង លោកថា នៅក្មេងអាយុ១៨ លោកបានចូលធ្វើជាកងទ័ព។ ពេលនុ៎ង គេបានចាត់លោកឲ្យទៅរៀន រៀនខាង យោធា រៀនខាងបច្ចេកទេសយោធា ច្បាប់ទម្លាប់យោធាទាំងអស់ហ្នឹង។ បើលោកបានទៅរៀនត្រឹមត្រូវ ដូចជាអ្នកយោធាផ្សេងៗដែលបានសិក្សាអីចឹងដែរ លោកអាចនិយាយបន្ថែមអំពីរចនាសម្ព័ន្ធយោធា ខ្ញុំ ចង់បញ្ជាក់ថា រចនាសម្ព័ន្ធនេះចង់និយាយអំពីឋានានុក្រមតាំងពីថ្នាក់តូច។ ឧទាហរណ៍ថា ជាក្រុម ជា ផ្នែក រហូតទៅដល់កងពល។ សូមលោកជម្រាបតុលាការម្តងទៀត ថារចនាសម្ព័ន្ធនេះឲ្យលម្អិត ហើយ ឲ្យត្រឹមត្រូវតាមក្បួនច្បាប់ដែលលោកបានសិក្សានៅក្នុងសាលា?

[១៥:១០:១២]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបពីរចនាសម្ព័ន្ធយោធាថ្មីម្តងទៀត។ ដំបូង គេហៅថា ក្រុមៗនុ៎ង គេ រៀបពីក្រុមទៅមុន។ ក្រុមហ្នឹង មាន១២នាក់។ ចំនួនមនុស្សហ្នឹង ១២នាក់ ហ្នឹងហៅថាក្នុងមួយក្រុម។ ដល់មួយកងតូច គេរៀបចំបីក្រុម--

**ស៖** សូមកាត់។ សូមបញ្ជាក់ថា កងតូចហ្នឹង កងអី? កងតូចយ៉ាងម៉េច?

**ឆ៖** អាហ្នឹង កងអនុសេនាតូច។ កងអនុសេនាតូច វាមានបីក្រុម គេហៅថា កង -- មួយកង អនុសេនាតូច។ ហើយរៀបជាអនុសេនាធំវិញ វាមានបីៗកងអនុសេនាតូច គឺវាបានមួយអនុសេនាធំ។ ហើយវាមានបីអនុសេនាធំហ្នឹង វាត្រូវបានមួយកងវរសេនាតូច។ ហើយគេរៀបមានបីកងវរសេនាតូច

ហ្នឹងៗ គេកំណត់ថា មួយវរសេនាធំ។

[១៥:១២:០១]

ហើយក្នុងបីវរសេនាធំៗ ហ្នឹង គេរៀបចំឲ្យបានមួយកងពលតូច។ ក្នុងនោះ មានកងវរពិសេសរបស់កងពលតូច មួយវរសេនាតូចសម្រាប់កងពលតូចប្រើប្រាស់។ ហើយគេមានបីកងពលតូច គេមានមួយកងពលធំ។ ក្នុងនេះ ខ្ញុំសូមបញ្ជាក់ខ្លីអំពីរចនាសម្ព័ន្ធ។ ឯមានកងខ្លះទៀត គេរៀបក្នុងនុំងដែរ ក៏ប៉ុន្តែដោយការកងពលធំសម្រាប់បញ្ជា ឬក៏រៀបចំឧបករណ៍សម្ភារៈដែលមានចាំបាច់ ដូចជាមាន កាំភ្លើងធំកងកាំភ្លើងធំ មានកងពិសេស សម្រាប់គេកងពលធំ ឬក៏កងពលតូច គេគ្រប់គ្រងផ្ទាល់។ ខ្ញុំសូមជម្រាបខ្លីប៉ុណ្ណឹង។ ហើយសរុបទៅយកៗ មួយក្រុមពីរដណ្ដប់នាក់ គុណនឹងបី ហើយយកបី គុណ និងបី ទៀតតរហូត ដឹងចំនួនមនុស្សដែលត្រូវចំនួនគ្រប់។ នែ៎ ចំនួនកងពលតូច និងកងពលធំ។ ខ្ញុំមិនបាច់កំណត់ចំនួនថាប៉ុណ្ណេះ ប៉ុណ្ណោះទេ ពីព្រោះការរៀបចំ វាមិនបានគ្រប់នឹងនរ ត្រឹមត្រូវទេ។ ជួនកាល រៀបចំថ្ងៃណេះ ទៅវ៉ៃថ្ងៃនោះ ស្លាប់អស់ប៉ុណ្ណេះប៉ុណ្ណោះ វាអាចមិនគ្រប់ក៏មានដែរ។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** អរគុណលោកសាក្សី។ លោកសូមបញ្ជាក់បន្តិចទៀតថា មួយកងពលតូច មានយើង -- នេះខ្ញុំសួរនេះ គឺក្នុងន័យមួយថា តាមក្បួនច្បាប់ ដែលលោកបានរៀនសិក្សាណ៎ះ មិនមែនទៅតាមកាលៈទេសៈៗ ក៏មានតិចមានច្រើន អាហ្នឹង ខ្ញុំយល់ ប៉ុន្តែថា គ្រាន់ថាមួយកងពលតូច ខ្ញុំសួរបង្រួមមកតែម្ដង មានកងយោធាប៉ុន្មាន?

**ឆ៖** មិនហួសពី៣.០០០ ទេ នេះកម្រិតមធ្យម។

[១៥:១៤:៤៩]

**ស៖** ចុះមួយកងវរសេនាធំ មានយោធាប៉ុន្មាន វរសេនាធំ?

**ឆ៖** មួយវរសេនាធំ មិនហួសពី៦០០ទេ។

**ស៖** អរគុណណាស់។ ខ្ញុំសូមសួរតទៅទៀត នៅក្នុងឯកសារសួរចម្លើយរបស់ចៅក្រមស៊ើបអង្កេត នៅលេខ E3/424 នៅចម្លើយរបស់លោកនៅចម្លើយទី១ លោកសាក្សីបានចូលបដិវត្តន៍តាំងពីឆ្នាំ១៩៧០ ពេលហ្នឹងអាយុប្រហាក់ប្រហែល ១៨ឆ្នាំ។ ពេលនោះលោកបានចូលជាក្រុមយុវជនស្នេហាជាតិក្នុងការតស៊ូរំដោះប្រទេសឲ្យរួចផុតពីអាណានិគមនិយម និងមូលធននិយម។ ពេលនោះលោកបានទទួលភារកិច្ចជាកងការពារ និងជាអ្នកនាំផ្លូវរបស់កម្មាភិបាលផង។ ពាក្យលោកនិយាយថា “រំដោះប្រទេសឲ្យរួចផុតពីអាណានិគមនិយម និងមូលធននិយម” ពាក្យនេះ លោកអាចពន្យល់ឲ្យបានទូលំ

ទូលាយជាងនេះបន្តិច ថាអាណានិគមនិយមហ្នឹង ឬមូលធននិយមនេះ លោកសំដៅលើមនុស្ស ឬប្រទេសណា ក្នុងពេលដែលលោកឆ្លើយជាមួយនឹងចៅក្រមស៊ើបអង្កេត?

[១៥:១៦:៥៩]

**ឆ:** បាទ អំពីរំដោះឲ្យរួចពីអាណានិគមបារាំង កាលយើងដឹងថា ប្រទេសយើងពីដើមមកគឺនៅក្នុងអាណានិគមនិយមបារាំង រាប់ច្រើនឆ្នាំ ប្រហែលជាជិត១សតវត្សរ៍ ក៏ប៉ុន្តែយើងខ្ញុំជំនាន់នោះមិនទាន់ដឹងច្បាស់ទេ។ ដូច្នេះបានន័យថា រហូតមកបានសម្តេចសោយរាជ្យ គឺបានដឹងថា អាណានិគមបារាំង ពេលដែលបារាំងចេញទៅស្រុក តស៊ូជាមួយឥស្សរៈហ្នឹង បារាំងទៅស្រុកអស់ ក៏ប៉ុន្តែសេដ្ឋកិច្ចឬក៏វត្ថុអ្វីដែលធំដុំ គឺនៅលើបារាំងកាន់កាប់ទាំងអស់។ ឧទាហរណ៍ ដូចជា ក្រុមហ៊ុនទឹកក្រូច ចម្ការកៅស៊ូ ចម្ការកាហ្វេ ក៏នៅលើបារាំងត្រួតត្រាទាំងអស់។ នេះហៅថា ក្រោមអាណានិគមបារាំង។ ហើយក្នុងហ្នឹងបានន័យថា ខ្មែរយើងអត់មានអំណាចអីគ្រប់គ្រងលើបារាំងទេ អ្វីក៏នៅលើបារាំងទាំងអស់។ នេះហើយដែលគេហៅថា អាណានិគមនិយមបារាំង។

[១៥:១៨:១៨]

ត្រង់នេះដែលខ្ញុំបានដឹងយល់ខ្លះអំពីអាណានិគមនិយម។ ឯមូលធននិយម ឧបមាថា របស់របរទិញដូរ ឬក៏ចេញចូលប្រទេសមួយទៅប្រទេសមួយហ្នឹងហៅថា មូលធននិយម ហើយដើម្បីទិញដូរពីរាស្ត្រខ្មែរទៅ ថោក ប៉ុន្តែខ្មែរយើង រាស្ត្រខ្មែរយើងទៅទិញពីនាយទុន ឬមូលធនមក វាថ្លៃ។ ត្រង់នេះហើយបានន័យថា ការជិះជាន់សង្កត់សង្កិនលើរាស្ត្រខ្មែរយើងពីសេដ្ឋកិច្ច គឺប្រជាជនខ្មែរយើងងើបអត់រួច។ ដូច្នេះប្រជាជនខ្មែរយើងគ្មានអំណាចអ្វី ឬគ្មានសិទ្ធិអ្វីដែលតវ៉ា ដើម្បីទិញថោក លក់ថ្លៃ នេះហើយដែលគេហៅថា មូលធននិយមរកស៊ីផ្តាច់មុខ ហើយខ្មែរយើង អ៎! ប្រជាជនខ្មែរយើងដែលមានការលំបាក។ នេះដែលហៅថា សេដ្ឋកិច្ច ហើយក្នុងការដែលរំដោះសក្តិភូមិ របបសក្តិភូមិ ក៏យ៉ាងដូច្នេះដែរដូចគ្នា។ អ៊ីចឹងហើយប្រជាជនខ្មែរយើងពិសេសប្រជាជននៅជនបទ គឺគ្មានសិទ្ធិ គ្មានសេរីភាពក្នុងការរកស៊ីអ្វីទាំងអស់។ ត្រង់នេះហើយខ្ញុំសូមបញ្ជាក់ខ្លីប៉ុណ្ណេះ អស់។

[១៥:២០:០៨]

**ស:** អរគុណ។ ពេលដែលលោកចូលធ្វើជាអ្នកតស៊ូបដិវត្តន៍ ពេលនោះលោកតែត្រឹមតែ១៨។ លោកជម្រាបតុលាការអំមិញ ពន្យល់តុលាការអំមិញ អំពីពាក្យមូលធននិយម សក្តិភូមិអីទាំងអស់ហ្នឹង។ លោកយល់ដឹងតាមការយល់ដឹងរបស់លោក ឬក៏លោកយល់តាមលោកបានសិក្សានៅសាលា

ណាមួយ ឬក៏លោកយោងទៅលើឯកសារណាមួយ បានជាលោកពន្យល់របៀបនេះ?

**ឆ៖** បាទ ខ្ញុំបានយល់ពីកិច្ចការប្រទេសជាតិ អ៊ីចឹងខ្ញុំយល់ពីបញ្ញាជនខ្លះដែលបានប្រាប់ខ្ញុំ ឧទាហរណ៍ដូចលោក ហ៊ូ នឹម គាត់បានប្រាប់ខ្ញុំអ៊ីចឹង។ ឥស្សរជនគ្រូបង្រៀន ដែលគាត់នៅមិនបានក្នុងភ្នំពេញ គាត់បែកមុខ ខ្ញុំមិនបានចាំឈ្មោះកាលណោះ ក៏គាត់បានមកបង្រៀនខ្ញុំ។ ហើយខ្ញុំចាំឈ្មោះម្នាក់ទៀត ដូចជាគ្រូបង្រៀនឈ្មោះ តាគ្រិន គាត់បានបង្រៀនអំពីប្រទេសជាតិយើងអ៊ីចឹង។ ដូច្នេះខ្ញុំអត់ចេះដឹងយល់ខ្លួនឯង ខ្ញុំបានរៀនពីបញ្ញាជន ឥស្សរជនខ្លះដែលគាត់ប្រាប់ខ្ញុំ ហើយការដែលរៀនសិក្សានោះអត់មានសាលាណាមកបង្រៀនទេ ក្នុងពេលដែលៗខ្ញុំ គឺខ្ញុំរៀនតាមម្លប់ឈើ តាមក្នុងព្រៃ ពេលដែលឆ្នាំ៧០ ហើយនោះ។

[១៥:២២:១០]

ហើយខ្ញុំសូមបញ្ជាក់ម្តងទៀត ខ្ញុំដែលអាយុប្រហែលជា១៨នោះ ខ្ញុំមិនមែនឆ្នាំ៧០ ទេ។ ខ្ញុំ -- ឆ្នាំ១៩៦៨ អាយុខ្ញុំប្រហែលជា១៨ ដល់មកឆ្នាំ៧០ ខ្ញុំមិនមែនជាអាយុ១៨ទេ ព្រោះខ្ញុំកើតឆ្នាំ១៩៤៤។ នេះដែលខ្ញុំសូមបញ្ជាក់ ពីបញ្ហាដែលខ្ញុំបានសិក្សារៀនសូត្រ ហើយខ្ញុំចេះតស៊ូ ដឹងយល់ ក៏ដឹងពីបញ្ញាជនឥស្សរជនគាត់ស្នេហាជាតិ បានដឹងច្បាស់។ ខ្ញុំមានយោបល់ប៉ុណ្ណឹង។

**ស៖** អរគុណចម្លើយរបស់លោក។ នៅឆ្នាំមួយពាន់ -- នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកនៅក្នុងកងពលលេខ១ និងជួយការងាររបស់ តាសឿន (ស៊ីក)។ ខ្លួនលោកផ្ទាល់ លោកកាន់យោធាជាមេបញ្ជាការកងវរសេនាធំ អ៊ីចឹងត្រឹមត្រូវទេ? អ៎! ក្នុងកងវរសេនាធំលេខ១៣៦ ក្នុងកងពលៗទី១។ ខ្ញុំនិយាយនេះត្រឹមត្រូវទេ ឬក៏បើខុសកែខ្ញុំ?

**ឆ៖** បាទ វរសេនាធំលេខ១៦ មិនមែនមួយរយ -- លេខវរសេនាតូចនោះ កាលខ្ញុំនៅវរសេនាតូចវាលេខ១៣៦ ប៉ុន្តែដល់ខ្ញុំបានឡើងវរសេនាធំលេខ១៦។

[១៥:២៤:០៤]

**ស៖** អរគុណណាស់។ ពេលនោះកងទ័ពខ្មែរក្រហមបានសម្រេចចិត្ត នឹងវាយចូលក្រុងភ្នំពេញ។ ពេលដែលវាយចូលក្រុងភ្នំពេញ លោកកាន់កងឯកភាព មានន័យថាកងវរសេនាធំលេខ១៦នុ៎ងបើតាមឯកសារ ថាលោកវាយចូល ថាកងពលទី១ ហ្នឹង ឬក៏និរតី ខាងនិរតីវាយចូលតាមចូលច្រកពោធិ៍ចិនតុង អូរបែកក្អម និងស្ទឹងមានជ័យ។ អាហ្នឹងតាមឯកសារដែលលោកឆ្លើយជាមួយចៅក្រមស៊ើបអង្កេត។ តើត្រឹមត្រូវទេ?

[១៥:២៤:៥៨]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅក្នុងឯកសារ E3 លេខ 4 -- E3/424 ចម្លើយទី២។ ពេលដែលលោកៗជាកងយោធា ពេលដែលគេចាត់ឲ្យលោកវាយចូលភ្នំពេញមុននឹងៗវាយចូលភ្នំពេញ លោកមានដឹងគម្រោង ឬផែនការរបស់កម្ពុជាប្រជាធិបតេយ្យ នឹងជម្លៀសខ្លួនចេញពីភ្នំពេញទេ? មានបានដឹងរឿងហ្នឹងទេ?

**ឆ៖** បាទ មិនបានដឹងទេ។

**ស៖** មុនពេលវាយចូលភ្នំពេញ មុខព្រួញខាងភូមិភាគបូព៌ា និរតីជាដើម បានប្រជុំជាមួយអគ្គសេនាធិការមានតា សុន សេន និង តា នួន ជា អ្នកដឹកនាំប្រជុំជាមួយមេកងពលគ្រប់ភូមិភាគ ហើយប្រធានកងពលបានយកមកផ្សព្វផ្សាយបន្តមកដល់កងវរសេនាធំ មានន័យថាបានដល់លោកជាដើម។ ការប្រជុំនោះ ទិសដៅ និងផែនការ គឺវាយរំដោះភ្នំពេញឲ្យបាននៅថ្ងៃទី១៨ មេសា ឆ្នាំ១៩៧៥ ប៉ុន្តែភ្នំពេញត្រូវបានរំដោះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វិញ មានន័យថា មុន១ថ្ងៃ។

[១៥:២៧:០២]

ចំពោះកងទ័ពដែលវាយចូលភ្នំពេញ ត្រូវបានថ្នាក់លើណែនាំមិនឲ្យវាយតប ជាមួយខ្មាំងពេលដែលគេលើកទង់សសុំចុះចាញ់ និងហាមប៉ះពាល់ទ្រព្យសម្បត្តិរបស់របរក្នុងទីក្រុង។ ខ្ញុំសូមសួរថា បន្ថែមពីបទបញ្ជាពីមេដឹកនាំខាងលើនេះមក តើលោកនៅចាំបានទេថា មានបទបញ្ជា ឬការណែនាំផ្សេងៗអ្វីបន្ថែមទៀតទេ បើតាមលោកនៅចាំ?

**ឆ៖** បាទ ខាងខ្ញុំមិនមានណែនាំអីទៀតទេ។

**ស៖** ក្នុងសំណួរដដែល ខ្ញុំសួរថា មុខព្រួញខាងភូមិភាគបូព៌ា និរតីជាដើម បានប្រជុំជាមួយអគ្គសេនាធិការ មាន តា សុន សេន និង តា នួន ជា ជាអ្នកដឹកនាំប្រជុំជាមួយមេកងពលគ្រប់ភូមិភាគ។ លោកដឹងថា អគ្គសេនាធិការហ្នឹងមានលោក សុន សេន និងជាមួយ នួន ជា លោកដឹងហ្នឹងតាមរយៈអ្វី? តាមរយៈណា ថាលោក សុន សេន ជាមួយ នួន ជា រៀបចំផែនការដើម្បីវៃចូល?

**ឆ៖** បាទ ពីព្រោះខ្ញុំជាអនុ ខ្ញុំត្រូវទទួលបញ្ជា ហើយក៏គាត់ -- តាសឿង គាត់ស្នងការ គាត់អាចទៅប្រជុំ ៗហើយបានគាត់ដឹងផែនការមកផ្សព្វផ្សាយដល់ខ្ញុំ ខ្ញុំផ្សព្វផ្សាយដល់វរសេនាធំ តគ្នាអ៊ីចឹងទៅបាទ។

[១៥:២៨:១៦]

**ស៖** ពេលនោះ តាសឿង ហ្នឹងបានប្រាប់ច្បាស់អ៊ីចឹងថា អគ្គសេនាធិការហ្នឹងមាន សុន សេន ជាមួយ នួន ជា អ៊ីចឹង ឬក៏តា សុន សេន ឬ តា ម៉ុក?

**ឆ៖** បាទ គាត់មិនបានប្រាប់ឈ្មោះថា តា សុន សេន ឬលោក នួន ជា គាត់អត់ប្រាប់អ៊ីចឹង។ គាត់បានទៅប្រជុំផ្ទះអគ្គបញ្ជាការ គាត់មិនបានប្រាប់ឈ្មោះថាលោក សុន សេន ឬលោក នួន ជា ឬលោក ខៀវ សំផន អីគាត់អត់បានប្រាប់ទេ គាត់ថាផែនការរបស់អង្គការ ត្រូវឲ្យយើងរៀបចំផែនការវ៉ៃសម្រុកទីក្រុងភ្នំពេញ ហៅថា "សមរភូមិ៩៩០" ហើយធ្វើយ៉ាងម៉េចយើងរៀបចំ វ៉ៃឲ្យឈ្នះក្នុងថ្ងៃ១៨ មេសា។ ហ្នឹងក៏គាត់មានប្រាប់អ៊ីចឹងទេ គាត់ប្រាប់តែផែនការដែលប្រយុទ្ធ ឯឈ្មោះគាត់មិនបានប្រាប់ថាអ្នកនេះអ្នកនោះ ឬក៏គាត់ថា ទៅប្រជុំកន្លែងនេះកន្លែងនោះ។ គាត់បានប្រាប់ថា ថ្នាក់លើដាក់ផែនការមកក៏ផ្សព្វផ្សាយអ៊ីចឹង។ ខ្ញុំទទួលផែនការពី តាសឿង បាទ។

[១៥:៣០:៣៦]

**ស៖** អរគុណ។ លោកបានឆ្លើយអំមិញថា អត់បានទទួលដឹងថា អគ្គសេនាធិការហ្នឹងជាអ្នកណាទេ ប៉ុន្តែលោកឆ្លើយនៅក្នុង -- ឆ្លើយតបទៅនឹងចៅក្រមស៊ើបអង្កេតថា អគ្គសេនាធិការដែលមាន សុន សេន និង នួន ជា។ លោកសំអាងទៅលើអ្វី បានជាលោកឆ្លើយថា ឈ្មោះពីរនាក់ហ្នឹង អំមិញលោកថា មិនដឹងជាអ្នកណាទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ក៏ប៉ុន្តែវាប្រហែលជាបញ្ហាបកប្រែតែប៉ុណ្ណោះ។ តាមបកប្រែជាភាសាអង់គ្លេស ខ្ញុំស្តាប់ទៅហាក់ដូចជា មេធាវីនេះលើកឡើងភស្តុតាងចម្លើយរបស់សាក្សីខុស។ មេធាវីលើកឡើងថា "សាក្សីបានឆ្លើយថាគាត់មិនបានដឹង អំពីអគ្គសេនាធិការ"។ តាមពិតទៅ សាក្សីបាននិយាយថា "តាសឿង មិនបានលើកឈ្មោះបុគ្គលណានោះទេ"។ ចំណុចនេះ វាមានភាពខុសគ្នាដូច្នេះ ក៏ប៉ុន្តែវាជាចំណុចសំខាន់។ សាក្សីគាត់មិនបាននិយាយដូច្នោះ ដូចអ្វីដែលមេធាវីបានលើកឡើងនោះទេ។

**សួរដោយលោក សុន អរុណ៖**

**ស៖** នៅក្នុងចម្លើយសារភាពរបស់លោកសាក្សី ជាមួយនឹងចៅក្រមស៊ើបអង្កេត នៅ E3/424 ចម្លើយលេខ៣ បានឆ្លើយច្បាស់អ៊ីចឹង "មុនពេលវាយចូលភ្នំពេញ មុខព្រួញខាងភូមិភាគបូព៌ា និរតីជា

ដើមបានប្រជុំជាមួយអគ្គសេនាធិការ មានតា សុន សេន និងតា នួន ជា ជាអ្នកដឹកនាំប្រជុំជាមួយកងពលគ្រប់ភូមិភាគ ហើយប្រធានកងពលបានយកមកផ្សព្វផ្សាយបន្តមកដល់កងវរសេនាធំ"។ នេះច្បាស់ណាស់។ អ៊ីចឹងមិញគាត់ -- អ៊ីចឹង ខ្ញុំសួរបន្ថែមថា ហេតុអីបើលោកថា លោកដឹងថា អគ្គសេនាធិការ ប៉ុន្តែឈ្មោះអ្នកណាៗ លោកមិនបានដឹងទេ។ តើលោកឥឡូវលោកខ្ញុំសួរថា តើលោកដឹងឈ្មោះ សុន សេន និង នួន ជា ប្រជុំហ្នឹងលោកបានដឹងមកពីណា? ហើយហេតុអីបានជាលោកឆ្លើយថា លោកមិនបានដឹងឈ្មោះអ្នកណាទេ ប៉ុន្តែលោកឆ្លើយចំពោះមុខចៅក្រមស៊ើបអង្កេត លោកថា ឈ្មោះពីរនាក់នុ៎ង?

[១៥:៣៣:៣០]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំមិនបានថា បញ្ជាក់ក្នុងអគ្គសេនាធិការ គាត់មិនបានប្រាប់ឈ្មោះទេ ក៏ប៉ុន្តែដែលខ្ញុំដឹងនោះ ខ្ញុំដឹងដល់ក្រោយថ្ងៃរំដោះហើយ បានដឹងថាអគ្គបញ្ជាការលោក សុន សេន ហើយនិង តាម៉ុក។ ឯក្នុងពេលដែលមិនទាន់រំដោះនោះ គឺអត់បានៗបញ្ជាក់ទេ ហ្នឹងគឺថា នៅពេលដែលខ្ញុំដឹង គឺថាដែលក្រោយរំដោះហើយ បានដឹងថា អគ្គបញ្ជាការ។ ហើយក្នុងពេលប្រជុំពេលនោះគឺថា អត់ទទួលផែនការពីកងពល។ លេខាកងពលទៅទទួលផែនការពីៗខាងលើមកផ្ទាល់ ហើយគាត់មិនបានប្រាប់ឈ្មោះកន្លែងនោះទេបាទ។

**ស៖** បើដូច្នោះ ចម្លើយលោកជាមួយនឹងចៅក្រមស៊ើបអង្កេត ឈ្មោះ តា សុន សេន ជាមួយ នួន ជា ដែលមានធ្វើប្រតិចារឹកដូចហើយហ្នឹង លោកនៅរក្សាទុកចម្លើយហ្នឹងដដែល ឬក៏លោកៗលុបឃ្លាហ្នឹងចោល?

**ឆ៖** បាទ ខ្ញុំអត់ត្រូវ -- លុបចេញទៅ ព្រោះខ្ញុំដឹងថា ដល់ក្រោយរំដោះបានខ្ញុំដឹងថា តា សុន សេន ជាអគ្គបញ្ជាការ ប៉ុន្តែក្នុងពេលសមរភូមិពេលនោះ គឺអត់មានឈ្មោះគាត់ អត់មាន គេអត់មានប្រាប់ឈ្មោះខ្ញុំទេ លេខាកងពលអត់ប្រាប់ឈ្មោះ។ ហើយបើៗប្រាប់ឈ្មោះ ខ្ញុំប្រាប់ថា ដឹងឈ្មោះ ប៉ុន្តែគាត់អត់ប្រាប់ គាត់ប្រាប់ថា "ផែនការថ្នាក់លើឲ្យរៀបចំវ៉ៃសម្រុក ហើយកុំដកថយឲ្យសោះ" គឺគាត់បានប្រាប់អ៊ីចឹងបាទ។

**ស៖** បើអ៊ីចឹងខ្ញុំសូមបញ្ជាក់ម្តងទៀត ពេលដែលលោកឆ្លើយចំពោះចៅក្រមស៊ើបអង្កេតថា មានអគ្គសេនាធិការប្រជុំហ្នឹងដែលមានឈ្មោះ សុន សេន និង នួន ជា លោកមិនបានឆ្លើយចំពោះចៅក្រមស៊ើបអង្កេតទេ។ លោកពិតជាអ៊ីចឹងណាស់ ឬក៏លោកចង់ផ្លាស់ប្តូរយ៉ាងម៉េច ឬក៏ -- ខ្ញុំសួរថាលោក

ឆ្លើយហ្នឹងគឺលោកមិនទទួលស្គាល់ទេ តើលោកត្រូវការលុបឃ្លាហ្នឹងចោល ឬក៏យ៉ាងម៉េច ហ្នឹងសូមសួរម្ដងទៀត?

[១៥:៣៥:៥៨]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីអាននូវឯកសារ E3/200 -- 424 ត្រង់ចម្លើយតបទៅនឹងសំណួរលេខ៣ លោកមេធាវី -- មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់ឯកសារឲ្យគាត់អាន អានឲ្យចប់សិនទៅ សូមពិចារណាហើយឆ្លើយតប។ សំណួរចុះឡើងៗអ៊ីចឹង មិនយល់ថា បំណងនៃសំណួរហ្នឹងសួរថាយ៉ាង ចង់បានអី ហើយចម្លើយឆ្លើយថាម៉េចទេ។

*(សាក្សីអានឯកសារកំណត់ហេតុស្ដាប់ចម្លើយ)*

[១៥:៣៧:១៥]

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកសាក្សីចង់ខ្ញុំអានជូន ឬក៏លោកអានរួចហើយ ហើយលោកនឹងឆ្លើយ?

**លោក មាស វឿន៖**

**ឆ៖** បាទ ចំណុចនេះ ខ្ញុំមិនបានទេ សូមលុបចោលឃ្លាហ្នឹង ពីព្រោះខ្ញុំមិនបានបញ្ជាក់ថាឈ្មោះលោក នួន ជា ឬក៏ សុន សេន។ ខ្ញុំបានបញ្ជាក់តែពីកងពលប្រាប់ប៉ុណ្ណឹង។ ដូច្នេះឃ្លានេះ ឃ្លាបកប្រែទ្បំយ៉ាងណា ខ្ញុំមិនដឹងដែរ។

**ស៖** សូមអរគុណ ខ្ញុំសួរបន្តទៅទៀត។ លោកបានដឹងទេថា មុខព្រួញវាយមកពីខាងទិសបស្ចិមដែលសព្វថ្ងៃគេហៅ តំបន់កប់ស្រូវម្ដុំហ្នឹង។ តើកងពលណាដែលៗវាយចូលៗមកតាមច្រកបស្ចិមនោះ? មានន័យថាខាងម្ដុំកប់ស្រូវប្រហែលជាលោកសាក្សីដឹងដែរ ស្គាល់ ប៉ុន្តែខ្ញុំនិយាយថា វៃចូលតាមច្រកបស្ចិម តើលោកដឹងទេពេលនុ៎ង?

**ឆ៖** បាទ តាមវត្តកប់ស្រូវ កងពលទី១ មួយកំណាត់ដែរ។

**ស៖** ហើយមួយកំណាត់ទៀត កងពលខាងណាលេខប៉ុន្មានលោកអាចដឹងទេ?

**ឆ៖** បាទ មួយកំណាត់ទៀតកងពលឧត្ដរ តែមិនដឹងថាលេខប៉ុន្មានទេ។ ខ្ញុំមិនចាំលេខកងពលគេទេ។

[១៥:៤០:០០]

**ស៖** លោកកាន់កងវរសេនាធំ ពេលដែលវ៉ៃចូលភ្នំពេញ។ លោកបានបញ្ជាឲ្យវ៉ៃចូល ឬក៏វ៉ៃចេញ ឬក៏យ៉ាងម៉េច បញ្ជាដោយផ្ទាល់នុ៎ង គឺបញ្ជាពីខាងណា? ពីគណៈសេនាធិការ ឬក៏ពីមេកងពល?

**ឆ៖** បាទ ទទួលពីកងពល។

**ស៖** ប៉ុន្តែលោកអាចដឹងទេថា កងយោធាទាំងគ្រប់ទិស វ៉ៃចូលគ្រប់ច្រកចូលភ្នំពេញ លោកអាចដឹងថា ទិសណា? កងពលណា? ពីទិសណា? កងពលណា? ដឹងៗទាំងអស់ទេ ឬក៏ថាដឹងតែខាងលោក?

[១៥:៤១:០២]

**ឆ៖** បាទ ខ្ញុំដឹងពីខាងលិច ដឹងថា កងពលលេខ១ ហើយពីខាង ភ្ជាប់ពីៗពួនភ្នំ ទៅកើតមានកងពលឧត្តរ ហើយពីកើតទៀត ខ្ញុំអត់បានដឹងថា កងពលណាទេ។ ប៉ុន្តែគាត់ៗប្រាប់ថា បូព៌ា ប៉ុន្តែមិនដឹងបូព៌ាកងលេខប៉ុន្មាន ខ្ញុំមិនដឹងដែរ មិនដឹងកងគេលេខប៉ុន្មាន។ ហើយមានកងពលពិសេស ក៏អត់ដឹងលេខដែរ។ បាទ ប៉ុណ្ណឹង។

**ស៖** លោកបានឆ្លើយ ជម្រាបទៅចៅក្រមស៊ើបអង្កេតថា "ការ ក្នុងការ -- ក្នុងបញ្ជារបស់គណៈសេនាធិការ ថាវ៉ៃចូលដល់ភ្នំពេឲ្យបាននៅថ្ងៃ១៨"។ អាហ្នឹង តាមសម្ដីលោកមាននិយាយ ប៉ុន្តែដោយចៃដន្យ ឬក៏ដោយហេង ឬក៏ដោយយ៉ាងម៉េច បានវ៉ៃចូលថ្ងៃទី១៧ មានន័យថា មុន១ថ្ងៃ។ លោកអាចដឹងថា ហេតុផលអ្វីទេ បានជាឈ្នះមុន១ថ្ងៃអ៊ីចឹង? លោកដឹងទេ ហើយលោកអាចជម្រាបតុលាការបានទេ?

**ឆ៖** បាទ ក្នុងពេលដែលវ៉ៃឲ្យឈ្នះថ្ងៃ១៨ មេសានោះ ជាផែនការរបស់កងពលប្រាប់ ប៉ុន្តែដល់វ៉ៃដែលឈ្នះថ្ងៃ១៧ មេសា វិញនោះ ដោយកងពលប្រាប់ថា "កម្លាំងរបស់ខ្មាំងត្រូវមានការចុះចាញ់ ឬក៏ថមថយ ដោយស្មារតីប្រយុទ្ធមិនសូវមាន។ ដូច្នេះ យើងត្រូវរៀបចំប្រយុទ្ធឲ្យកាន់តែខ្លាំងថែមទៀត ដើម្បីយើងសំដៅទៅទីក្រុងភ្នំពេញ"។ ដូច្នេះ ដល់ពេលដែលយើងវ៉ៃទៅ ដោយត្រូវនឹងកងពលបានប្រាប់ថា ស្មារតីរបស់ខ្មាំង មិនមានស្មារតីប្រយុទ្ធ។ ដូច្នេះការដែលវ៉ៃទៅឈ្នះ ថ្ងៃ១៧ មេសា។ នេះហើយដែលយើងខ្ញុំដឹងថា ជាក់ស្ដែងអ៊ីចឹង។

[១៥:៤៣:៥៤]

**ស៖** ខ្ញុំមានសំណួរមួយទៀត បើលោកមិនដឹង លោកឆ្លើយថា មិនដឹង បើលោកដឹង សូមលោកជម្រាបតុលាការ។ ហេតុដែលឲ្យមានការវ៉ៃឈ្នះមុន១ថ្ងៃ តាម -- ឈ្នះមុនគម្រោង១ថ្ងៃនុ៎ង លោកមាន

ឮពីកងពល ឬពីអគ្គសេនាធិការអីបានប្រាប់ថា មានការចរចាពីរដ្ឋាភិបាល លន់ នល់ និងកងទ័ពខ្មែរក្រហមឬទេ?

**ឆ៖** បាទ ត្រង់ហ្នឹង អត់បានដឹងទេ។

[១៥:៤៤:៣៧]

**ស៖** អរគុណ។ ត្រង់ចម្លើយរបស់លោកសាក្សីទៅចៅក្រមស៊ើបអង្កេត នៅត្រង់ឯកសារ E3/73 ចម្លើយលេខ១១ "ប្រជុំនៅខែមីនា ឆ្នាំ១៩៧៦ ដែលរៀបចំឡើង ដោយតា ជូ ជេត ធ្វើនៅច្បារមន ភូមិភាគបស្ចិម កំពង់ស្ពឺ ហើយនិងមានប្រជុំនៅកំពង់ឆ្នាំង ពេលនោះ មានតា នួន ជា ឬតា ប៉ុល ពត" ពេលនោះលោកសាក្សីបានចូលរួមទេ ពេលដែលប្រជុំនៅកំពង់ឆ្នាំង ឬក៏នៅច្បារមននោះ? កំពង់ឆ្នាំងមានន័យថា នៅលង្វែក។

**ឆ៖** បាទ បានប្រជុំៗមែន ប៉ុន្តែខ្ញុំនៅ ប្រជុំនៅកំពង់ស្ពឺនោះ កន្លែង តាស៊ី នុំងប្រជុំអត់បានចប់ទេ។ ដោយបង សឿង ឲ្យខ្ញុំទៅសមរភូមិវិញ ដោយសភាពការណ៍ខាងព្រំដែនអត់ស្រួល។

**ស៖** លោកឆ្លើយអំមិញថា អាហ្នឹងប្រជុំនៅច្បារមនកំពង់ស្ពឺអ៊ីចឹង?

**ឆ៖** បាទ។

**ស៖** ចុះប្រជុំនៅលង្វែក កំពង់ឆ្នាំងលោកបានចូលរួមទេ?

[១៥:៤៦:៥៣]

**ឆ៖** បាទ បានចូលរួមកន្លែងនុំង។

**ស៖** បើលោកបានចូលរួមកន្លែងប្រជុំទាំងពីរ លោកច្បាស់ថា ប៉ុល -- ក្រោមការប្រជុំរបស់ នួន ជា ឬក៏របស់ ប៉ុល ពត?

**ឆ៖** បាទ ក្នុងពេលដែលប្រជុំនុំង ខ្ញុំឃើញតែតា ប៉ុល ពត គាត់អ្នកដឹកនាំប្រជុំ ហើយនិង តាស៊ី គាត់ដឹកនាំប្រជុំ។ ឯចំណែកលោក នួន ជា អត់បានឃើញមុខគាត់។

**ស៖** បើដូច្នេះការប្រជុំទាំងពីរ ដូចលើកឡើងខាងលើនេះ មិនមានលោក នួន ជា ចូលរួមប្រជុំទេ គឺលោក ប៉ុល ពត ប្រាកដជាអ៊ីចឹងទេ ឬយ៉ាងម៉េច?

**ឆ៖** បាទ ប្រាកដ។

[១៥:៤៨:១៣]

**ស៖** បើដូច្នេះ លោកឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា មានលោក នួន ជា ឬ ប៉ុល ពត

អាហ្នឹងលោក សូមលុបចោល ឬក៏លោកទុកឃ្លាហ្នឹងដដែល?

**ឆ៖** បាទ អង្កាល់នោះ ខ្ញុំឮបងសឿង គាត់ប្រាប់ខ្ញុំថា លោក នួន ជា មកដែរ ក៏ប៉ុន្តែខ្ញុំមិនឃើញ បានន័យថា ខ្ញុំថាអត់ឃើញ។ ក៏ប៉ុន្តែបើលោក ប៉ុល ពត ហើយនិង តាស៊ី ហើយម្នាក់ទៀត អ៊ំប៉ាល់ អ៊ំ និង តាប៉ាល់ ឃើញគាត់មកប្រជុំ។ នេះខ្ញុំឃើញថា ចំពោះលោក នួន ជា ខ្ញុំអត់បានឃើញ មិនដឹងគាត់មានវត្តមាន ឬអវត្តមានយ៉ាងណា ខ្ញុំមិនឃើញគាត់ពេលនោះ។ អ៊ីចឹងខ្ញុំថា កំណត់ថា លុបចោល។

**ស៖** សូមអរគុណ។ ខ្ញុំបន្តទៅសំណួរខាងក្រោម--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកខាងតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ រវាងសំណួរទាំងពីរនេះ គឺថានីតិវិធីដែលមេធាវីគាត់កំពុងតែអនុវត្តហ្នឹង គឺមិនសមស្របនោះទេ។ មិនជាការសមស្របក្នុង ដែលទៅសួរសាក្សីថា សាក្សីចង់ដកចម្លើយរបស់ខ្លួនចេញពីកំណត់ហេតុ ដូច្នេះគឺមិនត្រឹមត្រូវទេ មិនអាចអនុវត្តនីតិវិធីបែបនេះ នៅក្នុងតុលាការបានទេ។ គ្រាន់តែបើសួរថា តើចម្លើយរបស់លោកហ្នឹងត្រឹមត្រូវឬក៏អត់? មិនគួរណាសួរសាក្សីថា តើសាក្សីមានបំណងចង់ដកនូវចម្លើយរបស់ខ្លួនចេញពីកំណត់ហេតុស្តាប់ចម្លើយនោះទេ។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយចំពោះព្រះរាជអាជ្ញា សំណួរនេះទាំងខ្ញុំ ទាំងមេធាវីការពារមួយចំនួនបានប្រើរួចទៅហើយ។ ហើយប្រើទៅរួច មិនមានជំទាស់អ្វីព្រះរាជអាជ្ញាទេ។ សាក្សីមានសិទ្ធិនឹងដក ឬសុំលុបចោលនូវប្រតិចារឹកដែលមានសរសេរអ្វីដែលគាត់បដិសេធ។

[១៥:៥០:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ចំណុចនេះក៏អាចប៉ះពាល់ដល់ក្រុមយើងខ្ញុំដែរ។ ខ្ញុំសូមមានយោបល់ថា សហព្រះរាជអាជ្ញាលើកឡើងនេះមិនត្រឹមត្រូវទេ គឺមេធាវីអាចលើកឡើងថា ចម្លើយរបស់សាក្សីនេះ គឺថាអ្វីដែលគាត់ឆ្លើយគឺមិនស៊ីសង្វាក់ទៅនឹងអ្វីដែលគាត់ឆ្លើយនៅក្នុងកំណត់ហេតុស្តាប់

ចម្លើយនោះទេ។ ខ្ញុំគិតថា មេធាវីក្រុមមេធាវីការពារ នួន ជា ប្រហែលជាគាត់អាចប្រើពាក្យពេចន៍ខុសតែប៉ុណ្ណោះ ដូចជា ការសុំដកចេញ ឬក៏លុបអីយ៉ាងនេះ។ ក៏ប៉ុន្តែបើសិនណា១ ជាសាក្សីគាត់យល់ឃើញថាចម្លើយដែលគាត់បានផ្តល់ហ្នឹង គឺវាមិនត្រូវគ្នាជាមួយនឹងចម្លើយ ដែលគាត់កំពុងតែឆ្លើយនោះ ជាការសមស្របណាស់ដែលអាចថាសុំឲ្យដក ឬក៏យ៉ាងណានោះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគាំទ្រចំពោះការលើកឡើងរបស់មេធាវីការពារទាំងពីរក្រុម។ ហើយខ្ញុំយល់ថា សាក្សីមានសិទ្ធិដកចេញនូវចម្លើយរបស់ខ្លួនទាំងឡាយណា ដែលខ្លួនយល់ឃើញថាមិនត្រឹមត្រូវ។ ពីព្រោះប្រតិចារឹក ទាំងកំណត់ហេតុនៅក្នុងចៅក្រមស៊ើបសួរស៊ើបអង្កេតនោះ មិនមែនជាចម្លើយស្រង់តាមសម្តីគ្រប់ម៉ាត់របស់សាក្សីទេ វាជាប្រភេទនៃការសង្ខេបរបស់អ្នកស៊ើបអង្កេត។

[១៥:៥២:១៤]

ដូច្នេះវាអាចមានការខុសឆ្គងខ្លះ ជាយថាហេតុ។ អ៊ីចឹងហើយបានថាសិទ្ធិនៃការប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការដកនូវចំណុចទាំងឡាយណា ដែលមិនសមគួរ មិនត្រឹមត្រូវនេះ គឺត្រូវតែអនុវត្ត។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកបញ្ជាក់បន្តិចមើលលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន។ លោកអំមិញគាំទ្រនូវការលើកឡើងរបស់មេធាវីទាំងពីរក្រុម បើតាមយើងស្តាប់ទៅមេធាវីទាំងពីរក្រុមនេះពិតមែនតែមានគំនិតដូចគ្នា តែការប្រើពាក្យខុសគ្នា។ ហើយពាក្យនេះខុសគ្នាឆ្ងាយណាស់ បើចេញជាភាសាខ្មែរ គឺខុសគ្នាឆ្ងាយមែនទែននៅក្នុងក្នុងកិច្ចនីតិវិធីរវាងសុំដកចេញ ឬក៏លុបចេញពីកំណត់ហេតុស្តាប់សក្ខីកម្មរបស់ខ្លួន និងចម្លើយហ្នឹងគឺវាមិនស៊ីសង្វាក់គ្នា។ ពាក្យនេះខុសគ្នាឆ្ងាយណាស់ នៅក្នុងជាការប្រើប្រាស់ជាភាសាខ្មែរ ពីព្រោះវាពាក់ព័ន្ធនឹងនីតិវិធីដែលត្រូវប្រព្រឹត្តទៅ។ តើលោកអះអាងថា ឯកភាពទាំងពីរហ្នឹង វា១ហេតុយ៉ាងម៉េចទៅ ដែលបញ្ជាក់បញ្ជាឯកភាពទាំងពីរនេះ? លោកយល់ថា ទាំងពីរហ្នឹងជារឿងតែមួយ ឬក៏ទាំងពីរនេះវាជារឿងខុសគ្នា?

[១៥:៥៣:៣០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ជាការពិត គឺថាការដកចេញនូវកំណត់ហេតុវាអាចដកទាំងស្រុង ក្នុងករណីដែលកំណត់ហេតុនោះវាខុសទាំងស្រុង។ ក៏ប៉ុន្តែបើសិនជាកំណត់ហេតុនោះវាខុសតែផ្នែកណាមួយ ចំណុចណាមួយ ដូច្នេះការលុបចេញនូវផ្នែកណាមួយនោះ វាជាសិទ្ធិរបស់សាក្សី។ នេះខ្ញុំចង់បញ្ជាក់ជាលក្ខណៈរួម ជាគោល។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមអធ្យាស្រ័យដែលខ្ញុំលើកមតិនៅក្រោយក្រុមការពារក្តី។ សេចក្តីដែលមានសរសេរនៅក្នុងកំណត់ស្តាប់យកចម្លើយរបស់សាក្សីរូបនេះ តាមការពិតត្រូវបានអានជូនសាក្សី ហើយសាក្សីក៏បានផ្តិតមេដៃថាបានត្រឹមត្រូវរួចហើយ។

[១៥:៥៤:៣០]

ដូច្នេះហើយនៅពេលនេះ គឺជាពេលដែលភាគីមានសិទ្ធិនៅក្នុងការសួរដើម្បីបញ្ជាក់អំពីចំណុចនានា ហើយដែលទោះថាចំណុចនានា ដែលសួរចេញពីការបញ្ជាក់នេះ អាចមានព័ត៌មានដូចគ្នាក្តី ព័ត៌មានខុសគ្នាក្តី ផ្ទុយគ្នាក្តី ក៏គួរទុក -- សាក្សីមិនមានសិទ្ធិនៅក្នុងការដកឃ្លានេះចេញបានទេ ហើយដោយសារខ្លួនបានផ្តិតមេដៃរួចហើយនៅក្នុងការទទួល។ ក៏ប៉ុន្តែខ្ញុំយល់ថា គួរតែទុកលទ្ធភាពនៅក្នុងការពិចារណាអំពីមតិរបស់សាក្សីដែលផ្តល់ភស្តុតាងនេះ ទុកជូនចៅក្រមនៅក្នុងការពិចារណា ដោយប្រើឆន្ទានុសិទ្ធិរបស់ខ្លួនវិញល្អជាង ដើម្បីពិនិត្យថាតើមតិរបស់សាក្សី ដែលបាននិយាយពេលមុន ហើយនិងពេលក្រោយខុសគ្នានោះ ថាតើមតិមួយណាដែលអាចទទួលយកបាន។ សូមអរគុណលោកប្រធាន។

[១៥:៥៥:២៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៧:៤៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ក្រោយពីការពិភាក្សាគ្នាយ៉ាងខ្លីមក អង្គជំនុំជម្រះគឺយល់ឃើញថា មិនមាននីតិវិធីណាសមស្រប ដើម្បីឲ្យឆ្លូតចោល លុបចោលនូវកំណត់ហេតុស្ដាប់ចម្លើយ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ ក៏ប៉ុន្តែអង្គជំនុំជម្រះយល់ឃើញថា យើង -- សក្ខីកម្មផ្ទាល់មាត់របស់សាក្សីរូបនេះ ក្នុងការដែលផ្ដល់ទម្ងន់ណាមួយដែលថា សមស្របនៅក្នុងការផ្ដល់ភស្តុតាងរបស់គាត់នោះ ដើម្បីឲ្យយើងអង្គជំនុំជម្រះ គឺថាអាចនឹងឈានទៅដល់ការធ្វើការសម្រេចសេចក្ដីមួយប្រកបដោយហេតុផល។

អស់លោក លោកស្រីចៅក្រមដទៃទៀតមានសំណួរអីដែរ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

មិនមានអីទៀតទេ។ សូមអញ្ជើញលោកមេធាវី សុន អរុណ បន្តការតាំងសំណួរ។

[១៥:៥៨:៥៤]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តសំណួរនេះទៅមុខទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** នៅក្នុងឯកសារលេខ E3/424 ចម្លើយទី១ របស់សាក្សីឆ្លើយចំពោះចៅក្រមស៊ើបអង្កេត។ តាំងពីឆ្នាំ១៩៧០ លោកបានចូលធ្វើ -- ចូលបដិវត្តន៍ធ្វើយោធារហូតដល់ឆ្នាំ -- ដល់ខែមេសា ឆ្នាំ ១៩៧៥។ លោកដែលឮឈ្មោះ នួន ជា ទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ដល់ឆ្នាំ១៩៧៥ ខ្ញុំឮឈ្មោះហើយ។

**ស៖** លោកឮឈ្មោះ ប៉ុន្តែដែលលោក -- ដែលៗបានជួបលោក នួន ជា ផ្ទាល់ឬក៏បានធ្វើលិខិតឆ្លងឆ្លើយទំនាក់ទំនងអ្វីជាមួយគាត់ទេ?

**ឆ៖** បាទ គ្មានទេ។

**ស៖** បើដូច្នេះ លោកមិនស្គាល់លោក នួន ជា ច្បាស់លាស់ទេ លោកគ្រាន់តែឮឈ្មោះតាមរយៈអ្នកដទៃនិយាយពីឈ្មោះគាត់តែប៉ុណ្ណឹងទេ អ៊ីចឹងឬយ៉ាងម៉េច?

[១៦:០០:៣៦]

**ឆ៖** បាទ មិនមែនតាមរយៈអ្នកដទៃទេ ឮតាមកងពលខ្ញុំប្រាប់។

**ស៖** អរគុណ។ នៅពេលដែលវ៉ៃចូលភ្នំពេញ ពីកងឯកភាពមួយ ពីកងពលមួយទៅកងពលមួយ ហើយពីកងពលមួយមកថ្នាក់ក្រោមបង្គាប់។ ឧទាហរណ៍ដូចជាខាងកងវរសេនាធំរបស់លោកអ៊ីចឹង ការទំនាក់ទំនងរវាងកងឯកភាពមួយទៅឯកភាពមួយ គេទំនាក់ទំនងតាមរបៀបណា?

**ឆ៖** បាទ រវាងក្នុងសមរភូមិ ពីវរសេនាធំមួយទៅវរសេនាធំមួយ យើងដាក់ជាប់គ្នាដែរ ជាប់គ្នា ហើយមានកិច្ចការងារអីចាំបាច់ យើងដើរតាមខ្សែត្រៀមយើងអ៊ីចឹងទៅ ហើយជួបគ្នាទៅ នេះកន្លែង -- ឧបមាថា នេះជាកន្លែងខ្ញុំ នោះជាកន្លែងគេអ៊ីចឹង គឺដឹងថា នេះក្របខ័ណ្ឌពីត្រឹមនេះទៅត្រឹមនេះ គឺកងខ្ញុំអ៊ីចឹងទៅ ហើយពីត្រឹមនោះៗ គឺកងគេអ៊ីចឹងទៅ ហើយស្គាល់ឈ្មោះគ្នាអ៊ីចឹងទៅតាមវរសេនាតូច ឬក៏វរសេនាធំ ដែលអាចជាប់គ្នា។ ហើយកងវរសេនាធំហ្នឹងដើរសម្រួលតាមខ្សែត្រៀមរហូតអ៊ីចឹងទៅ ហើយវរសេនាតូច ដែលនៅជាប់នៅត្រង់សេជាមួយគ្នានឹងយុទ្ធជនទាំងអស់គ្នា គឺអត់នៅឆ្ងាយពីគ្នាទេ នៅជាប់តែជាមួយគ្នា រហូតដូចយើងអង្គុយអ៊ីចឹង បាទ។

**ស៖** សូមអរគុណ។

**លោក សុន អរុណ៖**

លោកប្រធានសូមទោស ខ្ញុំមានសំណួរប្រហែលប្រាំប្រាំមួយសំណួរទៀត លោក -- ឥឡូវដល់ម៉ោងហើយ តើអាចបញ្ចប់ពេលហ្នឹង ឬក៏ខ្ញុំអាចបន្តទៅទៀតបាន?

[១៦:០៣:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។ អរគុណសាក្សី។ បាទ កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការ សម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី៩ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី មាស វឿន ដែលនឹងបន្តសួរដេញដោលដោយក្រុមមេធាវីការពារក្ដី នួន ជា និង មេធាវីពីរក្រុមទៀត។ សូមភាគី និងសាធារណជនជ្រាប។

លោក មាស វឿន ការស្ដាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ សវនាការនឹងបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត គឺ

ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយក្រុម -- មេធាវីប្រឹក្សាសាក្សី ក៏អញ្ជើញមកចូលរួមនៅក្នុងសវនាការដូចគ្នា នឹងសាក្សីដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*